**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា**

# ការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **គណៈកម្មការមូលបត្រកម្ពុជា**

| | |
|---|---|
| តាក់តែងឡើងដោយ | សាស្ត្រាចារ្យណែនាំ |
| និស្សិតឈ្មោះ **ម៉ៅ ស្រីអ៊ិញ** | លោក **សួន ចំរើន** |
| **តឿ ឆេងតាយ** | |

| | | | |
|---|---|---|---|
| ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ | | ឆ្នាំចូលសិក្សា | ២០១៣ |
| ជំនាន់ទី ១០ | | ឆ្នាំសរសេររបាយការណ៍ | ២០១៧ |

# មាតិកា

ទំព័រ

បញ្ជីអក្សរកាត់ ..... v

ពាក្យបច្ចេកទេសមូលបត្រ ..... v

បញ្ជីតារាង ..... vi

បញ្ជីរូប ..... vii

បញ្ជីឧបសម្ព័ន្ធ ..... viii

# សេចក្ដីផ្ដើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ..... ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១

៣.គោលបំណងនៃការស្រាវជ្រាវ ..... ២

៤.ទំហំដែនកំណត់ និងវិសាលភាព ..... ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ..... ២

៦.វិធីសាស្ត្រនៃការស្រាវជ្រាវ` ..... ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៣

# ជំពូកទី១ ទីផ្សារមូលបត្រនៅកម្ពុជា

១.១. ទីផ្សារមូលបត្រ ..... ៥

១.១.១. និយមន័យ ..... ៥

១.១.២. ប្រវត្តិនៃទីផ្សារមូលបត្រនៅកម្ពុជា ..... ៥

១.២. ប្រភេទនៃទីផ្សារមូលបត្រ ..... ៦

១.២.១.ចំណាត់ថ្នាក់នៃប្រភេទទីផ្សារហិរញ្ញវត្ថុ ..... ៦

១.២.២.ប្រភេទនៃមូលបត្រ ..... ៦

១.២.៣. អ្នកចូលរួមក្នុងទីផ្សារ ..... ៧

១.២.៤. ទីផ្សារភាគហ៊ុន ..... ៨

១.២.៤.១. ទីផ្សារដំបូង ..... ៨

១.២.៤.២. ទីផ្សារបន្ទាប់ ..... ៨

១.២.៤.៣. ការផាត់ទាត់ និងទូទាត់(កាត់កងរវាងអ្នកទិញ និងអ្នកលក់មូលបត្រ)............ ៩
១.២.៤.៤. នីតិវិធីនៃការចុះបញ្ជីផ្លូវការ........................................................................១០
១.២.៤.៥. ឯកសារផ្តល់ព័ត៌មានសាជីវកម្ម ..................................................................១០
១.២.៥.ទីផ្សារសញ្ញាបណ្ណ.........................................................................................១១
១.២.៥.១. និយមន័យសញ្ញាបណ្ណ.............................................................................១១
១.២.៥.២. ភាពខុសគ្នារវាងសញ្ញាបណ្ណ និងភាគហ៊ុន..................................................១១
១.២.៥.៣. អ្នកចូលរួមក្នុងទីផ្សារសញ្ញាបណ្ណ..............................................................១១
១.២.៥.៤. អ្នកបោះផ្សាយសញ្ញាបណ្ណ........................................................................១១
១.២.៦. កត្តាជោគជ័យនៃទីផ្សារមូលបត្រ ........................................................................ ១២
១.៣. មុខងារនៃទីផ្សារមូលបត្រ......................................................................................... ១២
១.៤. ប្រភេទនៃទីផ្សារមូលបត្រ.......................................................................................... ១២
១.៤.១. មូលបត្រមហាជន.............................................................................................១៣
១.៤.២. មូលបត្ររដ្ឋ .....................................................................................................១៤
១.៥. យន្តការទីផ្សារមូលបត្រ ..............................................................................................១៥
១.៥.១. យន្តការទីផ្សារដំបូង .........................................................................................១៥
១.៥.២. យន្តការទីផ្សារបន្ទាប់ .........................................................................................១៦
១.៦. កត្តាជំរុញឱ្យមានការវិនិយោគលើវិស័យមូលបត្រ.......................................................១៦
១.៧. តួនាទីចូលរួមក្នុងទីផ្សារមូលបត្រ................................................................................១៧
១.៧.១. តួអង្គសំខាន់ៗ.................................................................................................. ១៧
១.៧.២. តួអង្គដទៃទៀត ................................................................................................. ២៥
១.៨. អត្ថប្រយោជន៍ទីផ្សារមូលបត្រ.....................................................................................៣០

## ជំពូកទី២ ស្ថានភាពទូទៅនៃគណៈកម្មការមូលបត្រ

២.១.ប្រវត្តិនិងទីតាំងរបស់គណៈកម្មការមូលបត្រកម្ពុជា...................................................៣២
២.១.២ ក្រុមប្រឹក្សាភិបាល ...........................................................................................៣២
២.១.២. អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា.......................................................... ៣៣
២.២ និមិត្តសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា ........................................................... ៣៣

២.២.១ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា ........ ៣៣
២.២.១.១. រូបសញ្ញា ........ ៣៣
២.២.១.២. អត្ថន័យរូបសញ្ញា ........ ៣៤
២.២.១.៣. មូលហេតុនៃជម្រើសយករូបហង្សព្រណ៌មាសជានិមិត្តសញ្ញា ........ ៣៤
២.២.២ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៣៥
២.៣. ចក្ខុវិស័យរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៣៥
២.៤. បេសកកម្ម ឬគោលបំណងរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៣៦
២.៥ មុខងារ និងការគ្រប់គ្រងរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៣៦
២.៥.១. មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៣៦
២.៥.២. តួនាទី និងភារកិច្ចនៃនាយកដ្ឋាននីមួយៗ ........ ៣៧
២.៥.២.១. អង្គភាពសវនកម្មផ្ទៃក្នុង ........ ៣៧
២.៥.២.២. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ........ ៣៨
២.៥.២.៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ ........ ៣៩
២.៥.២.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ ........ ៤០
២.៥.២.៥. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ និងទំនាក់ទំនងអន្តរជាតិ ........ ៤១
២.៥.២.៦. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ........ ៤២
២.៥.២.៧. នាយកដ្ឋានគតិយុត្តិ ........ ៤៣
២.៥.៣. ប្រភពធនធាន និងការគ្រប់គ្រងហិរញ្ញវត្ថុ ........ ៤៤
២.៦. សមាសភាពរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៤៤
២.៦.១. អង្គការចាត់តាំងរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៤៤
២.៦.២. រចនាសម្ព័ន្ធរបស់គណៈកម្មការមូលបត្រកម្ពុជា ........ ៤៥

## ជំពូកទី៣ ការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ

៣.១. កិច្ចដំណើរការនៃការស្នើសុំអាជ្ញាប័ណ្ណ ........ ៤៧
៣.២. លក្ខខណ្ឌតម្រូវក្នុងការផ្តល់អាជ្ញាប័ណ្ណ ........ ៤៧
៣.២.១. លក្ខខណ្ឌបរិមាណ ........ ៤៩

៣.២.២. លក្ខខណ្ឌគុណភាព ......................................................................................................៤៩
៣.២.៣. កម្រៃសេវានៃការស្នើសុំ ......................................................................................................៥១
៣.៣. ការបដិសេធលើការស្នើសុំ...................................................................................................... ៥២
៣.៤. ការត្រួតពិនិត្យមុនផ្តល់អាជ្ញាប័ណ្ណ ......................................................................................................៥៤
៣.៤.១. ភាពរឹងមាំនៃហិរញ្ញវត្ថុ......................................................................................................៥៤
៣.៤.១.១. លក្ខខណ្ឌតម្រូវមូលធនភាគហ៊ុនិក......................................................................................................៥៤
៣.៤.១.២. លក្ខខណ្ឌតម្រូវលើមូលធនសុទ្ធ ......................................................................................................៥៤
៣.៤.១.៣. កម្រិតមូលធនសុទ្ធកាតព្វកិច្ច ......................................................................................................៥៤
៣.៤.១.៤. កាតព្វកិច្ចផ្តល់របាយការណ៍ស្ថានភាពមូលធនសុទ្ធ......................................................................................................៥៥
៣.៤.១.៥. វិធានការកែតម្រូវបន្ទាន់ ......................................................................................................៥៥
៣.៥.២. ក្រមសីលធម៌វិជ្ជាជីវៈ......................................................................................................៥៦
៣.៥.២.១. គោលការណ៍អាជីវកម្ម ......................................................................................................៥៦
៣.៥.២.២. គណនីអតិថិជន ...................................................................................................... ៥៧
៣.៥.២.៣. ការផ្តល់ព័ត៌មានទៅកាន់អតិថិជន ......................................................................................................៥៨
៣.៥.៣.៤. ការផ្តល់ប្រឹក្សាវិនិយោគ ......................................................................................................៥៩
៣.៥.៣.៥ .ការអនុវត្តការជួញដូរមូលបត្រ......................................................................................................៥៩
៣.៥.៣.៦. កាតព្វកិច្ចដែលត្រូវហាមឃាត់ក្នុងការប្រកបអាជីវកម្ម......................................................................................................៦០
៣.៥.៣.៧. ការផ្សាយពាណិជ្ជកម្ម...................................................................................................... ៦២

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

១. សេចក្តីសន្និដ្ឋាន ......................................................................................................៦៥
២. អនុសាសន៍ ......................................................................................................៦៦
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

## បញ្ជីអក្សរកាត់

IPO ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

គ.ម.ក. គណៈកម្មការមូលបត្រកម្ពុជា

T + 2 ពីថ្ងៃបន្ទាប់ពីការជួញដូរ

## ពាក្យបច្ចេកទេសមូលបត្រ

- **កិច្ចសន្យាធានាទិញ** គឺជាកិច្ចព្រមព្រៀងដែលធ្វើឡើងដើម្បីធានាទិញមូលបត្រទាំងអស់ ឬមួយផ្នែក ដែលលក់ជូនវិនិយោគិនសាធារណៈមិនអស់តាមនីតិវិធីនៅកាលបរិច្ឆេទផុតកំណត់នៃសំណើលក់ជាសាធារណៈ។ កិច្ចសន្យាធានាទិញនេះរាប់បញ្ចូលទាំងកិច្ចសន្យាធានាទិញបន្តដែលធ្វើឡើងដោយបុគ្គលដែលច្បាប់អនុញ្ញាត។
- **ក្រុមហ៊ុនមូលបត្រ** (Securities Firm) សំដៅដល់ក្រុមហ៊ុន ឬក្រុមហ៊ុនសហាកកម្មសិទ្ធដែលទទួលបានអាជ្ញាបណ្ណដើម្បីធ្វើអាជីវកម្មមូលបត្រ ដោយស្របទៅតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។
- **ក្រុមហ៊ុនមានសិទ្ធិបោះឆ្នោត** (Voting Share) សំដៅដល់ភាគហ៊ុន របស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតដែលផ្តល់សិទ្ធិបោះឆ្នោតទៅឱ្យអ្នកកាន់កាប់ភាគហ៊ុនដែលបានចុះបញ្ជី។
- **ក្រុមហ៊ុនទទួលខុសត្រូវមានកម្រិត** (Public Limited Company) សំដៅដល់ក្រុមហ៊ុនដែលបង្កើតឡើង និងចុះបញ្ជីតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ក្នុងគោលបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- **ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា** (CSX) ហៅកាត់ផ.ម.ក. គឺជាប្រតិបត្តិករក្នុងវិស័យមូលបត្រនៅកម្ពុជា ដែលទទួលបានការអនុញ្ញាតពី គ.ម.ក ដើម្បីធ្វើអាជីវកម្មលើការចុះបញ្ជីក្រុមហ៊ុន ផ្តល់ប្រព័ន្ធជួញដូរមូលបត្រ រក្សាទុកមូលបត្រ ព្រមទាំងជាត់ទាត់និងទូទាត់មូលបត្រ។ ផ.ម.ក. គឺជាក្រុមហ៊ុនរួមទុនរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនមូលបត្រកូរ៉េ។
- **ការធ្វើប៊ុកបៀលឌីង** ជាដំណាក់ស្ទាបស្ទង់ថ្លៃដែលធ្វើឡើងរវាងក្រុមហ៊ុនបោះផ្សាយ និងវិនិយោគដែលស្ថិតក្រោមជំនួយរបស់ក្រុមហ៊ុនធានាទិញមូលបត្រ។ គោលបំណងសំខាន់នៃការធ្វើប៊ុកបៀលឌីង គឺដើម្បីធានាបាននូវថ្លៃមួយដែលមានតម្លាភាព និងដើម្បីធានាថាថ្លៃមូលបត្រកម្មសិទ្ធិបានឆ្លុះបញ្ចាំងពីតម្រូវការទីផ្សារ។ ក្នុងនោះដែរ ចំនួនមូលបត្រដែលត្រូវធ្វើប៊ុកបៀល-

ឌីងមានចំនួន ៧០%នៃមូលបត្រកម្មសិទ្ធិសរុប និង ៣០%ទៀតទុកសម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យ ក្នុងដំណាក់កាលប៊ុកបៀលឌីងដើម្បីធ្វើបរិវិសកម្ម។

- **គណៈកម្មការមូលបត្រកម្ពុជា** (SECC) ហៅកាត់ថាគ.ម.ក. គឺនិយ័តករនៃវិស័យមូលបត្រកម្ពុជាដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្ដាប្រតិបត្តិករមូលបត្រក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ និងអ្នកចូលរួមទីផ្សារៗទៀតសំដៅការការពារវិនិយោគិនមូលបត្រ ព្រមទាំងធានាឱ្យមាននូវការជួញដូរមូលបត្រប្រកបដោយចីរភាពប្រសិទ្ធភាព តម្លាភាព យុត្តិធម៌ និង សណ្ដាប់ធ្នាប់។
- **គណនីជួញដូរ** សំដៅដល់លើគណនីសម្រាប់ជួញដូរភាគហ៊ុន ហើយអ្នកអាចបើកគណនីនេះបានទៅតាមក្រុមហ៊ុនមូលបត្រដែលជាសមាជិករបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។
- **គណនីទូទាត់សាច់ប្រាក់** គឺជាគណនីរបស់ធនាគារមួយ ដែលវិនិយោគិនគ្រប់រូបត្រូវបើកសម្រាប់ធ្វើការទូទាត់នៅពេលទិញ លក់ មូលបត្រ។ គណនីនេះអាចបើកបានតែនៅភ្នាក់ងារពាក់ព័ន្ធដែលទទួលបានការអនុញ្ញាតពីគ.ម.ក. តែប៉ុណ្ណោះ។
- **បរិវិសកម្ម** (Subscription) ការទិញមូលបត្រនៅលើផ្សារដំបូង ឬការទិញមូលបត្រពីក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- **មូលបត្របំណុល** (Debt Securities) សំដៅដល់ឧបករណ៍ហិរញ្ញវត្ថុដែលបោះផ្សាយដោយបុគ្គលណាមួយដោយបញ្ជាក់ ឬទទួលស្គាល់នូវបំណុលរបស់ខ្លួនចំពោះបុគ្គលមួយទៀតដែលបានឱ្យប្រាក់ ឬដាក់ជាប្រាក់បញ្ញើជាមួយបុគ្គលនោះ ឬបុគ្គលនោះជំពាក់តាមវិធីផ្សេងពីនេះ ហើយទោះបីជាមាន ឬគ្មានទ្រព្យដាក់ធានាក្ដី។
- **លេខអត្តសញ្ញាណវិនិយោគិន** (Investor ID) គឺជាលេខសម្គាល់ដែលគណៈកម្មការមូល-បត្រកម្ពុជា ផ្ដល់ជូនទៅដល់វិនិយោគិន ដើម្បីជាការសម្គាល់អត្តសញ្ញាណរបស់វិនិយោគិននីមួយៗ។
- **ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ** (Derivative Instrument) សំដៅដល់កិច្ចសន្យាដែលផ្ដល់សិទ្ធិ ឬកាតព្វកិច្ចនៃមូលបត្រដើមទៅឱ្យបុគ្គលណាមួយ ដោយរាប់បញ្ចូលទាំងសិទ្ធិ ឬកាតព្វកិច្ចទិញ លក់ ឬដាក់ពាក្យសុំទិញមូលបត្រក្នុងពេលអនាគត ដោយមិនគិតថាបុគ្គលនេះមានបំណងប្រើសិទ្ធិ ឬមិនប្រើប្រាស់នេះក៏ដោយ។

# បញ្ជីតារាង

តារាងទី១៖ ភាពខុសគ្នារវាងសញ្ញាបណ្ណ និងភាគហ៊ុន ..........១១

# បញ្ជីរូប

រូបភាពទី១៖ គំនូសតាងនីតិវិធីនៃការចុះបញ្ជី ..........១០
រូបភាពទី២៖ គំនូសតាងយន្តការទីផ្សារដំបូង ..........១៥
រូបភាពទី៣៖ គំនូសតាងយន្តការទីផ្សារបន្ទាប់ ..........១៦
រូបភាពទី៤៖ រចនាសម្ព័ន្ធគ្រប់គ្រងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ..........១៩
រូបភាពទី៥៖ រូបតំណាងរបស់គ.ម.ក. ..........៣៤
រូបភាពទី៦៖ រូបត្រារបស់គ.ម.ក. ..........៣៦
រូបភាពទី៧៖ រចនាសម្ព័ន្ធចាត់តាំងរបស់គ.ម.ក. ..........៤៧

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ដំណើរការទីផ្សារមូលបត្របាននឹងកំពុងធ្វើដំណើរឆ្ពោះទៅមុខជាលំដាប់ ស្របពេលជាមួយ និង ក្រុមហ៊ុនមួយចំនួនក៏បានចូលរួមក្នុងទីផ្សារនេះ ចំណែកឯក្រុមហ៊ុនមួយចំនួនទៀត កំពុងតែត្រៀមខ្លួនដើម្បីចូលក្នុងទីផ្សារមូលបត្រ។ ចំពោះតួអង្គដែលសំខាន់នៅក្នុងទីផ្សារមួយនេះគឺ គណៈកម្ម-ការមូលបត្រ (Securities and Exchange Commission of Cambodia, SECC) យ៉ាងនេះហើយបានជាកើតមានក្រុមហ៊ុនមូលបត្រ ដែលបានជួយបម្រើមិនថាតែទៅលើសេវាកម្ម តែដោយសារតែមានការភ័យខ្លាចនៃការកេងប្រវ័ញ្ច និងយកផលចំណេញ ដែលជាហេតុធ្វើអោយប៉ះពាល់ដល់ផលចំណេញបុគ្គល ទើបបានជា គ.ម.ក (SECC) បានបង្កើតលក្ខខណ្ឌឡើង ដើម្បីចៀសវាងពីបញ្ហាទាំងនេះ។

ទោះបីជាយ៉ាងណាការជួញដូរមូលបត្រ បានកំពុងតែប្រតិបត្តិការ នៅលើទីផ្សារយ៉ាងសស្រាក់សស្រាំ និងមានការចូលរួមពីសំណាក់អ្នកវិនិយោគកាន់តែច្រើន បើប្រៀបធៀបទៅនឹងឆ្នាំមុនៗ យើងឃើញមានការរីកចម្រើន និងមានការយល់ដឹងច្រើនជាងមុនពីវិស័យមួយនេះ។ ដោយសារតែការខិតខំប្រឹងប្រែងតាមរយៈការធ្វើសន្និសិទ្ធ ការសិក្ខាសិលា ការចែករំលែកផ្សេងៗ និងការផ្សព្វផ្សាយតាមប្រព័ន្ធបណ្តាញសង្គម និងគេហទំព័រផ្សេងៗ របស់ គ.ម.ក និង ផ.ម.ក ដែលបានចូលរួមធ្វើឱ្យវិស័យនេះកាន់តែមានការចាប់អារម្មណ៍ពីសំណាក់សាធារណជន។ ហេតុនេះហើយបានមានក្រុមហ៊ុនមូលបត្រដែលជួយសម្រួលដល់អ្នកជួញដូរទាំងឡាយ។ ហើយដើម្បីឱ្យការជួញដូរប្រព្រឹត្តទៅត្រឹមត្រូវតាមច្បាប់ និងមានប្រសិទ្ធភាព ទើបគ.ម.ក បានបង្កើតលក្ខខណ្ឌ និងច្បាប់ផ្សេងៗដើម្បីឱមានតម្លាភាព និងប្រសិទ្ធភាពក្នុងការជួញដូរ និងប្រកបដោយក្រមសីលធម៌ដើម្បីក្លាយជាក្រុមហ៊ុនមូលបត្រមួយដែលមានការទុកចិត្ត និងត្រឹមត្រូវតាមច្បាប់។ ដូច្នេះហើយបានជា គ.ម.ក ត្រូវតែត្រួតពិនិត្យទៅលើក្រុមហ៊ុនមូលបត្រ ដើម្បីដឹងថាក្រុមហ៊ុនទាំងនោះមិនមានការកិបគេង និងមិនទម្លាយរឿងពីក្រុមហ៊ុនមួយទៅក្រុមហ៊ុនមួយទៀត ឬពីបុគ្គលមួយទៅបុគ្គលមួយទៀត និងក៏ជាកត្តាមួយដែលផ្តល់ការទុកចិត្ត និងទាក់ទាញវិនិយោគបន្ថែម។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាទូទៅក្រុមហ៊ុនដែលជាក្រុមហ៊ុនមូលបត្រ សុទ្ធតែជាក្រុមហ៊ុនដែលទទួលបានអជ្ញាបណ្ណត្រឹមត្រូវ ដោយគោរពទៅតាមលក្ខខណ្ឌ យន្តការ និងនីតិវិធីរបស់ផ្លូវច្បាប់ដែលបានកំណត់។ ក្រុមហ៊ុនមូលបត្រមានបួន គឺអ្នកធានាទិញមូលបត្រ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ និងអ្នកប្រឹក្សាវិនិយោគ។ ដោយឡែកក្រុមហ៊ុនទាំងនេះក៏បានផ្តល់ភាពងាយស្រួល និងសេវាកម្ម

ដល់វិនិយោគិន ដូច្នេះថាតើដើម្បីត្រួតពិនិត្យបាន តើគណៈកម្មការមូលបត្រ ត្រូវត្រួតពិនិត្យអ្វីខ្លះទៅលើក្រុមហ៊ុនមូលបត្រ? ដើម្បីទទួលបានអាជ្ញាបណ្ណទៀតសោតថាតើក្រុមហ៊ុនទាំងនោះត្រូវត្រៀម និងគោរពតាមលក្ខខណ្ឌអ្វីខ្លះ? ហើយអ្វីដែលជាបញ្ហា បន្ទាប់ពីការទទួលបានអាជ្ញាបណ្ណ និងមានសិទ្ធិពេញលេញជាក្រុមហ៊ុនមូលបត្រ តើក្រុមហ៊ុនមូលបត្រមានតួនាទី និងកាតព្វកិច្ចអ្វីខ្លះ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនេះធ្វើឡើង គឺដើម្បីសម្រេចនូវគោលបំណងមួយចំនួនដូចខាងក្រោម៖

- សិក្សាពីប្រវត្តិ និងស្ថានភាពទូទៅរបស់ក្រុមហ៊ុនមូលបត្រ
- ស្វែងយល់ពីដំណើរការរបស់ក្រុមហ៊ុនមូលបត្រ
- ស្វែងយល់ពីការត្រួតពិនិត្យរបស់ គ.ម.ក ទៅលើក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនមូលបត្រត្រូវធ្វើអ្វីខ្លះដើម្បីអាចទទួលបានសិទ្ធិពេញលេញ
- ស្វែងយល់ពីលក្ខខណ្ឌតម្រូវមុនទទួលអាជ្ញាបណ្ណ និងក្រោយទទួលអាជ្ញាបណ្ណដើម្បីក្លាយជាក្រុមហ៊ុនមូលបត្រ
- ស្វែងយល់ពីតួនាទី និងកាតព្វកិច្ចដើម្បីក្លាយជាក្រុមហ៊ុនមូលបត្រ
- ស្វែងយល់ពីវិធីសាស្ត្រ នីតិវិធី និងក្រមសីលធម៌ពេលក្លាយជាក្រុមហ៊ុនមូលបត្រ
- ស្វែងយល់អំពីអត្ថប្រយោជន៍នៃក្រុមហ៊ុនមូលបត្រ

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ដោយសារទីផ្សារមូលបត្រកំពុងតែមានការរីកចម្រើន និងដំណើរការទៅមុខសន្សឹមៗ ទើបការសិក្សាស្រាវជ្រាវនេះទៅផ្តោតទៅលើ ការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ ដែលជាសេវាកម្មមួយដែលមានសារៈសំខាន់ និងមិនអាចខ្វះបាន ហើយផ្តោតសំខាន់តែទៅលើការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ និងនីតិវិធី និងយន្តការ ដើម្បីទទួលបានអាជ្ញាបណ្ណ និងក្រោយពេលទទួលបានតែប៉ុណ្ណោះ ក្នុងឆ្នាំ២០១៦ - ២០១៧។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទមួយនេះនឹងផ្តល់អត្ថប្រយោជន៍ដូចខាងក្រោម៖

- ផ្តល់ឱ្យយើងខ្ញុំអនុវត្តជាក់ស្តែងដោយផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តី
- ជួយផ្តល់ជាទស្សនៈទានគំនិតដល់វិនិយោគិន ក៏ដូចជាសាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍លើវិស័យមួយនេះ

- ផ្តល់ពីលក្ខខណ្ឌតម្រូវ និងនីតិវិធីក្នុងការត្រៀមខ្លួនមុនពេលទទួលអាជ្ញាបណ្ណ និងពេលដែលទទួលអាជ្ញាបណ្ណ
- ផ្តល់ជាព័ត៌មានសម្រាប់ក្រុមហ៊ុនបោះផ្សាយដទៃទៀតដែលកំពុងនឹងត្រៀមខ្លួន ឬចង់ក្លាយជាសមាជិក និងជាដៃគូរក្នុងការវិនិយោគ
- ផ្តល់ជាព័ត៌មានអំពីលក្ខខណ្ឌ និងនីតិវិធីរបស់ គ.ម.ក ក្នុងការត្រួតពិនិត្យក្រុមហ៊ុនមូល-បត្រ
- ជួយផ្សព្វផ្សាយ និងពង្រីកចំណេះដឹងពីក្រុមហ៊ុនមូលបត្រ
- រក្សាទុកជាឯកសារសំរាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ដើម្បីមានភាពងាយស្រួលដល់ការស្រាវជ្រាវ និងអ្នកដែលមានបំណាងចង់ដឹងពីទីផ្សារនេះ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីទទួលនូវចំណេះដឹងដែលទាក់ទងនឹងវិស័យមូលបត្រ និងដឹងពីការត្រួតពិនិត្យលើក្រុមហ៊ុនមូលបត្រ យើងខ្ញុំបានប្រើវិធីសាស្ត្រពីរយ៉ាងក្នុងការប្រមូលទិន្នន័យ និងព័ត៌មានដូចខាងក្រោម៖

**ទិន្នន័យចម្បង** ជាទិន្នន័យ និង ព័ត៌មានដែលប្រមូលបានមកពី៖

- សាកសួរដោយផ្ទាល់ជាមួយអ្នកជំនាញ និងផ្នែកដែលពាក់ព័ន្ធ
- ការអង្កេតដោយផ្ទាល់

**ទិន្នន័យបន្ទាប់បន្សំ** ជាទិន្នន័យ និង ព័ត៌មានដែលប្រមូលបានមកពី៖

- ឯកសារសិក្សានៅសាកលវិទ្យាល័យ
- ឯកសារស្រាវជ្រាវ សារណា និងរបាយការណ៍របស់សិស្សច្បង
- ឯកសារដែលបានមកពីការចូលរួម នៅក្នុងសិក្ខាសាលានានាដែលទាក់ទងនឹងវិស័យមូលបត្រ
- ឯកសាររបាយការណ៍ ដែលបានចងក្រង និងចេញផ្សាយដោយ គ.ម.ក
- បទប្បញ្ញាត្តិ ច្បាប់ អនុក្រឹត ប្រកាស ដែលដកស្រង់ចេញពីគេហទំព័ររបស់ គ.ម.ក

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រវជ្រាវនេះត្រូវបានរៀបចំឡើង និងចងក្រងទៅតាមរចនាសម្ព័ន្ធដូចខាងក្រោម៖

សេចក្តីផ្តើម ៖ មានដូចជា លំនាំបញ្ហា ចំណោទបញ្ហា ទំហំ និងដែនកំណត់ គោលបំណង សារៈសំខាន់វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី១ ៖ រំលឹកទ្រឹស្តីទីផ្សារមូលបត្រ គឺធ្វើការស្រាវជ្រាវទៅលើទីផ្សារមូលបត្រ

ជំពូកទី២ ៖ស្ថានភាពទូទៅរបស់គណៈកម្មការមូលបត្រកម្ពុជា គឺធ្វើការស្រាវជ្រាវលើប្រវត្តិរបស់គណៈកម្មការមូលបត្រ ស្ថានភាព សមាសភាព និងកាតព្វកិច្ច មុខងារ តួនាទី។

ជំពូកទី៣ ៖ការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ គឺធ្វើការសិក្សាពីក្រុមហ៊ុនមូលបត្រ របៀបនៃការទទួលបានអាជ្ញាបណ្ណ ការត្រួតពិនិត្យ លក្ខខណ្ឌ និងក្រមសីលធម៌របស់ក្រុមហ៊ុនមូលបត្រ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍ គឺធ្វើការសរុបសេចក្តីទៅលើរបាយការណ៍កម្មសិក្សា និងផ្តល់ជាគំនិតយោបល់ដែលអាចឱ្យក្រុមហ៊ុនកាន់តែមានការអភិវឌ្ឍបន្ថែម។

# ជំពូកទី១
# ទីផ្សារមូលបត្រនៅកម្ពុជា

## ១.១ ទីផ្សារមូលបត្រ

បច្ចុប្បន្នសេដ្ឋកិច្ច ក្នុងប្រទេសកម្ពុជាយើងកំពុងតែអភិវឌ្ឍទៅមុខ ដោយសារតែមានវត្តមានទីផ្សារភាគហ៊ុន ឬអាចហៅម៉្យាងទៀតបានថា ជាទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងវិស័យសេដ្ឋកិច្ច ជាមួយនឹងមុខងារជាអន្តរការីហិរញ្ញវត្ថុ ដើម្បីផ្តល់ភាពងាយស្រួលនូវតម្រូវការរបស់អ្នកដែលមានសាច់ប្រាក់លើស និងអ្នកដែលខ្វះសាច់ប្រាក់។ អ្នកដែលមានមូលធនលើស ពួកគាត់ចង់វិនិយោគមូលធនរបស់គាត់ នៅកន្លែងដែលមានសុវត្ថិភាព ហានិភ័យទាបទូទាត់ជាសាច់ប្រាក់បានឆាប់រហ័ស ចំណេញខ្ពស់ ដើម្បីការពារតម្លៃជាក់ស្តែងនៃបរិមាណប្រាក់វិនិយោគ ចំពោះអ្នកសុំខ្ចី គឺចង់បានបរិមាណកម្ចីជាមួយនឹងបរិមាណខុសៗគ្នា ដើម្បីបំពេញប្រតិបត្តិការនូវមូលធនរយៈពេលខ្លី មធ្យម និងវែង។ កត្តាខាងលើនេះហើយទើបជំរុញឱ្យកើតមានទីផ្សារមូលបត្រនេះឡើង។

### ១.១.១. និយមន័យ

ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ ផ្ទេរ ឬស្នីការ ទិញ-លក់មូលបត្រ។ ទីផ្សារនេះ យើងចាត់ចូលក្នុងប្រភេទទីផ្សារហិរញ្ញវត្ថុ។

### ១.១.២. ប្រវត្តិនៃទីផ្សារមូលបត្រនៅកម្ពុជា

[1]ទីផ្សារមូលបត្រកម្ពុជា ត្រូវបានផ្តួចផ្តើមគំនិតឡើងដោយសម្តេច ហ៊ុនសែន ជានាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។ នៅឆ្នាំ ១៩៩៥ មានគម្រោងបង្កើតទីផ្សារមូលបត្រនៅកម្ពុជា ប៉ុន្តែជាអកុសលគំនិតផ្តួចផ្តើមនេះក៏ត្រូវបានកាត់ផ្តាច់ ដោយសារតែប្រព័ន្ធធនាគារមិនទាន់មានភាពរឹងមាំរដ្ឋាភិបាលសម្រេចចិត្តពន្យាការបង្កើតទីផ្សារនេះ។ រហូតដល់ឆ្នាំ ២០០១ រដ្ឋាភិបាលបានបង្កើតទស្សនៈវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០១-២០១០ បន្ទាប់មកត្រូវបានធ្វើបច្ចុប្បន្នកម្មទៅជា យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០០៦-២០១៥ នៅក្នុងឆ្នាំ

[1] សៀវភៅរបស់ សាស្ត្រាចារ្យ អ៊ឹង អ៊ូ ឆ្នាំ ២០១៦ ២០១៧ "ទីផ្សារមូលបត្រកម្ពុជា"

២០០៦។ យុទ្ធសាស្ត្រនេះ គឺមានគោលបំណងដើម្បីអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែរឹងមាំ និងដំណើរការល្អតាមរយៈការប្រមូលឱ្យមានការកៀងគរ និងបែងចែកធនធានហិរញ្ញវត្ថុនៅក្នុងសេដ្ឋកិច្ចនោះប្រកបដោយប្រសិទ្ធិភាព។ ចាប់ពីឆ្នាំ ២០០៧ មកសង្កេតឃើញថា ច្បាប់ អនុក្រឹត្យ ប្រកាស និងសេចក្ដីសម្រេចផ្សេងៗមួយចំនួនដែលព័ន្ធនឹងទីផ្សារមូលបត្រត្រូវបានបង្កើតឡើងជាបន្តបន្ទាប់។ នៅថ្ងៃទី ១៩ តុលា ឆ្នាំ ២០០៧ មានចេញច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន មួយទៀត នៅថ្ងៃ ០៦ កញ្ញា ២០០៧ គម្រោងបង្កើតទីផ្សារមូលបត្រនៅកម្ពុជា បានប្រកាសដាក់ឱ្យដំណើការជាផ្លូវការដោយនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ។ ចូលដល់ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៨ ចេញអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ។

## ១.២. ប្រភេទនៃទីផ្សារមូលបត្រ

### ១.២.១.ចំណាត់ថ្នាក់នៃប្រភេទទីផ្សារហិរញ្ញវត្ថុ

[2]ទីផ្សារហិរញ្ញវត្ថុ មានពីរប្រភេទដែលប្រភេទទី ១ គឺទីផ្សាររូបិយវត្ថុ ដែលសំដៅដល់ទីផ្សារដែលធ្វើការជួញដូរឧបករណ៍ហិរញ្ញវត្ថុរយៈពេលខ្លី ដូចជា Commercial Paper, Repurchase Agreement, Treasury Note និង ឧបករណ៍ដ៏ទៃទៀត និងប្រភេទទី ២ គឺទីផ្សារមូលធន ឬទីផ្សារមូលបត្រ ធ្វើការជួញដូរនូវឧបករណ៍ហិរញ្ញវត្ថុរយៈមធ្យម និងវែង ដូចជាសញ្ញាបណ្ណ និងមូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន។

### ១.២.២.ប្រភេទនៃមូលបត្រ

ឧបករណ៍ហិរញ្ញវត្ថុ សំដៅដល់ឧបករណ៍ដែលក្រុមហ៊ុនបោះផ្សាយអាចបោះផ្សាយក្នុងគោលបំណងស្វែងរកមូលធន តាមរយៈការបោះភាគហ៊ុន ឬបណ្ណបំណុល តែឧបករណ៍និស្សន្ទដូចជា Future និងOption ក្នុងគោលបំណងមិនស្វែងរកដើមទុនឡើយ តែដើម្បីបញ្ចៀសនូវហានិភ័យនៃការឡើងចុះនៃថ្លៃ។

[2] ឈាង ហ៊ុយ(២០១៤-២០១៥) "មូលដ្ឋានគ្រឹះវិនិយោគ" បោះពុម្ពលើកទី៣

[3]រចនាសម្ព័ន្ធនៃប្រភេទមូលបត្រ មានដូចខាងក្រោម :




ភាពខុសគ្នារវាងការទិញភាគហ៊ុនធម្មតា និងភាគហ៊ុនបុរិមា

| | Basic concept | Voting rights | Dividends |
|---|---|---|---|
| Common Stock | Standardized | Voting rights | Dividend after preferred stocks |
| Preferred Stock | Rank above common shares for certain specific rights | In principle, no voting rights | Preference for dividend over common stocks |
| | | If no dividend, then voting rights | |

### ១.២.៣.អ្នកចូលរួមក្នុងទីផ្សារ

ទីផ្សារមូលបត្រ អាចដំណើរការបាន លុះត្រាតែមានតួអង្គសំខាន់ៗចូលរួមដូចជា៖ ក្រុមហ៊ុនបោះផ្សាយ (ក្រុមហ៊ុនឯកជន រាជរដ្ឋាភិបាល និងក្រុមហ៊ុនបរទេស) ក្រុមហ៊ុនមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ និងក្រុម

[3] អ៊ឹង អ៊ូ(២០១៦-២០១៧) "ទីផ្សារមូលបត្រកម្ពុជា"

ប្រឹក្សាវិនិយោគ) វិនិយោគិន (អាចជាធនាគារពាណិជ្ជ ធនាគារឯកទេស ក្រុមហ៊ុនមីក្រូហ្វាយនែន ក្រុមហ៊ុនសាជីវកម្ម រាជរដ្ឋាភិបាល ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងឯកត្តជន) និង គណៈកម្មការមូលបត្រកម្ពុជា (និយ័តករមូលបត្រ)។

### ១.២.៤.ទីផ្សារភាគហ៊ុន

[4]ទីកន្លែង ផ្តល់នូវមុខងារដូចខាងក្រោម :

- ធ្វើការអនុវត្តវិធានទីផ្សារចំពោះសមាជិករបស់ខ្លួន
- ផ្តល់កន្លែងសម្រាប់ដំណើរការជួញដូរមូលបត្រ
- អនុវត្តវិធានសម្រាប់ក្រុមហ៊ុនចុះបញ្ជីលក់
- និងដាក់ទណ្ឌកម្មចំពោះសមាជិក និងអ្នកចូលរួមដែលមិនគោរពតាមវិធាននៃទីផ្សារ។

<u>**ផលប្រយោជន៍នៃទីផ្សារភាគហ៊ុន**</u>

- កន្លែងដែលក្រុមហ៊ុនអាចធ្វើការបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីរកមូលធនរយៈពេលវែង
- ជាកន្លែងដែលមូលបត្រត្រូវបានលក់ជាលើកដំបូង
- ជាកន្លែងដែលទទួលបានហិរញ្ញប្បទានដោយផ្ទាល់ពីវិនិយោគិនមូលបត្រ
- ជាកន្លែងជម្រុញនូវប្រភពមូលធនទាំងធំ និងតូចៗទៅក្នុងដំណើរការសេដ្ឋកិច្ច
- ជាកន្លែងដែលអាចផ្តល់លទ្ធិភាពឱ្យក្រុមហ៊ុនឯកជនធម្មតា ទៅជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

#### ១.២.៤.១ ទីផ្សារដំបូង

សំដៅដល់ការបោះផ្សាយលក់មូលបត្រជាលើកដំបូង ទៅឱ្យអ្នកទិញដំបូងគេបង្អស់ នៅកាលបរិច្ឆេទកំណត់ណាមួយ។ អ្នកវិនិយោគអាចធ្វើការទិញភាគហ៊ុន ដែលបោះលក់លើកដំបូងដោយក្រុមហ៊ុន បោះផ្សាយតាមរយៈការចូលរួមធ្វើប៊ីុកប៉ៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រ។

#### ១.២.៤.២ ទីផ្សារបន្ទាប់

សំដៅដល់ការទិញ-លក់មូលបត្ររវាងអ្នកទិញ-លក់ទូទៅ នៅរៀងរាល់កាលបរិច្ឆេទ នៃការជួញដូរនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ទីផ្សារបន្ទាប់) ចាំបាច់ត្រូវតែមានដំណើរការប្រកបដោយតម្លាភាព សន្ទនីយភាព និងប្រសិទ្ធិភាព គឺមានន័យថារាល់

[4] Securities Book in Cambodia របស់គ.ម.ក. នៅក្នុងជំពូកទី១ និយាយពីទិដ្ឋភាពទូទៅនៃទីផ្សារមូលបត្រ ទំព័រទី ៥

ព័ត៌មានត្រូវតែទាន់ពេលវេលា និងត្រឹមត្រូវ ពេលបង្ហាញទៅដល់សាធារណជនទូទៅ និងផ្តល់លទ្ធិភាពឱ្យអ្នកទិញ និងអ្នកលក់ ងាយស្រួលក្នុងការទិញ-លក់មូលបត្រ ។

**<u>នីតិវិធីនៃការជួញដូរមូលបត្រ</u>**

១. អតិថិជន ត្រូវបើកគណនីជួញដូរនៅក្នុងក្រុមហ៊ុនឈ្នួញជើងសាមូលបត្រ

២. ដាក់ការបញ្ជាទិញ-លក់ : អតិថិជន ដាក់ការបញ្ជាទិញ-លក់ទៅក្នុងក្រុមហ៊ុនឈ្នួញជើងសាមូលបត្រតាមរយៈ Online ឬ Offline ហើយក្រុមហ៊ុន បញ្ជូនការបញ្ជាទិញ-លក់នេះទៅកាន់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

៣. ក្រុមហ៊ុនផ្សារមូលបត្រ ចាប់ផ្តើមធ្វើការផ្គូរផ្គងនូវការទិញ-លក់ ដោយគោរពតាមគោលការណ៍អធិភាព នៃការជួញដូរ (Trading Priority)

៤. ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា បញ្ជូនដំណឹងមកក្រុមហ៊ុនឈ្នួញជើងសាមូលបត្រ ពីលទ្ធផលនៃការជួញដូរបានសម្រេច ហើយក្រុមហ៊ុនឈ្នួញជើងសាមូលបត្រ បញ្ជូនដំណឹងបន្តមកកាន់អតិថិជនរបស់ខ្លួន

៥. ការទូទាត់ : ក្រុមហ៊ុនឈ្នួញជើងសាខាងអ្នកលក់ ត្រូវទូទាត់មូលបត្រឱ្យក្រុមហ៊ុនមូលបត្រខាងអ្នកទិញ តាមរយៈប្រតិបត្តិកររក្សាទុកមូលបត្រនៃក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រីឯក្រុមហ៊ុនមូលបត្រខាងអ្នកទិញ ត្រូវ
ប្រគល់សាច់ប្រាក់មកឱ្យក្រុមហ៊ុនមូលបត្រខាងអ្នកលក់ តាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដោយមានការត្រួតពិនិត្យពីប្រិតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់មូលបត្រ។

**១.២.៤.៣ ផាត់ទាត់ និងទូទាត់ (កាត់កងរវាងអ្នកទិញ និងអ្នកលក់មូលបត្រ)**

- <u>ផាត់ទាត់</u> សំដៅដល់ដំណើរការរបស់ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ ត្រួតពិនិត្យមើលកាតព្វកិច្ចខាងអ្នកលក់ ចំពោះខាងអ្នកទិញ និងកាតព្វកិច្ចខាងអ្នកទិញចំពោះខាងអ្នកលក់ដើម្បីធានានូវការទូទាត់នៅថ្ងៃ T+ ... ដោយដោយធ្វើបន្សុទ្ធ មូលបត្រ និងសាច់ប្រាក់រវាងអ្នកទិញនិងអ្នកលក់។

ឧទាហរណ៍៖

អ្នកលក់មូលបត្រ = (total sale- total purchase) money = ??

អ្នកទិញមូលបត្រ = ( total sale-total purchase) securities = ??

- ទូទាត់ សំដៅដល់ដំណើរការបញ្ចប់នៃការកិច្ចសន្យាជួញដូរ ដោយអ្នកលក់មូលបត្រ បំពេញនូវកាតព្វកិច្ចក្នុងការផ្ទេរនូវម្ចាស់កម្មសិទ្ធិ នៃមូលបត្រដែលបានលក់ទៅឱ្យអ្នកទិញ ហើយអ្នកទិញ ក៏បំពេញកាតព្វកិច្ចក្នុងការផ្ទេរនូវសាច់ប្រាក់នៃមូលបត្រដែលបានទិញទៅឱ្យអ្នកលក់។

**១.២.៤.៤ និតិវិធីនៃការចុះបញ្ជីផ្លូវការ**




**១.២.៤.៥ ឯកសារផ្តល់ព័ត៌មានសាជីវកម្ម**

សំដៅដល់ឯកសារដែលមានប្រភេទដូចខាងក្រោម ៖

- ឯកសារផ្តល់ព័ត៌មានទាន់ពេល (Inquired Disclosure) : ឯកសារផ្តល់ព័ត៌មានទាន់ហេតុការណ៍ ដូចជា ពាក្យអាចាមអារាម ឬព័ត៌មានដែលនាំឱ្យយល់ខុស។

- ឯកសារផ្តល់ព័ត៌មានសមាយិក (Periodic Disclosure) : ឯកសារផ្តល់ព័ត៌មានស្តីពីព័ត៌មាន ដូចជារបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ប្រចាំត្រីមាស។

- ឯកសារផ្តល់ព័ត៌មានរសើប (Hahoc Disclosure) : ឯកសារផ្តល់ព័ត៌មានស្តីពីព័ត៌មានរសើប ដូចជាការបង្កើននូវមូលធន ការបោះផ្សាយនូវឧបករណ៍មូលបត្រថ្មី និងការផ្លាស់ប្តូរនូវការគ្រប់គ្រងជាដើម។

- ឯកសារផ្តល់ព័ត៌មាន ដែលបង្ហាញពីផែនការគ្រប់គ្រងគម្រោង ផលជោគជ័យនៃអាជីវកម្ម។

- ឯកសារផ្តល់ព័ត៌មាន ត្រូវដែលមានភាពងាយស្រួលក្នុងការទទួលបាន និងត្រឹមត្រូវដល់វិនិយោគិនទូទៅ សម្រាប់ជម្រាបជាព័ត៌មាន ដើម្បីធ្វើការសម្រេចចិត្តវិនិយោគ ឬមិនវិនិយោគ។

### ១.២.៥ ទីផ្សារសញ្ញាបណ្ណ

#### ១.២.៥.១ និយមន័យនៃសញ្ញាបណ្ណ

[5]សំដៅដល់ការព្រមព្រៀងដែលអ្នកលក់សញ្ញាបណ្ណ (ក្រុមហ៊ុនបោះផ្សាយ) សន្យាធានាអ្នកទិញសញ្ញាបណ្ណនូវប្រាក់ដើម និងការប្រាក់តាមកាលបរិច្ឆេទកំណត់ជាក់លាក់ណាមួយ។

#### ១.២.៥.២ ភាពខុសគ្នារវាងសញ្ញាបណ្ណ និងភាគហ៊ុន

| លក្ខណៈពិសេស | ភាគហ៊ុន/មូលបត្រកម្មសិទ្ធិ | សញ្ញាបណ្ណ/បណ្ណបំណុល |
|---|---|---|
| ➢ ប្រាក់ចំណេញ | ➢ ភាគលាភ | ➢ ការប្រាក់ |
| ➢ ការយកពន្ធដារ | ➢ យកពន្ធជាឯកត្តជនមិនមែនជាចំណាយក្រុមហ៊ុន | ➢ យកពន្ធជាឯកត្តជនជាចំណាយរបស់ក្រុមហ៊ុន |
| ➢ ការគ្រប់គ្រង | ➢ មានសិទ្ធិបោះឆ្នោត | ➢ មានចែងក្នុងកិច្ចព្រមព្រៀងឬទេ |
| ➢ មិនអាចទូទាត់ | ➢ មិនមែនក្ស័យធន | ➢ អាចឈានទៅរកភាពក្ស័យធន |

#### ១.២.៥.៣ អ្នកចូលរួមក្នុងទីផ្សារសញ្ញាបណ្ណ

ទីផ្សារសញ្ញាបណ្ណ អាចដំណើរការទៅបាន លុះត្រាតែមានការចូលរួមពីតួអង្គសំខាន់ៗដូចជា ក្រុមហ៊ុនបោះផ្សាយ វិនិយោគិន ក្រុមហ៊ុនអន្តរការី និងភ្នាក់ងារដាក់ពិន្ទុ។

#### ១.២.៥.៤ អ្នកបោះផ្សាយសញ្ញាបណ្ណ

អ្នកបោះផ្សាយសញ្ញាបណ្ណ អាចជាធនាគារ ស្ថាប័នហិរញ្ញវត្ថុ ក្រុមហ៊ុនសាជីវកម្ម និងរាជរដ្ឋាភិបាល។ គុណសម្បត្តិនៃការបោះសញ្ញាបណ្ណលក់ បើប្រៀបធៀបនឹងកម្ចីពីធនាគារ មាន៖

- សាច់ប្រាក់ដែលបានពីការបោះសញ្ញាបណ្ណ គឺមានទំហំធំជាងពីកម្ចីពីធនាគារ
- អ្នកទិញសញ្ញាបណ្ណ តែងតែស្វែងរកអត្រាការប្រាក់ដែលមានការប្រកួតប្រជែង ជាងអត្រាការប្រាក់ពី ធនាគារ

[5] អ៊ឹង អ៊ូ ឆ្នាំ (២០១៦- ២០១៧) "ទីផ្សារមូលបត្រកម្ពុជា"

- អ្នកបោះផ្សាយសញ្ញាបណ្ណ ទទួលបាននូវសាច់ប្រាក់រយៈពេលយូរជាងរយៈពេលដែលធនាគារផ្តល់កម្ចី

### ១.២.៦ កត្តាជោគជ័យនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ទទួលបានជោគជ័យត្រូវពឹងផ្អែកលើកត្តា ៣ ធំៗ គឺៈ

- មានឧបករណ៍មូលបត្រទិញ-លក់សម្បូរបែប
- មានចំនួនអ្នកទិញ និងអ្នកលក់ច្រើន
- ប្រព័ន្ធជួញដូរប្រកបដោយប្រសិទ្ធិភាព ជាមួយនឹងការបញ្ជូនព័ត៌មានទាន់ពេលវេលា

## ១.៣. មុខងារនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានមុខងារសំខាន់ជាមូលដ្ឋានពីរយ៉ាងគឺៈ

- មុខងារបង្កើនដើមទុន ព្រោះទីផ្សារមូលបត្រជាកន្លែងប្រជុំវិនិយោគិនទាំងអស់ដែលមានដើមទុនដើម្បីវិនិយោគ ទៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណាដែលស្វែងរកទុនដើម្បីបង្កើនមូលធនរបស់ខ្លួន។
- មុខងារសន្ទនីយភាព គឺជាលទ្ធភាពក្នុងការលក់ឧបករណ៍វិនិយោគនៅក្នុងទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រផ្តល់សន្ទនីយភាពតាមរយៈការផ្តល់ជាទីកន្លែងជួញដូរ (តាំងនៅទីកន្លែង និងតាមប្រព័ន្ធអេឡិចត្រូនិច) ដែលក្នុងនោះអ្នកលក់ជួបគ្នាដើម្បីព្រមព្រៀងតម្លៃ និងធ្វើការជួញដូរមូលបត្រ។

## ១.៤. ប្រភេទមូលបត្រ

មូលបត្រ គឺជាទំនិញហិរញ្ញវត្ថុមួយប្រភេទ ដែលមានលក្ខណៈប្លែកពីគេ និងតម្លៃរបស់វាមិនមានទំនាក់ទំនងទៅនឹងទ្រង់ទ្រាយ ឬរូបរាងរបស់វាទេ ប៉ុន្តែវាអាស្រ័យទៅនឹងការសិទ្ធិកាន់កាប់នូវផលប្រយោជន៍ពេលអនាគត និងមិនមានតម្លៃប្រើប្រាស់ដូចជាផ្ទះ ម៉ូតូ ឡាន អង្ករ សាច់ ឬដែកថែបទេ...។ ទំនិញ ធម្មតាជាទំនិញដើម្បីប្រើប្រាស់ ចំណែកឯមូលបត្រវិញជាទំនិញហិរញ្ញវត្ថុ។ ទំនិញហិរញ្ញវត្ថុ គឺមិនមានតម្លៃប្រើប្រាស់ ឬអាចនិយាយឱ្យខ្លីថា គេបោះលុយចោលដើម្បីទិញ នូវប្រដាសបំណុលជំនួសឱ្យបរិមាណលុយ ដែលទទួលបានមកវិញនៅថ្ងៃអនាគតជាមួយនឹងក្តីសង្ឃឹមច្រើនជាងទឹកប្រាក់ដែលបានបោះបង់ចោលនោះ (ប៉ុន្តែក្តីសង្ឃឹមនេះគ្មានពេលណាថាពិតប្រាកដទាំងអស់ទេ) ។

ដំណើរការប្រើប្រាស់នូវប្រភេទទំនិញប្រើប្រាស់ គឺជាការប្រើប្រាស់វាជាមួយនឹងគោលបំណង ជាមធ្យោបាយប្រើប្រាស់សម្រាប់ការរស់នៅ រហូតពេលទំនិញនោះលេងស្ថិតស្ថេរតទៅទៀត ឬក្លាយជាឧបករណ៍ផ្សេងៗទៀត ឬក្លាយជាសំរាម។ ផ្ទុយមកវិញការប្រើប្រាស់មូលបត្រ គឺជាដំណើរការរក្សាវានៅក្នុងដៃ ដូចជាមធ្យោបាយមួយ ដើម្បីបង្កើតជាតម្លៃថ្មី គឺប្រាក់ចំណេញ។ មូលបត្រ គ្រាន់តែអស់តម្លៃនៅពេលដល់កាលកំណត់ប៉ុណ្ណោះ។ បើគ្មានមូលបត្រ វាក៏គ្មានក្រុមហ៊ុនមូលបត្រកើតមានដែរ ដូច្នេះមូលបត្រគឺជាកត្តាមួយដែលបង្កើតក្រុមហ៊ុនមូលបត្រ។ មូលបត្រគឺជាប្រភេទទំនិញពិសេសម្យ៉ាង (ទំនិញហិរញ្ញវត្ថុ) គឺជាឧបករណ៍ម្រមូលមូលធនពីកន្លែងដែលមានមូលធនលើស ទៅកាន់កន្លែងដែលមានមូលធនខ្វះ ពីអ្នកផ្គត់ផ្គង់មូលធនទៅកាន់អ្នកដែលត្រូវការមូលធន។ ការលេចឡើងនូវប្រភេទមូលបត្រជាក់ស្តែង គឺជាសំនូមពរចាំបាច់ ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច។ មូលបត្រ គឺជាប្រភេទទំនិញចរាចរនៅលើទីផ្សារមូលបត្រ ដែលតម្លៃរបស់វាជានិច្ចជាកាលមានការកើនឡើង និងថយចុះជានិច្ចនៅលើទីផ្សារ។ មូលបត្រជាក្រដាសបញ្ជាក់ពីសិទ្ធិរបស់ម្ចាស់កម្មសិទ្ធិមួយចំណែកនៅក្នុងសហគ្រាសណាមួយ នោះត្រូវបានគេហៅថា Stock ចំណែកឯក្រដាសដែលបញ្ជាក់ពីបំណុលគេហៅថា Bonds។

មូលបត្រមានចំនុចពិសេសដូចខាងក្រោម៖

- គឺជាបណ្ណាក្រដាសបញ្ជាក់ពីតម្លៃទ្រព្យសម្បត្តិរបស់ម្ចាស់កម្មសិទ្ធិ
- គឺជាបណ្ណាឧបករណ៍ហិរញ្ញវត្ថុរយៈពេលមធ្យម និងរយៈពេលវែង
- ត្រូវបានការពារពីច្បាប់មូលបត្រ
- ត្រូវបានអនុញ្ញាតដោះដូរផ្ទេរសិទ្ធលើផ្សារមូលបត្រមានន័យថាមានLiquidity ខ្ពស់។

យោងតាមច្បាប់ និងបទប្បញ្ញត្តិមូលបត្រចែកចេញជាពីរប្រភេទ៖ គឺមូលបត្ររដ្ឋ និងមូលបត្រមហាជន។

### ១.៤.១ មូលបត្រមហាជន (Non-government Securities)

សំដៅដល់មូលបត្រដែលត្រូវបានបោះផ្សាយ ដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលផ្សេងទៀតដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយលក់មូលបត្រជាសាធារណៈ។ (ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន) មូលបត្រមហាជនរួមមាន៖

- មូលបត្រកម្មសិទ្ធិ (Equit Securities) រាប់បញ្ចូលទាំងភាគហ៊ុន (Stock)
- មូលបត្របំណុល (Debt Securties) រាប់បញ្ចូលទាំងសញ្ញាបណ្ណ (Bond)
- ផលប្រយោជន៍ក្នុងការវិនិយោគរួម (collection Investment Scheme)

- ឧបករណ៍និទស្សន្ទ ឬឧបករណ៍ដេរីវេទីវ (Derivative Investment)

**១.៤.២. មូលបត្ររដ្ឋ** (Government Securities)

សំដៅដល់ប័ណ្ណ ឬសញ្ញាប័ណ្ណ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងៗទៀតដែលបញ្ជាក់ពីការទទួលស្គាល់បំណុល ដែលបានបោះផ្សាយក្នុងនាមជារាជរដ្ឋាភិបាល (ច្បាប់ស្តីពីមូលបត្ររដ្ឋ) ។ មូលបត្ររដ្ឋរួមមាន៖

- ប័ណ្ណរតនាគារ (Treasury Bills) ដែលមានឥណប្រតិទានតិចជាងមួយឆ្នាំ។
- សញ្ញាប័ណ្ណរតនាគារ ( Treasury Bonds) ដែលមានឥណប្រតិទានចាប់ពីមួយឆ្នាំឡើងទៅ។
- សញ្ញាបណ្ណដែលផលចំណូលផ្សារភ្ជាប់នឹងអតិផរណា ឬអត្រាប្តូរប្រាក់ ឬអត្រាផ្សេងៗ។
- មូលបត្ររដ្ឋដែលមិនអាចជួញដូរបាននៅលើទីផ្សារ។

ចំពោះប្រភេទមូលបត្រដែលចរាចរនៅលើផ្សារមូលបត្ររួមមាន៖

**១. ប័ណ្ណភាគហ៊ុន** ( Stock )

គេអាចមានរាប់រយវិធីដើម្បីវិនិយោគទុន ដើម្បីជ្រើសរើសបាននូវវិធីល្អបំផុត អ្នកវិនិយោគទុន ដំបូងត្រូវស្វែងរកព័ត៌មានទាក់ទងនឹងឧបករណ៍ហិរញ្ញវត្ថុ ដែលពួកគាត់កំពុងពិនិត្យមើល។ ភាគហ៊ុន គឺជាក្រដាសប្រភេទដែលមួយបញ្ជាក់ពីសិទ្ធិក្នុងកម្មសិទ្ធិរបស់ម្ចាស់ភាគហ៊ុន ឬអាចហៅបានថាជាក្រដាសបញ្ជាក់ពីការវិនិយោគរបស់បុគ្គលម្នាក់ទៅក្នុងក្រុមហ៊ុនមួយ។

**១.១. ភាគហ៊ុនធម្មតា** (Common Stock )

- ភាគលាភមិនកំណត់
- មានសិទ្ធិក្នុងការប្រជុំក្រុមប្រឹក្សាភិបាល
- ទទួលបានការទូទាត់ភាគលាភពីក្រុមហ៊ុនក្រោយ Preferred Stock
- មានហានិភ័យខ្ពស់ជាង Preferred Stock

**១.២. ភាគហ៊ុនបុរិមា** (Preferred Stock)

- ទទួលបានអត្រាភាគលាភថេរ
- គ្មានសិទ្ធិក្នុងការសម្រេចចិត្តជ្រើសរើសនៅក្នុងក្រុមបឹក្សាភិបាល
- ទទួលបានការទូទាត់ភាគលាភមុន Common Stock
- មានហានិភ័យតិចជាង Common Stock

## ១.៥. យន្តការទីផ្សារមូលបត្រ

### ១.៥.១. យន្តការទីផ្សារដំបូង

ទីផ្សារដំបូង គឺជាទីផ្សារទ្រព្យសកម្ម ដែលនៅទីនោះមូលបត្រត្រូវបានបោះផ្សាយ និងលក់ជាលើកដំបូងតាមរយៈការធ្វើសំណើទិញ ឬដំណើរការដេញថ្លៃ។ ទីផ្សារដំបូងត្រូវបានជួយសម្រួលដោយសម្ព័ន្ធក្រុមហ៊ុនធានាទិញមូលបត្រដែលរួមមាន ធនាគារវិនិយោគ ដែលនឹងដាក់តម្លៃដេញថ្លៃដំបូងក្នុងចន្លោះណាមួយសម្រាប់មូលបត្រណាមួយ។

យន្តការទីផ្សារដំបូង




### ១.៥.២. យន្តការទីផ្សារបន្ទាប់

ទីផ្សារបន្ទាប់ ជាទីផ្សារមួយដែលវិនិយោគិនទិញមូលបត្រ ឬទ្រព្យពីវិនិយោគិនផ្សេងទៀតជាជាងទិញ ពីក្រុមហ៊ុនបោះផ្សាយដោយផ្ទាល់។ បន្ទាប់ពីភាគហ៊ុនត្រូវបានបោះផ្សាយលក់នៅទីផ្សារដំបូង ភាគហ៊ុនទាំងនោះ នឹងត្រូវបានជួញដូរនៅទីផ្សារបន្ទាប់រវាងវិនិយោគិនគ្នាឯង។ ជាញឹកញាប់នៅក្នុងទីផ្សារដំបូងថ្លៃត្រូវបានកំណត់ជាមុន ខណៈដែលនៅទីផ្សារបន្ទាប់ តម្លៃមូលដ្ឋានដូចជាការផ្គត់ផ្គង់ និងតម្រូវការជាអ្នកកំណត់ថ្លៃមូលបត្រ។

**យន្តការទីផ្សារបន្ទាប់**




## ១.៦. កត្តាជំរុញឱ្យមានការវិនិយោគលើវិស័យមូលបត្រ

កត្តាជម្រុញឱ្យមានការវិនិយោគលើវិស័យមូលបត្រមានចំពោះ៖

❖ អត្ថប្រយោជន៍របស់ទីផ្សារមូលបត្រដល់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ

- ជួយជំរុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគនៅក្នុងសេដ្ឋកិច្ច។
- ជួយពូនផ្តុំមូលធនតូចៗ ទៅជាមូលធនធំមួយ ដើម្បីវិនិយោគនៅក្នុងវិស័យសេដ្ឋកិច្ចរូបវន្ត។
- ជួយសម្រួលដល់រាជរដ្ឋាភិបាលក្នុងការអនុវត្ត នូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម។
- ជួយទាក់ទាញ និងស្រូបយកមូលធនពីបរទេស។
- ជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា ប្រកបអាជីវកម្មដោយប្រសិទ្ធភាព និងមានតម្លាភាព។
- ជួយជំរុញឱ្យប្រភពមូលធនក្នុងស្រុកមានចរាចរ ឬចលនារស់រវើក។
- ជួយបង្កើតនូវទម្លាប់នៃការវិនិយោគ។
- ទាក់ទាញវិនិយោគិនបរទេសមកធ្វើការវិនិយោគ។

➢ អ្នកវិនិយោគ

ដើម្បីបង្កើតនូវទំនុកចិត្តដល់ការវិនិយោគ ក្នុងទីផ្សារមូលបត្រកម្ពុជាពីសំណាក់សាធារណជន គ.ម.ក. មានវិធានការដូចខាងក្រោម ៖

- បទដ្ឋានគតិយុត្តដែលមានភាពរឹងមាំ
- ការអប់រំវិនិយោគិន និងសាធារណជន
- ក្រុមហ៊ុនដែលកំពុងបោះផ្សាយ មានអភិបាលកិច្ចល្អ
- ក្រុមហ៊ុនមូលបត្រដែលធ្វើធុរៈកិច្ចស្របតាមក្រមសីលធម៌វិជ្ជាជីវៈ
- ប្រព័ន្ធជួញដូរដែលមានប្រសិទ្ធិភាព និងទាន់ពេលវេលា

➢ ប្រជាពលរដ្ឋ

- ប្រជាពលរដ្ឋដែលនៅតាមស្រុកស្រែចំការដែល គាត់មិនបានយល់ពីទីផ្សារនេះ ពួកគាត់ នឹងទទួលបាននូវអត្ថប្រយោជន៍ដែរ
- ផលចំណេញពីការលក់ដូរជុំវិញក្រុមហ៊ុនដែលបានពង្រីកធុរកិច្ច
- បង្កើនការងារធ្វើតាមរយៈ ការពង្រីកធុរកិច្ចរបស់ក្រុមហ៊ុនបោះផ្សាយ ដែលទទួលបានមូលធនរយៈពេលវែង ពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

## ១.៧ តួអង្គចូលរួមក្នុងទីផ្សារមូលបត្រ

[6]ទីផ្សារមូលបត្រ អាចដំណើរការបាន លុះត្រាតែមានតួអង្គសំខាន់ចូលរួមដូចជាៈ ក្រុមហ៊ុនបោះផ្សាយ (ក្រុមហ៊ុនឯកជន រាជរដ្ឋាភិបាល និងក្រុមហ៊ុនបរទេស ) ក្រុមហ៊ុនមូលបត្រ (ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ និងក្រុមប្រឹក្សាវិនិយោគ) វិនិយោគិន (អាចជាធនាគារពាណិជ្ជ ធនាគារឯកទេស ក្រុមហ៊ុនមីក្រូហ្វាណាន់ ក្រុមហ៊ុនសាជីវកម្ម រាជរដ្ឋាភិបាល ក្រុមហ៊ុនធានារ៉ាប់-រង ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងឯក្កជន) និងគណៈ-កម្មការមូលបត្រកម្ពុជា (និយ័តករមូលបត្រ)។

### ១.៧.១. តួអង្គសំខាន់ៗ

➢ **និយ័តករមូលបត្រ**

និយ័តករមូលបត្រគឺជានីតិបុគ្គលដែលបង្កើតឡើងដើម្បីគ្រប់គ្រង និងត្រួតពិនិត្យប្រតិបត្តិការមូលបត្រ។ និយ័តករមូលបត្រនៅក្នុងប្រទេសកម្ពុជាគឺជា គណៈកម្មការមូលបត្រកម្ពុជា **គ.ម.ក**

[6] www.secc.gov.kh

(Securities and Exchange Commission of Cambodia/SECC)។ គ.ម.ក. បានបង្កើតឡើងថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៨ និងដាក់សម្ពោធ ជាផ្លូវការថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៩។

➢ **ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា**

ទីផ្សារមូលបត្រ សំដៅដល់ទីផ្សារ ឬទីកន្លែងជួញដូរមូលបត្រ ឬប្រព័ន្ធដែលផ្តល់មធ្យោបាយនៃការធ្វើសំណើរលក់ ផ្ទេរ ឬស្ទីការទិញ-លក់មូលបត្រ។ ទីផ្សារមូលបត្រនៅក្នុងប្រទេសកម្ពុជាមានឈ្មោះថា ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (Cambodia Securities Exchange)។ ទីផ្សារមូលបត្របានដាក់សម្ពោធជាផ្លូវថ្ងៃទី ១១ខែ កក្កដា ឆ្នាំ ២០១១ ហើយទីផ្សារមូលបត្រជួញដូរជាផ្លូវការថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២។ ក្រុមហ៊ុនផ្សារមូលបត្រដើរតួនាទីជា ប្រតិបត្តិករទីផ្សារមូលបត្រ ដែលជាកន្លែងមូលបត្រត្រូវបានទិញ និងលក់ ហើយជាកន្លែងផ្តល់ប្រព័ន្ធជួញដូរ។ មួយទៀត ជាប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ ដែលត្រួតពិនិត្យមូលបត្រខាងអ្នកលក់ និងសាច់ប្រាក់ខាងអ្នកទិញ ដើម្បីបញ្ចៀសហានិភ័យ និងជាប្រតិបត្តិការរក្សាទុកមូលបត្រ ជាអ្នករក្សាទុកមូលបត្រ និងធ្វើការផ្លាស់ប្តូរកម្មសិទ្ធិករ និងតម្កល់មូលបត្រ និងដកចេញមូលបត្រ។

ក្រុមហ៊ុនផ្សារមូលបត្រ ជាកន្លែងដែលមានបំណងជួយសម្រួលដល់ការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា ជួយបង្កើតនូវបរិយាកាសជួញដូរមូលបត្រ ដែលអំណោយផលដល់ការវិនិយោគិនទាំងក្នុង និងក្រៅប្រទេស ហើយជួយបង្កើននូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់ចូលរួមទីផ្សារ និងដើម្បីដាក់ឱ្យដំណើរការនៅសហគ្រាសសាធារណៈមួយដែលមានស្វ័យចិរភាពក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

**រចនាសម្ព័ន្ធគ្រប់គ្រង**



ចំពោះក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជាមានសមាជិក ៧រូប តែងតាំងដោយរដ្ឋាភិបាលកម្ពុជាសមាជិក ៤រូប និង តែងតាំងដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េសមាជិក ៣រូប។

➢ **ក្រុមហ៊ុនមូលបត្រ**

ក្រុមហ៊ុនមូលបត្រ គឺជាក្រុមហ៊ុនដែលទទួលអាជ្ញាប័ណ្ណសម្រាប់ធ្វើអាជីវកម្មមូលបត្រ។ ការធ្វើអាជីវកម្មត្រង់ចំនុចនេះ សំដៅដល់ការបើកអាជីវកម្មរបស់ក្រុមហ៊ុនផ្សារមូលបត្រ ក្រោយពីទទួលបានអាជ្ញាបណ្ណ។ ក្រុមហ៊ុនមូលបត្រអាចធ្វើអាជីវកម្ម បានលុះត្រាណាតែទទួលបានការអនុញ្ញាតពី គ.ម.ក។ ក្រុមហ៊ុននេះបានស្វែងរកកេរ្តិ៍ឈ្មោះ តាមរយៈការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ ហើយវាជាអន្តរការីដែលជួយបង្កើនមូលនិធិដល់សាជីវកម្ម។

➢ **ក្រុមហ៊ុនធានាទិញមូលបត្រ**

ក្រុមហ៊ុនធានាទិញមូលបត្រ គឺអាចធ្វើអាជីវកម្មបានទាំងការផ្តល់ប្រឹក្សាទិញមូលបត្រចាត់ចែងរៀបចំដំណើរការលក់មូលបត្រជាសាធារណៈឱ្យក្រុមហ៊ុនបោះផ្សាយ។ នៅពេលដែលសាជីវកម្មចង់បង្កើនមូលនិធិ ពេលនោះពួកគេបានសម្រេចចិត្តបោះផ្សាយលក់មូលបត្ររយៈពេលវែង ជាហេតុមួយដែលវាចាំបាច់ ត្រូវរកក្រុមហ៊ុនធានាទិញដើម្បីជួយសម្រួលដល់ការលក់មូលបត្រ។ ចំពោះដំណើរនៃការធានាលើការបោះផ្សាយមូលបត្រ គឺមូលបត្រដែលក្រុម-ហ៊ុនបានទិញចូលនៅតម្លៃកំណត់ទុកមុន ហើយវាក៏មានសេវាមួយចំនួនដែលផ្គត់ផ្គង់នៅក្នុងដំណើរការធានាទិញដូចជា រៀបចំឯកសារ ផ្តល់ប្រឹក្សាយោបល់។

- ផ្តល់ប្រឹក្សាដល់ការបោះផ្សាយលក់មូលបត្រជាសាធារណៈដូចជា ការដាក់តម្លៃមូលបត្រ ការកំណត់ទំហំសាច់ប្រាក់ និងចំនួនមូលបត្រ នៃសំណើបោះផ្សាយ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈជាដើម។
- ទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុន ក្នុងគោលដៅចែកចាយ ឬលក់បន្ត។
- ទិញមូលបត្រដែលលក់មិនអស់ក្នុងដំណើរការនៃការបោះផ្សាយលក់ ដើម្បីធានានូវជោគជ័យនៃការបោះផ្សាយ។
- ចាត់ចែងដំណើរការ ការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឱ្យក្រុមហ៊ុនបោះផ្សាយ

ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណជាក្រុមហ៊ុនធានាទិញមូលបត្រ អាចធ្វើអាជីវកម្មបានដូចជាធានាទិញមូលបត្រ ជួញដូរមូលបត្រ ដើងសារមូលបត្រ និងផ្តល់ប្រឹក្សាវិនិយោគ។ម៉្យាងវិញទៀតក្រុមហ៊ុនប្រភេទនេះបានផ្តល់យោបល់ដល់សាជីវកម្ម មានបំណងបន្ថែមដើម

ទុនរបស់ខ្លួន ដែលពិបាកចម្រេចចិត្ត ដើម្បីជ្រើសរើសនៅវិធីសាស្ត្រណាដែលល្អសម្រាប់គាត់។ ដូចជាការសម្រេចចិត្តបោះពុម្ព Stock ឬ Bond ដែលក្រុមហ៊ុននេះអាចជួយធ្វើវិភាគលើបញ្ហានេះបាន។ ឧទាហរណ៍ តម្លៃ Stock នៅលើទីផ្សារកាន់តែខ្ពស់ និងអត្រាការប្រាក់លើ Bond កាន់តែទាប។ ក្រុមហ៊ុនត្រូវការការផ្តល់យោបល់ផងដែរ នៅពេលដែលមូលបត្រត្រូវលក់។ ឧទាហរណ៍ ប្រសិនបើអ្នកប្រកួតប្រជែងបានបង្ហាញពីរបាយការណ៍ចំណូល ដែលបង្ហាញពីប្រាក់ចំណេញទាបនោះ វាអាចប្រសើរសម្រាប់ការរង់ចាំមុនបោះបង់ការលក់ ក្រុមហ៊ុនចង់កំណត់ពេលទីផ្សារ ដើម្បីលក់ Stock នៅពេលវេលានឹងឡើងតម្លៃខ្ពស់បំផុត។ មួយវិញទៀតជារៀងរាល់ថ្ងៃ វាមានឥទ្ធិពលទៅវិញទៅមកជាមួយនឹងទីផ្សារមូលបត្រ ដែលក្រុមហ៊ុនធានាទិញអាចផ្តល់ប្រឹក្សាវិនិយោគបាន ទៅលើពេលវេលាសម្រាប់ការលក់។ ការកំណត់តម្លៃមូលបត្រ វាជាការពិបាកណាស់សម្រាប់ការបោះពុម្ពមូលបត្រលើកដំបូង ដែលគេហៅថា Initial public offering (IPO) ប៉ុន្តែចំពោះមូលបត្រដែលធ្លាប់បោះផ្សាយច្រើនហើយនោះ វាងាយស្រួលក្នុងការកំណត់តម្លៃ ដែលការបោះពុម្ពនោះគេហៅថា Second Issues ។

ក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាបណ្ណពីគ.ម.ក មានចំនួន៧ រួមមាន៖ យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី, អ អេច ប៊ី អូ អេស ខេ ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី លីមីតធីត, កាណា ស៊ីឃ្យូរីធី អិលធីឌី, កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី, ខេមបូឌា- វៀតណាម ស៊ីឃ្យូរីធី ភីអិលស៊ី, អេស ប៊ី អាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី, ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី។

SBI Royal Securities

យាន់តា ស៊ីឃ្យួរីធី Yuanta Securities (Cambodia)

ក្រុមហ៊ុនធានាទិញមូលបត្រ : ក្រុមហ៊ុនធានាទិញមូលបត្រ មានតួនាទីដូចខាងក្រោម៖

- ជួញក្រុមហ៊ុនដែលមានបំណងបោះផ្សាយលក់មូលបត្រជាសាធារណៈធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង (IPO) ។
- កំណត់ថ្លៃមូលបត្រ ទំហំទឹកប្រាក់ ចំនួនមូលបត្រ ប្រភេទមូលបត្រ និងពេលវេលានៃការបោះផ្សាយ លក់មូលបត្រជាសាធារណៈជាដើម។
- ដឹកនាំក្រុមការងារធ្វើការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។
- នៅពេលបើកឱ្យធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់នូវទម្រង់នៃការធ្វើបរិវិសកម្ម ទៅឱ្យវិនិយោគិន បញ្ជូនទម្រង់នេះ ទៅកាន់ភ្នាក់ងារបញ្ជិកាមូលបត្រ។
- ក្រុមហ៊ុនធានាទិញ ត្រូវធានាទិញនូវមូលបត្រដែលសេសសល់ក្នុងករណីមានការធ្វើបរិវិសកម្មមូលបត្រមិនអស់។

➢ **ក្រុមហ៊ុនជួញដូរមូលបត្រ**

ក្រុមហ៊ុនជួញដូរមូលបត្រ គឺជាការជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង។ ក្រុមហ៊ុនប្រភេទនេះធ្វើអាជីវកម្មក្នុងទីផ្សារទី២ ហើយវាជាអន្តរការីមួយ ដែលមានសកម្មភាព ដូចភ្នាក់ងារសំរាប់អ្នកវិនិយោគនៅក្នុងការទិញ ឬលក់មូលបត្រ។ មុខងាររបស់ពួកគេគឺ ភ្ជាប់ទំនាក់ទំនងរវាងអ្នកលក់ និងអ្នកទិញដែលពួកគេចំណាយលើថ្លៃសេវា។ ក្រុមហ៊ុនប្រភេទនេះខុសពី ក្រុមហ៊ុនឈ្មួញជើងសារ ត្រង់ថាវាភ្ជាប់អ្នកទិញ និងអ្នកលក់ដោយឈរជាអ្នកទិញ និងអ្នកលក់មូលបត្រនៅតម្លៃបានកំណត់។ វារកប្រាក់ចំណេញតាម

រយៈកំណត់រវាង Bid Price and ASK Price។ ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណជាក្រុមហ៊ុនធានាជួញដូរមូលបត្រ អាចធ្វើអាជីវកម្មបានដូចជាជួញដូរមូលបត្រ ជើងសារមូលបត្រ និងផ្តល់ប្រឹក្សាវិនិយោគ។

ក្រុមហ៊ុនជួញដូរមូលបត្រនៅកម្ពុជាមាន ឈ្មោះថា ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យូរីធី ភីអិលស៊ី។

-ក្រុមហ៊ុនពាណិជ្ជករមូលបត្រៈ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ មានតួនាទីដូចខាងក្រោម :

- ទិញ-លក់មូលបត្រក្នុងគណនីរបស់ខ្លួន
- ផ្តល់សេវាជួញដូរមូលបត្រក្នុងនាមគណនីរបស់អតិថិជន (ការបើកអត្ត-សញ្ញាណវិនិយោគិន គណនីជួញ)
- ដូរមូលបត្រ ទទួលការបញ្ជាទិញ-លក់ បង្គាប់ឱ្យអតិថិជនដាក់ប្រាក់ និងមូលបត្រទៅក្នុងគណនីរបស់ខ្លួន ប្រាប់ ដំណឹងមកកាន់អតិថិនជនទូទាត់

  កាតូកិច្ចជំនួសអតិថិជនពេលកាលបរិច្ឆេទ T+2 ។

➢ **ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ**

ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ គឺជាការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួន ដោយទទួលបាននូវកម្រៃជើងសារ។ ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រនៅកម្ពុជា គឺក្រុមហ៊ុន អេសស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី, ខេម ស៊ីឃ្យូរីធី លីមីធីត។

➢ ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ : ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ មានតួនាទីដូចខាងក្រោម :

- ផ្តល់សេវាជួញដូរមូលបត្រក្នុងនាមគណនីរបស់អតិថិជន (ការបើកអត្តសណ្ណាវិនិយោគិន គណនីជួញដូរមូលបត្រ ទទួលការបញ្ជាទិញ-លក់ បង្គាប់ឱ្យអតិថិជនដាក់ប្រាក់ និងមូលបត្រទៅក្នុងគណនីរបស់ខ្លួន ប្រាប់ដំណឹង មកកាន់អតិថិនជនទូទាត់កាត្វកិច្ចជំនួសអតិថិជនពេលកាលបរិច្ឆេទ T+2 ។

➢ អាកប្បកិរិយា ត្រូវហាមឃាត់របស់ក្រុមហ៊ុនមូលបត្រ :

- ធ្វើការបញ្ជាទិញ-លក់មូលបត្រដោយគ្មានបញ្ជាពីអតិថិជនរបស់ខ្លួន។
- ទទួលការបញ្ជាទិញ-លក់ពីអតិថិជន តែបរិមាណ ថ្លៃ និងពេលវេលា មិនគោរពតាមបញ្ជារបស់អតិថិជនខ្លួន (តែបើសិនការបញ្ជាទិញ-លក់មូលបត្រនោះ ខុសនឹងគោលការណ៍វិនិយោគ មានចំនួនច្រើនដងពេក សម្រាប់បុគ្គលផ្សេងទៀត)។
- ក្រុមហ៊ុនមូលបត្រ មិនត្រូវជំរុញឱ្យអតិថិជនរបស់ខ្លួនធ្វើការទិញ-លក់ច្រើនដង ឬមានទំហំធំពេកនោះទេ។
- គ្មានបុគ្គលិកនៃក្រុមហ៊ុនមូលបត្រ អាចធ្វើការបញ្ជាទិញ-លក់ក្នុងនាមគណនីខ្លួន។
- ភ្នាក់ងារផ្តល់ទីប្រឹក្សាវិនិយោគ មិនត្រូវធានាក្នុងការតបស្នងនូវការខាតបង់ពីការទិញលក់មូលបត្រដែលខ្លួនបានផ្តល់យោបល់ឡើយ ប៉ុន្តែក្រុមហ៊ុន ត្រូវសងនូវរាល់ការខាតបង់របស់អតថិជន បើសិនអតិថិជន ទទួលបានជ័យជំនះលើសកម្មភាពមិនស្របច្បាប់ណាមួយរបស់ក្រុមហ៊ុន តាមរយៈការដោះស្រាយវិវាទ និងពាក្យបណ្តឹងពី គ.ម.ក.។
- បុគ្គលិករបស់ក្រុមហ៊ុនមូលបត្រ មិនត្រូវអះអាងទៅកាន់បុគ្គលណាមួយដើម្បីរៀបចំឱ្យអតិថិជនរបស់ខ្លួន ខ្ចីប្រាក់ពីបុគ្គលនោះដើម្បីទិញមូលបត្រឡើយ។
- ភ្នាក់ងារក្រុមហ៊ុនមូលបត្រ មិនត្រូវរៀបចំឱ្យអតិថិជនរបស់ខ្លួនប្រើប្រាស់នូវគណនីជួញដូររបស់អ្នកដំទៃឡើយ។
- បុគ្គលិកក្រុមហ៊ុនមូលបត្រ មិនត្រូវធ្វើការជួញដូរមូលបត្រសម្រាប់គណនីខ្លួនឯងក្រោមឈ្មោះគណនីអ្នកដំទៃឡើយ។

- ភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ មិនត្រូវទទួលបញ្ហាណាដែលសង្ស័យថាជាការបន្លំទីផ្សារ ហើយត្រូវរាយការណ៍ជូន គ.ម.ក. ជាបន្ទាន់ និងសកម្មភាពជាច្រើនទៀត។

➢ **ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ**

ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ គឺជាផ្តល់ប្រឹក្សាវិនិយោគ ទៅលើមូលបត្រដល់អ្នកវិនិយោគសាធារណៈដោយទទួលបានកម្រៃសេវា។ មួយទៀតគឺផ្តល់ប្រឹក្សាវិនិយោគ លើការបោះផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រ ជូនដល់អ្នកវិនិយោគសាធារណៈ។ ក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ មានក្រុមហ៊ុន អង្គរ ឃែភីថល អ៊ែតវ៉ាយហ្សឺរ និង ក្រុមហ៊ុន អេហ្វ យូ ជី អាយ ហ្គោល។

➢ ក្រុមហ៊ុនផ្តល់ទីប្រឹក្សាវិនិយោគ ៖ ក្រុមហ៊ុនផ្តល់ទីប្រឹក្សាវិនិយោគ មានតួនាទីផ្តល់នូវការប្រឹក្សាយោបល់នូវរាល់ចម្ងល់ មុននឹងធ្វើការសម្រេចចិត្តរបស់អតិថិជន។ ក្រុមហ៊ុន មិនត្រូវញុសញុងឱ្យអតិថិជនរបស់ខ្លួនទិញ ឬមិនទិញនូវមូលបត្ររបស់ក្រុមហ៊ុនណាមួយឡើយ ក្នុងគោលបំណងទទួលបាននូវផលប្រយោជន៍ពីសេវារបស់ខ្លួន។

➢ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ៖ ជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលបោះផ្សាយលក់មូលបត្រជាសាធារណៈ ឬជាក្រុមហ៊ុនត្រូវការមូលធនពីទីផ្សារមូលបត្រមានដូចជា រដ្ឋករទឹកស្វយ័តក្រុងភ្នំពេញ ក្រុមហ៊ុន Grand Twins កំពង់ផែស្វយ័តក្រុងភ្នំពេញ ក្រុមហ៊ុនភ្នំពេញអេសអុីហ្សិត ភីអិលស៊ី និង កំពង់ផែស្វយ័តក្រុងព្រះសីហនុ។

➢ វិនិយោគិនសាធារណៈ ៖ វិនិយោគិនសាធារណៈ ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលទិញលក់មូលបត្រ ឬអាចហៅម៉្យាងទៀតបានថាជាបុគ្គល ដែលស្វែងរកប្រាក់ចំណេញពីការវិនិយោគលើមូលបត្រ។

### ១.៧.២. តួអង្គចូលរួមដទៃទៀត

❖ ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

- ចូលរួមក្នុងក្រុមការងារ IPO
- ត្រួតពិនិត្យ និងផ្តល់យោបល់ពីការបំពេញកាតព្វកិច្ចផ្នែកច្បាប់
- ធ្វើរបាយការណ៍បញ្ជាក់ពីការបំពេញកាតព្វកិច្ចតាមច្បាប់

ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. មានចំនួន ១០ (ដប់) ក្រុមហ៊ុន៖

**LKL – Lion King Law Firm**

❖ ក្រុមហ៊ុនគណនេយ្យជំនាញ

ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដទៃទៀតដែលធ្វើធុរកិច្ចនៅក្នុងវិស័យមូលបត្រ ត្រូវជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករ ឯករាជ្យ ដែលទទួលបានការទទួលស្គាល់ដោយ គ.ម.ក. ដើម្បីធ្វើសវនកម្ម នូវរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។

ក្រុមហ៊ុនគណនេយ្យជំនាញ និងសវនករឯករាជ្យផ្តល់សេវាក្នុងវិស័យមូលបត្រដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. មានចំនួន ០៦ (ប្រាំមួយ) ក្រុមហ៊ុន៖

**ANGKOR CERTIFIED ACCOUNTANT NETWORK MC**

❖ ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ

ក្រុមហ៊ុនបោះផ្សាយ និងក្រុមហ៊ុនដទៃទៀត ដែលធ្វើធុរកិច្ចនៅក្នុង វិស័យមូលបត្រត្រូវជ្រើសរើសក្រុមហ៊ុនវាយតម្លៃ និងអ្នកវាយតម្លៃឯករាជ្យ ដែលទទួលបានការទទួលស្គាល់ដោយ គ.ម.ក. ដើម្បីវាយតម្លៃទ្រព្យសកម្ម ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវស្តង់ដារដែលបានកំណត់។

ក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** មានចំនួន ២ ក្រុម-ហ៊ុន៖

❖ ភ្នាក់ងារបញ្ជាកាមូលបត្រ

- គ្រប់គ្រងនូវដំណើរការនៃការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រ
- កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រ
- ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រ
- ភ្នាក់ងារបញ្ជិកាមូលបត្រដែលទទួលបាន គ.ម.ក. មានចំនួន ០២ (ពីរ) ក្រុមហ៊ុន

❖ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ

- រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រ ឱ្យមានសង្គតិភាព
- រដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិ ការធ្វើរបាយការណ៍ ស្ថិតិ...
- រៀបចំការងារពាក់ព័ន្ធនឹងសិទ្ធិកម្មសិទ្ធិករមូលបត្រ ដូចជាការជូនដំណឹងអំពីការបែងចែកភាគលាភ ការបង់ការប្រាក់
- ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. មានចំនួន ០២ (ពីរ) ក្រុមហ៊ុន៖

❖ ភ្នាក់ងារទូទាត់

- គណនាភាគលាភ ការប្រាក់ ប្រាក់ដើម
- ធ្វើការទូទាត់ជូនកម្មសិទ្ធិករ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយ
- បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់ កម្មសិទ្ធិករមូលបត្រ និងទៅក្រុមហ៊ុនបោះផ្សាយ និង គ.ម.ក. តាមការចាំបាច់

• ភ្នាក់ងារទូទាត់ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក.មានចំនួន ០២ (ពីរ) ក្រុមហ៊ុន៖

**E-PRINTING (CAMBODIA) Co.,Ltd**

❖ ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

- ធ្វើការគ្រប់គ្រងគណនីទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ដូចជាការផ្ទេរ ឬការបង្វែរសាច់ប្រាក់ រវាងគូភាគីជួញដូរ
- ធ្វើប្រតិបត្តិការទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ប្រកបដោយសុវត្ថិភាព
- បំពេញប្រតិបត្តិការឱ្យដាច់ដោយឡែកពីមុខងារប្រតិបត្តិការធនាគារ
- ភ្នាក់ងារទូទាត់សាច់ប្រាក់ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**មានចំនួន ៣ ធនាគារ៖

❖ ក្រុមហ៊ុនផ្តល់សេវាបកប្រែ

- បកប្រែឯកសារពាក់ព័ន្ធនឹង IPO ឱ្យបានត្រឹមត្រូវតាមអត្ថន័យដើម
- ក្រុមហ៊ុនបកប្រែដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. មានចំនួន ០២(ពីរ) ក្រុមហ៊ុន៖

❖ ក្រុមហ៊ុនផ្តល់សេវាបោះពុម្ព

- ធានាថាឯកសារបោះពុម្ពពាក់ព័ន្ធនឹង IPO មានលក្ខណៈត្រឹមត្រូវតាមច្បាប់ដើម
- ក្រុមហ៊ុនផ្តល់សេវាបោះពុម្ពដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.**មានចំនួន ០២(ពីរ) ក្រុមហ៊ុន៖

❖ ក្រុមហ៊ុនសារព័ត៌មានទូរទស្សន៍

- ផ្សព្វផ្សាយព័ត៌មាននានាពាក់ព័ន្ធនឹងវិស័យមូលបត្រ
- ក្រុមហ៊ុនសារព័ត៌មានទូរទស្សន៍ដែលទទួលបានការទទួលស្គាល់ពី គ.ម.ក. មានចំនួន ០២ (ពីរ) ក្រុមហ៊ុន៖

**១. CAMBODIAN BROADCASTING SERVICE Co., Ltd**

២. ផូស មេឌា ខូអិលធីឌី Post Media Co, Ltd

ភ្នំពេញប៉ុស្តិ៍

## ១.៨. អត្ថប្រយោជន៍នៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រគឺជា កត្តាមូលដ្ឋានសេដ្ឋកិច្ចមួយយ៉ាងសំខាន់សម្រាប់សេដ្ឋកិច្ចជាតិ គេតែងតែ និយាយថា ទីផ្សារមូលបត្រគឺជានិមិត្តរូបនៃសេដ្ឋកិច្ចជាតិមួយទាំងមូល។ ជាការពិតណាស់រាល់ការប្រែប្រួលនៃបរិ បទសេដ្ឋកិច្ច វានឹងមានឥទ្ធិពលទៅលើតម្លៃមូលបត្រ ដូច្នេះយើង គួរវិភាគផងដែរនូវបរិយាកាសខាងក្រៅផង ដែរហើយបើយើង ក្រលេកមើលទៅលើសន្ទស្សន៍ហ៊ុន គេនឹងឃើញពីឥទ្ធិពលរបស់ទីផ្សារមូលបត្រលើសេដ្ឋកិច្ច យ៉ាងណា ពីព្រោះសន្ទស្សន៍ហ៊ុនរបស់ទីផ្សារមូលបត្រ វាបានឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចជាតិ។ ហេតុនេះស្ទើរ តែគ្រប់បណ្តាប្រទេសអភិវឌ្ឍន៍ និងកំពុងអភិវឌ្ឍន៍ទាំងអស់មានទីផ្សារមូលបត្រនេះ ហើយវាបានដើរតួនាទីយ៉ាង សំខាន់ ចំពោះសេដ្ឋកិច្ចជាតិ តែទោះបីវា មានគុណសម្បត្តិដ៏សំខាន់សម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ចជាតិក៏ដោយ ក៏មានគុណវិបត្តិមួយចំនួនផងដែរ ជាពិសេសសម្រាប់ បណ្តាប្រទេសមានប្រព័ន្ធច្បាប់ទន់ខ្សោយដែលតែង តែជួបប្រទះនូវបញ្ហាដូចខាងក្រោមនេះ៖

- ការឆក់ឱកាសកេងចំណេញ ក្នុងការទិញ-លក់ (Speculation)៖ គឺជាការជួញដូរមួយដែលមានការគិត គូរយ៉ាងម៉ត់ចត់ ដើម្បីទទួលបានផលចំណេញ ដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសក្នុងការកេងចំណេញ ក្នុងការទិញលក់នេះ អាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្នដោយរំពឹងថានាពេលអនាគត នឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ការឆក់ឱកាស កេងចំណេញក្នុងការទិញ-លក់របៀបនេះ វានឹងធ្វើ អោយមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះធ្វើឱ្យមានភាពងាយស្រួល នៅពេលពួកគេត្រូវគ្នាក្នុងការ ជួញដូរ ដែលនាំឱ្យស្ថានភាពនៅលើទីផ្សារមានពេលខ្លះធ្វើឱ្យភាគហ៊ុនខ្វះ ឬលើស ហើយធ្វើឱ្យមានចលនាឡើង ចុះតម្លៃនៃការជួញដូរមូលបត្រនៅទីផ្សារមូលបត្រ។
- ការជួញដូរផ្ទៃក្នុង៖ មានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ ក្រុមហ៊ុនដើម្បីធ្វើការជួញដូរភាគហ៊ុនស្វែងរកចំណេញរបស់ខ្លួន

ដែលមានឥទ្ធពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារ មូលបត្រ ដែលព័ត៌មាននោះមិនមែនព័ត៌មានសាធារណៈ (ព័ត៌មានសំងាត់)។

❖ ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារៈ គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវៀស មិនធ្វើសកម្មភាពដែលបណ្តាលឱ្យសាធារណជនទិញ-លក់មូលបត្រ ឬបណ្តាលឱ្យមានការកើនឡើង ឬថយចុះ ឬ នៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រ។

❖ ក្រុមហ៊ុនដែលបោះផ្សាយលក់មូលបត្រតម្រូវឱ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិ បាលកិច្ចសាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្ការ មកវិញនូវទុនរយៈ ពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។

❖ ទីផ្សារមូលបត្រជាកាតាលីករមួយ ជួញជំរុញឱ្យសេដ្ឋកិច្ចរបស់ប្រទេសមួយរីកចំរើនទៅមុខបាន។ ចំពោះអ្នកដែលចូលរួមនៅក្នុងទីផ្សារមូលបត្រ ក៏ដូចជាសង្គមជាតិគឺនឹងទទួលបានអត្ថប្រយោជន៍ទាំងអស់ ហើយអត្ថប្រយោជន៍ទាំងនោះរួមមានៈ

- ចំពោះក្រុមហ៊ុនបោះផ្សាយ
- ចំពោះវិនិយោគិន
- ចំពោះរដ្ឋាភិបាល
- ចំពោះសេដ្ឋកិច្ច

# ជំពូកទី២
# ស្ថានភាពទូទៅនៃគណៈកម្មការមូលបត្រកម្ពុជា

## ២.១. សាវតារបស់គណៈកម្មការមូលបត្រកម្ពុជា

[7]គណៈកម្មការមូលបត្រកម្ពុជា( គ.ម.ក.) ជាស្ថាប័នដែលមានមុខងារគ្រប់គ្រង ត្រួតពិនិត្យទីផ្សារមូលបត្រ គ្រប់គ្រងបណ្តាប្រតិបត្តិករមូលបត្រ ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនបោះផ្សាយមូលបត្រ និងសំដៅការពារអ្នកវិនិយោគមូលបត្រ ព្រមទាំងធានាឲ្យមានការជួញដូរមូលបត្រប្រកបដោយសណ្តាប់ធ្នាប់ និងត្រឹមត្រូវនៅក្នុងវិស័យមូលបត្រ នៃព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មការមូលបត្រកម្ពុជាត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០០៧។ ការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ម.កត្រូវបានធ្វើឡើងដោយ អនុលោមតាមអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០០៨។ គ.ម.ក មានទីតាំងស្ថិតនៅផ្ទះលេខ ៩៩ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខ័ណ្ឌឬស្សីកែវ រាជធានីភ្នំពេញ។

### ២.១.១ ក្រុមប្រឹក្សាភិបាល

- ប្រធានរបស់គណៈកម្មការមូលបត្រកម្ពុជា ជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សមាជិកនៃក្រុមប្រឹក្សាភិបាល មានសមាសភាពដូចខាងក្រោម៖
    1. តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ១ រូប
    2. តំណាងធនាគារជាតិនៃកម្ពុជា ១ រូប
    3. តំណាងក្រសួងពាណិជ្ជកម្ម ១ រូប
    4. តំណាងក្រសួងយុត្តិធម៌ ១ រូប
    5. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១ រូប
    6. អគ្គនាយក គ.ម.ក ១ រូប
    7. អ្នកជំនាញដែលមានបទពិសោធន៍វិស័យមូលបត្រ ២ រូប

[7] http://www.secc.gov.kh

### ២.១.២ អាណត្តិរបស់គណៈកម្មការមូលបត្រកម្ពុជា

គ.ម.ក ត្រូវបានបង្កើតឡើងក្រោមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន ដែលមានប្រធាន ១ (មួយ)រូប និងសមាជិក ៨ (ប្រាំបី) រូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ។ សមាជិក គ.ម.ក មានអាណត្តិរយៈពេល ៥ (ប្រាំ) ឆ្នាំ ហើយអាចត្រូវបានតែងតាំងជាថ្មីម្តងទៀត ឬក៏ផ្ទេរភារកិច្ចតាមបញ្ជារបស់ប្រធាន គ.ម.ក នៅពេលផុតអាណត្តិ។ ក្នុងរយៈពេលនៃការបំពេញការងាររបស់ខ្លួន សមាជិកអាចត្រូវដកហូត ឬផ្លាស់ប្តូរភារកិច្ចមុនពេលផុតអាណត្តិ។ មួយវិញទៀត សមាជិក គ.ម.ក អាចត្រូវបានតែងតាំងជាថ្មីទៀត ទៅតាមសំណើរបស់ប្រធានរបស់ គ.ម.ក នៅពេលផុតអាណត្តិ។

## ២.២ និមិត្តសញ្ញារបស់គណៈកម្មការមូលបត្រកម្ពុជា

### ២.២.១ រូបសញ្ញា និងអត្ថន័យនៃរូបសញ្ញា

#### ២.២.១.១ រូបសញ្ញា

- រូបហង្សពណ៌មាស។
- រូបភាពស្លឹកឈើផ្នែកខាងឆ្វេងមានរំលេចស្រមោលពណ៌មាស ហើយខាងស្តាំរំលេច ស្រមោលពណ៌ប្រ ផេះ។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ។
- ព័ទ្ធជុំវិញជារង្វង់នៅផ្នែកខាងលើ ដោយអក្សរខ្មែរថា "គណៈកម្មការមូលបត្រកម្ពុជា" និងព័ទ្ធរង្វង់នៅផ្នែក ខាងក្រោមដោយអក្សរអង់គ្លេសថា "SECURITIES AND EXCHANGE COMMISSION OF CAMBODIA" ។

### ២.២.១.២ អត្ថន័យនៃរូបសញ្ញា

- រូបហង្សមានពណ៌មាស តំណាងឱ្យអាជ្ញាធរហិរញ្ញវត្ថុ ដែលជាអ្នកត្រួតពិនិត្យ និងគ្រប់គ្រងប្រតិបត្តិការមូលបត្រ និងធានាឱ្យដំណើរការទីផ្សារមូលបត្រប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបរង្វង់ថាសដែលពាក់កណ្តាលមានពណ៌មាស និងពាក់កណ្តាលទៀតមានពណ៌ប្រផេះ ដែលតំណាងឱ្យ ភាពចំណេញខាត ឬភាពឡើងចុះនៃដំណើរការទីផ្សារ។
- រូបហង្សពណ៌មាសឈរលើរង្វង់ថាសដែលមានជើងម្ខាងជាន់លើផ្ទៃពណ៌មាស និងជើងម្ខាងទៀតជាន់លើផ្ទៃ ពណ៌ប្រផេះ ចង់បង្ហាញថាភាពចំណេញខាត ឬភាពឡើងចុះនៃកិច្ចដំណើរការទីផ្សារស្ថិតនៅក្រោមការត្រួត ពិនិត្យ និងគ្រប់គ្រងរបស់អាជ្ញាធរជាគណៈកម្មការមូលបត្រកម្ពុជា ប្រកបដោយប្រសិទ្ធភាព មានសណ្តាប់ធ្នាប់ និងតម្លាភាព។
- រូបស្លឹកឈើ តំណាងឱ្យលទ្ធផលជាផ្លែផ្កានៃការចូលរួមចំណែករបស់វិស័យមូលបត្រក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ២.២.១.៣ មូលហេតុនៃជម្រើសយករូបហង្សពណ៌មាសជានិមិត្តសញ្ញា

- រូបហង្សពណ៌មាសជាប់ពាក់ព័ន្ធទៅនឹងដំណើរការវិវឌ្ឍនៃរូបិយវត្ថុរបស់ខ្មែរ ដោយរូបនេះត្រូវបានប្រើប្រាស់ ជាលើកដំបូងនៅលើប្រាក់ប្រាសាទ ក្នុងរជ្ជកាលព្រះបាទអង្គឌួង ដើម្បីរំលឹកដល់លោក សំអាង ហង្ស ដែល ព្រះបាទអង្គឌួងបញ្ជូនឱ្យទៅសិក្សាវិជ្ជាបោះផ្សាយប្រាក់នៅបរទេស ហើយលោកបានរួមចំណែកយ៉ាងខ្លាំងក្នុងការធ្វើឱ្យរូបិយវត្ថុខ្មែរមានអត្តសញ្ញាណច្បាស់លាស់ និងដាក់ឱ្យចរាចរក្នុងសេដ្ឋកិច្ច។
- រូបហង្សពណ៌មាសនេះ ជារូបសញ្ញាតំណាងឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនាសម័យសង្គមរាស្ត្រនិយម សម័យសាធារណរដ្ឋ និងក្នុងសម័យព្រះរាជាណាចក្រកម្ពុជាទី២ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលការណ៍នេះ ត្រូវគ្នានឹងគណៈកម្មការមូលបត្រកម្ពុជា ដែលជាអាជ្ញាធរហិរញ្ញវត្ថុមួយ ហើយមានប្រធានជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគឺឯកឧត្តមឧបនាយករដ្ឋមន្ត្រី គាត ឈន់។

### ២.២.២ ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា



ត្រារបស់គណៈកម្មការមូលបត្រកម្ពុជា មានលក្ខណៈប្រហាក់ប្រហែលនឹងត្រាមូលរបស់អាជ្ញាធរ ឬស្ថាប័នរដ្ឋដទៃទៀតដែរ ដោយនៅកន្លែងរង្វង់មូលផ្នែកខាងលើមានអក្សរសរសេរថា "ព្រះរាជាណាចក្រកម្ពុជា" ផ្នែកកណ្តាលមានសញ្ញា ប្រាសាទអង្គរវត្ត និងផ្នែកខាងក្រោមមានអក្សរសរសេរថា"គណៈកម្មការមូលបត្រកម្ពុជា "។

## ២.៣.ចក្ខុវិស័យរបស់គណៈកម្មការមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា ហៅកាត់ (គ.ម.ក) មានគោលដៅគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅកម្ពុជា កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតិជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់និងទូទាត់ ប្រតិបត្តិកររក្សាទុកមូលបត្រ។ កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្របង្កើត និងរក្សាទំនុកចិត្តដល់អ្នកវិនិយោគ ជួយដោះស្រាយវិវាទនានា ដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ បង្ការនិងដាក់ទណ្ឌកម្មចំពោះបទល្មើសដែលផ្តល់ផលប៉ះពាល់ដល់ទីផ្សារមូលបត្រ និងអ្នកវិនិយោគ។

## ២.៤. បេសកកម្ម ឬគោលបំណងរបស់គណៈកម្មការមូលបត្រ

ដើម្បីអាចគ្រប់គ្រងលើវិស័យមូលបត្របាន ប្រកបដោយប្រសិទ្ធភាព គណៈកម្មការមូល-បត្រមូលបត្រកម្ពុជាដែលជាអាជ្ញាធរ មានបេសកកម្មសំខាន់ដូចជា៖

- បង្កើត និងរក្សាឱ្យមាននូវទំនុកចិត្តពីសំណាក់អ្នកវិនិយោគ នៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការការពារសិទ្ធិស្របច្បាប់របស់វិនិយោគិន និងធានាឱ្យមានការបោះផ្សាយ។

- លើកកម្ពស់ការគ្រប់គ្រងលើវិស័យមូលបត្រឱ្យមានប្រសិទ្ធភាព និងជំរុញការអភិវឌ្ឍទីផ្សារនេះឱ្យមានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយ។
- ជំរុញឱ្យមានភាពសម្បូរបែបនៃឧបករណ៍សញ្ញ័យ តាមរយៈការទិញមូលបត្រ និងឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត។
- ជួយជំរុញឱ្យមានការវិនិយោគពីបរទេស និងការចូលរួមក្នុងទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ជួយសម្រួលដល់ការជួញដូរឱ្យប្រកបដោយសណ្តាប់ធ្នាប់ និងភាពត្រឹមត្រូវ។
- ជួយសម្រួលដល់ការធ្វើឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៥. មុខងារ និងការគ្រប់គ្រងរបស់គណៈកម្មការមូលបត្រ

### ២.៥.១ មុខងាររបស់គណៈកម្មការមូលបត្រ

គណៈកម្មការមូលបត្រកម្ពុជា ហៅកាត់ថា គ.ម.ក ជានិយ័តករគ្រប់គ្រងវិស័យមូលបត្រដែលមានមុខងារតួនាទី និងភារកិច្ចដូចជា៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរួមទាំងទីផ្សារមូលបត្ររដ្ឋ។
- ដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលពាក់ព័ន្ធទីផ្សារមូលបត្រ។
- កំណត់លក្ខខណ្ឌ ដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់។
- ដើរតួនាទីជាស្ថាប័នត្រួតពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាបណ្ណ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកអ្នកចូលរួម និងវិនិយោគិន។
- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខខណ្ឌសម្បត្តិសមស្រប ដើម្បីបង្កើតការអនុវត្តគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជា។
- បំពេញលក្ខខណ្ឌផ្សេងៗទៀតដែលមានចែងក្នុងអនុក្រឹត្យ។

## ២.៥.២.តួនាទី និងភារកិច្ចនៃនាយកដ្ឋាននីមួយៗ

គ.ម.ក.មាននាយកដ្ឋានចំណុះចំនួន ០៦(ប្រាំមួយ)ដែលត្រូវគ្រប់គ្រង ដោយអគ្គនាយកនៃ គ.ម. ក មានដូចជា៖

### ២.៥.២.១. អង្គភាពសវនកម្មផ្ទៃក្នុង

គ.ម.ក មានអង្គភាពសវនកម្មផ្ទៃក្នុងមួយដែលនៅបិតក្រោមការដឹកនាំផ្ទាល់របស់ ប្រធាន គ.ម.ក។

❖ **អង្គភាពសវនកម្មផ្ទៃក្នុងមានមុខងារ និងតួនាទីដូចតទៅ៖**

- ពិនិត្យលើមុខងារ និងសកម្មភាព កម្មវិធី និងប្រតិបត្តិការនានារបស់ គ.ម.ក ក្នុងការិយបរិច្ឆេទសមស្រប ដើម្បីកំណត់ការអនុវត្តឱ្យបានសមស្របតាមការរៀបចំផែនការ ការចេញបទបញ្ជា និងបទប្បញ្ញត្តិផ្សេងៗ ការចាត់តាំងការងារ និងការត្រួតពិនិត្យដោយផ្អែកតាមគោលនយោបាយ ការណែនាំរបស់ថ្នាក់ដឹកនាំ និងនីតិវិធីជាធរមាន និងសមស្របតាមដៅរបស់ គ.ម.ក។
- កំណត់ភាពសមស្រប និងប្រសិទ្ធភាពប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងគណនេយ្យ រដ្ឋបាល និងប្រតិបត្តិការនានារបស់ គ.ម.ក។
- ពិនិត្យលើភាពអាចជឿជាក់បាន និងភាពពេញលេញនៃព័ត៌មាន ទិនន្ន័យ និងវិធីសាស្ត្រនៃការរៀបចំរបាយការណ៍។
- ពិនិត្យលើប្រព័ន្ធដែលបានបង្កើតរួច ដើម្បីធានាភាពត្រឹមត្រូវតាមគោលការណ៍នយោបាយផែនការ នីតិវិធីច្បាប់ និងបទប្បញ្ញត្តិនានា ហើយលើកសំណើកែតម្រូវ និងកែលំអរប្រសិនបើមានកំហុស។
- ពិនិត្យលើមធ្យោបាយក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ គ.ម.ក។
- វាយតម្លៃភាពសន្សំសំចៃ និងប្រសិទ្ធភាពសេដ្ឋកិច្ច នៃការប្រើប្រាស់ធនធានរបស់ គ.ម.ក ហើយលើកសំណើដោះស្រាយ និងកែលំអការអនុវត្តប្រតិបត្តិការ។
- ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការចំណាយ ចំណូលថវិការបស់ គ.ម.ក. ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ។
- ធ្វើរបាយការណ៍សវនកម្មជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃ គ.ម.ក. អំពីការប្រព្រឹត្តទៅរបស់នាយកដ្ឋាន ឬអង្គភាពដែលបានធ្វើសវនកម្មរួចហើយ។

- ធ្វើរបាយការណ៍អំពីសកម្មភាពការងាររបស់ខ្លួន ប្រចាំត្រីមាស និងប្រចាំឆ្នាំ ដើម្បីផ្ញើជូនប្រធាន និងសមាជិកនៃគ.ម.ក. ពិនិត្យ និងផ្តល់ការណែនាំ។
- ធ្វើសវនកម្មផ្ទៃក្នុង នៅពេលដែលមានការណែនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធាននៃគ.ម.ក។
- រៀបចំផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ ដើម្បីដាក់ជូនប្រធាន និងសមាជិកនៃ គ.ម.ក ពិនិត្យ និង សម្រេច។
- សម្របសម្រួលការងារសវនកម្មផ្ទៃក្នុង ជាមួយនឹងអាជ្ញាធរសវនកម្មជាតិ ដើម្បីធានាដំណើរការឲ្យបានគ្រប់គ្រាន់ និងសមស្រប ជាពិសេសកាត់បន្ថយការងារស្ទួនគ្នា។

### ២.៥.២.២. នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ




❖ **នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមានមុខងារនិងតួនាទីដូចជា៖**

- រៀបចំផែនការ និងថវិការបស់ គ.ម.ក
- គ្រប់គ្រងកិច្ចការរដ្ឋបាល
- ផ្គត់ផ្គង់ និងជួសជុលសំភារៈបរិក្ខារការិយាល័យ
- ចាត់ចែងការងារពិធីការ
- ធ្វើការទំនាក់ទំនងជាមួយស្ថាប័នរដ្ឋ និងឯកជននានា
- រៀបចំគោលនយោបាយគ្រប់គ្រង និងជ្រើសរើសបុគ្គលិក
- រៀបចំតារាងប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភនានាដល់មន្ត្រីនៃ គ.ម.ក.
- គ្រប់គ្រង និងផ្តល់សេវាកម្មបច្ចេកវិទ្យាព័ត៌មាន

### ២.៥.២.៣. នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រ




❖ **នាយកដ្ឋានគ្រប់គ្រងការបោះផ្សាយលក់មូលបត្រមានមុខងារនិងតួនាទីដូចជា៖**

- រៀបចំលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយមូលបត្រជា សាធារណៈ។
- រៀបចំលក្ខខណ្ឌតម្រូវនានា ទាក់ទងនឹងអភិបាលកិច្ច និងការគ្រប់គ្រងក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈជាប្រចាំ។
- ត្រួតពិនិត្យការអនុវត្តន៍តាមស្តង់ដារ គណនេយ្យ និងសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសា-ធារណៈ។
- ត្រួតពិនិត្យ និងផ្តល់យោបល់ ក្នុងការស្នើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ពិនិត្យ និងផ្តល់យោបល់ក្នុងការស្នើសុំចុះបញ្ជី ឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ។
- ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម និងសេចក្តីថ្លែងនានារបស់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- ពិនិត្យ និងផ្សព្វផ្សាយឯកសារផ្តល់ព័ត៌មាន ឯកសារផ្តល់ព័ត៌មានបន្ថែម ឯកសារផ្តល់ព័ត៌មានជំនួស និងសេចក្តីថ្លែងនានាដែលពាក់ព័ន្ធនឹងធុរកិច្ចមូលបត្រ តាមប្រព័ន្ធអេឡិចត្រូនិក ឬ/និង តាមប្រព័ន្ធផ្សព្វផ្សាយសាធារណៈ។

- ត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុ ឬ/និង របាយការណ៍អាជីវកម្មរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រលក់ជាសាធារណៈ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែង របស់ក្រុមហ៊ុនស្នើសុំបោះផ្សាយមូលបត្រជាសាធារណៈ ប្រសិនបើមាន ការចាំបាច់ស្របតាមក្របខ័ណ្ឌការងារ។
- គ្រប់គ្រងយន្តការបោះផ្សាយលក់មូលបត្រជាសាធារណៈ។
- បញ្ជូនសំណុំរឿងសង្ស័យថាមានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងការបោះផ្សាយលក់ មូលបត្រជាសាធារណៈ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត។

**២.៥.២.៤. នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ**




❖ **នាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រមានមុខងារ និងតួនាទីដូចជា៖**

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានា សម្រាប់ផ្តល់ការអនុញ្ញាតឱ្យធ្វើជាប្រតិបត្តិការជាមួយប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការពិនិត្យ និងអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក ។
- ពិនិត្យ និងផ្តល់យោបល់លើពាក្យស្នើសុំការអនុញ្ញាត ដើម្បីធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- ត្រួតពិនិត្យ និងតាមដានលើការផ្គត់ផ្គង់ប្រព័ន្ធជួញដូរមូលបត្រ និងប្រតិបត្តិករផ្សេងៗទៀតរបស់ប្រតិបត្តិករទីផ្សារមូលបត្រ។

- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការរបស់ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់។
- ត្រួតពិនិត្យ និងតាមដានលើប្រតិបត្តិការ នៃប្រតិបត្តិកររក្សាទុកមូលបត្រ
- ត្រួតពិនិត្យជាក់ស្តែងដល់ទីកន្លែងតាមការចាំបាច់ ចំពោះប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ។
- បញ្ជូនសំណុំរឿងសង្ស័យថា មានការប្រព្រឹត្តល្មើសនឹងច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធនឹងប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ទៅនាយកដ្ឋានកិច្ចការគតិយុត្ត ដើម្បីធ្វើការស៊ើបអង្កេតបន្ត។

### ២.៥.២.៥. នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ




❖ **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិមានមុខងារនិងតួនាទីដូចតទៅៈ**

- សិក្សាស្រាវជ្រាវពីយុទ្ធសាស្ត្រនានា ដើម្បីអភិវឌ្ឍន៍វិស័យមូលបត្រនៃព្រះរាជាណាចក្រកម្ពុជាសិក្សាស្រាវជ្រាវលើការអភិវឌ្ឍ។

- សិក្សាស្រាវជ្រាវលើការអភិវឌ្ឍរចនាសម្ព័ន្ធច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍវិស័យមូលបត្រ។
- គ្រប់គ្រង និង ការអភិវឌ្ឍវិស័យមូលបត្រ រៀបចំយុទ្ធសាស្ត្រដើម្បីជំរុញឱ្យក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ សិក្សាវាយតម្លៃ និងផ្តល់យោបល់។
- សិក្សាវាយតម្លៃ និងផ្តល់យោបល់លើការបង្កើតឧបករណ៍ហិរញ្ញវត្ថុថ្មីមុននឹងអនុញ្ញាតឱ្យបោះផ្សាយលើទីផ្សារ។
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណជន និងអ្នកចូលរួមនានាក្នុងវិស័យមូលបត្រ។
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់សាធារណៈ បណ្តាប្រទេសក្នុងតំបន់ និងនៅលើពិភពលោក។
- ចូលរួមក្នុងវេទិកាជាតិ និងអន្តរជាតិពាក់ព័ន្ធនានា។

**២.៥.២.៦. នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ**




❖ **នាយកដ្ឋានអន្តរការីមូលបត្រមានមុខងារ និងតួនាទីដូចជា៖**

- រៀបចំបទប្បញ្ញត្តិ ឬលក្ខខណ្ឌតម្រូវនានាសម្រាប់ផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារដើម្បីដាក់ពាក្យសុំការពិនិត្យ និង សម្រេចពីអគ្គនាយកនៃ គ.ម.ក។

- ពិនិត្យ និងផ្តល់យោបល់លើសំណើសុំអាជ្ញាបណ្ណ ដើម្បីធ្វើជាក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ។
- ត្រួតពិនិត្យ និងតាមដាននូវប្រតិបត្តិការរបស់ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ។
- ត្រួតពិនិត្យដល់ទីកន្លែងតាមការចាំបាច់ នូវប្រតិបត្តិការរបស់ ក្រុមហ៊ុនមូលបត្រភ្នាក់ងារក្រុមហ៊ុនមូលបត្រ ទីប្រឹក្សាវិនិយោគ ពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ អ្នកគ្រប់គ្រងមូលនិធិ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារ។

### ២.៥.២.៧. នាយកដ្ឋានកិច្ចការគតិយុត្ត




❖ **នាយកដ្ឋានកិច្ចការគតិយុត្តមានមុខងារនិងតួនាទីដូចតទៅ៖**

- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ដើម្បីដាក់សុំការពិនិត្យ និងសេចក្តីសម្រេចពីអគ្គនាយកនៃ គ.ម.ក។
- ពិនិត្យ និងផ្តល់យោបល់លើវិធានប្រតិបត្តិការ ដែលស្នើដោយស្ថាប័នស្វ័យនិយ័តករ។
- រៀបចំបទប្បញ្ញត្តិចាំបាច់នានា និងលើកសំណើធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យមូលបត្រ។

- ពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងវិស័យមូលបត្រ។
- ទទួលបណ្តឹង និងធ្វើការស៊ើបអង្កេតពាក់ព័ន្ធនឹងប្រតិបត្តិករបោះផ្សាយ និងជួញដូរមូលបត្រដែលល្មើសនឹងច្បាប់ ឬមិនប្រក្រតី ទាំងនៅក្នុងទីផ្សារដំបូង និងនៅទីផ្សារបន្ទាប់។
- ពិនិត្យ និងផ្តល់យោបល់ ដើម្បីចាត់វិធានការការដាក់ពិន័យនានាពាក់ព័ន្ធនឹងបុគ្គលល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ។
- សម្រុះសម្រួលដោះស្រាយវិវាទអ្នកចូលរួមក្នុងទីផ្សារមូលបត្រ។
- ចាត់វិធានការផាកពិន័យអន្តរការណ៍ លើបុគ្គលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិនានាដែលពាក់ពាព័ន្ធនឹង វិស័យមូលបត្រ។
- រៀបចំសំណុំរឿងពាក់ព័ន្ធដើម្បីដាក់ពាក្យបណ្តឹងទៅតុលាការ។

### ២.៥.៣. ប្រភពធនធាន និងការគ្រប់គ្រងហិរញ្ញវត្ថុ

ប្រភពធនធាន និងថវិការបស់គណៈកម្មការមូលបត្រកម្ពុជារួមមាន៖

- ថវិការជាតិដែលផ្តល់ដោយគណៈកម្មការមូលបត្រកម្ពុជា
- ថ្លៃសេវានៃការផ្តល់អាជ្ញាបណ្ណ ដល់ក្រុមហ៊ុនមូលបត្រ ឬតំណាងក្រុមហ៊ុនមូលបត្រ ឬអ្នកចូលរួមផ្សេងទៀតក្នុទីផ្សារមូលបត្រ
- ថ្លៃសេវានៃការដាក់ពាក្យសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ
- ថ្លៃសេវានៃប្រតិបត្តិការជួញដូរមូលបត្រនៅក្នុងទីផ្សារមូលបត្រ និងចំណូលពីប្រតិបត្តិការផ្សេងទៀត ដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់គណៈកម្មការមូលបត្រកម្ពុជា។
- ប្រាក់ពិន័យអន្តរការណ៍លើបុគ្គលដែលប្រព្រឹត្តល្មើសច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធនឹងវិស័យមូលបត្រ។

## ២.៦. សមាសធាតុរបស់គណៈកម្មការមូលបត្រកម្ពុជា

គ.ម.ក ចែកចេញជាពីរ៖

- រចនាសម្ព័ន្ធថ្នាក់ដឹកនាំ (គ.ម.ក និងអគ្គនាយកនៃ គ.ម.ក)
- រចនាសម្ព័ន្ធបច្ចេកទេស (នាយកដ្ឋាន អង្គភាពនៃ គ.ម.ក)

### ២.៦.១. អង្គការចាត់តាំងរបស់គ.ម.ក

យោងតាមអនុក្រឹត និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋាននៃគណៈកម្មការមូលបត្រកម្ពុជា៖

- នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋានត្រួតពិនិត្យការបោះផ្សាយលក់មូលបត្រ
- នាយកដ្ឋានត្រួតពិនិត្យផ្សារមូលបត្រ
- នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ
- នាយកដ្ឋានត្រួតពិនិត្យអន្តរការី
- នាយកដ្ឋានកិច្ចការគតិយុត្ត

### ២.៦.២. រចនាសម្ព័ន្ធចាត់តាំងរបស់ គ.ម.ក




គ.ម.ក មានសមាសភាព ០៩រូប តែងតាំងដោយអនុក្រឹត្យ ដែលក្នុងនោះមានប្រធា ០១រូបជារដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសមាជិក ០៨រូប៖

- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (១រូប)
- តំណាងធនាគារជាតិ (១រូប)
- តំណាងក្រសួងពាណិជ្ជកម្ម (១រូប)
- តំណាងក្រសួងកយុត្តិធម៌ (១រូប)
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី (១រូប)
- អគ្គនាយកនៃ គ.ម.ក (១រូប)
- អ្នកជំនាញខាងវិស័យមូលបត្រ (២រូប)

សមាជិករបស់ គ.ម.ក មានអាណត្តិ ៥ឆ្នាំ។ សមាជិក គ.ម.ក អាចត្រូវដកតំណែង ឬត្រូវផ្លាស់ប្តូរភារកិច្ចមុនផុតអាណត្តិ ឬអាចត្រូវតែងតាំងសារជាថ្មីតាមសំណើរបស់ប្រធាន គ.ម.ក។

**រចនាសម្ព័ន្ធចាត់តាំងរបស់ គ.ម.ក**



# ជំពូកទី៣
# ការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រ មានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។ អាជ្ញាបណ្ណដែលសុំបន្តដោយក្រុមហ៊ុនមូលបត្រ មានសុពលភាព ០៣ (បី) ឆ្នាំ ចាប់គិតពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។ គ.ម.កបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងកិច្ចដំណើរការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ គឺថាមុនផ្តល់ត្រូវធ្វើឡើងដោយប្រុង-ប្រយ័ត្ន និងមានច្រើនដំណាក់កាលគឺដើម្បីជ្រើសរើសបានពេញបានតាមលក្ខខណ្ឌតម្រូវរបស់គ.ម.ក។

## ៣.១. កិច្ចដំណើរការនៃការស្នើសុំអាជ្ញាបណ្ណ

បុគ្គលដែលមានបំណងធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនៅគ.ម.ក ទៅតាមទម្រង់បែបបទដែលបានកំណត់ ក្នុងរយៈពេលយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ។ ដើម្បីទទួលបានអាជ្ញាដំបូងក្រុមហ៊ុនគួរត្រៀមខ្លួនជាមុន គឺក្រុមហ៊ុនត្រូវរៀបចំឱ្យបុគ្គលិកក្រុមហ៊ុនមួយចំនួន និងប្រធានភ្នាក់ងារ ត្រូវមានគុណវឌ្ឍិ បន្ទាប់មកត្រូវបំពេញស្នើសុំដោយភ្ជាប់មកជាមួយឯកសារផងដែលតម្រូវដោយ គ.ម.ក។ បន្ទាប់មកទៀត គ.ម.ក ធ្វើការសិក្សាវាយតម្លៃ ហើយតមកទៀតគឺមានការសុំអនុញ្ញាតចុះដល់ទីកន្លែងដើម្បីត្រួតពិនិត្យ នឹងអាចសុំឯកសារបន្ថែមករណីដែលខាងក្រុមហ៊ុនផ្តល់ឱ្យមកខាង គ.ម.ក មានការខ្វះខាត។ ដំណាក់កាលបន្ទាប់ គ.ម.ក ចេញលិខិតអនុញ្ញាតលើគោលការណ៍ស្នើសុំ។ បន្តមកក្រុមហ៊ុនត្រូវបង់ថ្លៃសោហ៊ុយលើអាជ្ញាបណ្ណ និងឯកសារដែលផ្តល់មកមិនគ្រប់គ្រាន់តាមលក្ខខណ្ឌ។ ក្រោយពី គ.ម.ក ធ្វើការត្រួតពិនិត្យរួចរាល់ហើយ គ.ម.កការសម្រេចចិត្តផ្តល់អាជ្ញាបណ្ណ។

## ៣.២. លក្ខខណ្ឌតម្រូវក្នុងការផ្តល់អាជ្ញាបណ្ណ

ក្រុមហ៊ុនដែលមានបំណងចង់ធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ លុះត្រាណាតែជាក្រុមហ៊ុនដែលបង្កើតឡើងស្របតាមច្បាប់នៅកម្ពុជា ហើយមានអភិបាល ឬសហកម្មសិទ្ធិករ និងនិយោជិតគ្រប់រូបមានលក្ខណសម្បត្តិ និងអត្តចរិតល្អ។ មួយវិញទៀតអភិបាល ឬសហកម្មសិទ្ធិករម្នាក់ និងនិយោជិតម្នាក់ត្រូវមានគុណវិឌ្ឍិធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ។ គ្មានបុគ្គលម្នាក់ណាអាចបើកអាជីវកម្មមូលបត្របាន លុះត្រាណាតែបុគ្គលនោះទទួលបានការផ្តល់អាជ្ញាបណ្ណពីគ.ម.ក. ឱ្យធ្វើជាក្រុមហ៊ុនមូលបត្រ។

ការដាក់ពាក្យស្នើសុំអាជ្ញាបុគ្គលអាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ដើម្បីស្នើសុំធ្វើអាជីវកម្មមូលបត្រ ទៅគ.ម.ក. តាមទម្រង់បែបបទនិងបង់ថ្លៃសេវាដែលបានកំណត់របស់គ.ម.ក. ។ មួយទៀតនោះអគ្គនាយកអាច អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណផ្តល់ព័ត៌មានបន្ថែមតាមការចាំបាច់ និងអាចមិនពិនិត្យលើពាក្យស្នើសុំរហូតដល់អ្នកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណបានផ្តល់ ព័ត៌មានគ្រប់គ្រាន់។

ការពិនិត្យ និងសម្រេចចិត្តលើពាក្យស្នើសុំអាជ្ញាបណ្ណ ត្រូវអនុវត្តដូចខាងក្រោម៖[8]

- អគ្គនាយកនៃគ.ម.កអាចផ្តល់អាជ្ញាបណ្ណដល់អ្នកដាក់ពាក្យស្នើសុំ ដើម្បីធ្វើអាជីវកម្មមូលបត្របាន ករណីពាក្យបំពេញតាមលក្ខខណ្ឌ ដែលបានកំណត់ដោយគ.ម.ក. ។ នៅក្នុងរយៈពេលដែលអាជ្ញាបណ្ណមានសុពលភាព ប្រសិនបើលក្ខខណ្ឌដែលបានកំណត់មានការប្រែប្រួល អ្នកដាក់ពាក្យដែលទទួលបានអាជ្ញាបណ្ណរួចហើយត្រូវបន្តបំពេញតាមលក្ខខណ្ឌប្រែប្រួលនោះ។
- អគ្គនាយកនៃគ.ម.ក. មិនត្រូវបដិសេធក្នុងការផ្តល់អាជ្ញាបណ្ណជូនអ្នកដាក់ពាក្យស្នើសុំដោយមិនបញ្ជាក់ពីមូលហេតុជាលាយលក្ខណ៍ជាមុន និងដោយមិនទុកឱកាសឱ្យអ្នកស្នើសុំមានការពន្យល់ឡើយ។
- ប្រសិនបើអគ្គនាយកនៃគ.ម.ក. ផ្តល់អាជ្ញាបណ្ណជូនដល់អ្នកស្នើសុំ នោះអាជ្ញាបណ្ណនោះគឺស្ថិតនៅក្រោមបទប្បញ្ញត្តិ នឹងលក្ខខណ្ឌដែលបានកំណត់ដោយគ.ម.ក. ឬស្ថិតនៅក្រោមកំហិតណាមួយតាមការចាំបាច់ រួមទាងលក្ខខណ្ឌដែលបានដាក់កំហិតលើអាជីវកម្មដែលបានចែងក្នុងអាជ្ញាបណ្ណ ហើយនៅក្នុងរយៈពេលដែលអាជ្ញាបណ្ណមានសុពលភាព អគ្គនាយកអាចកំណត់លក្ខខណ្ឌ កែប្រែ ឬដកលក្ខខណ្ឌណាមួយវិញក្រោយទទួលបានការសម្រេចរបស់គ.ម.ក.។

ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ [9]

វិធានការចំពោះអ្នកកាន់អាជ្ញាបណ្ណមានដូចជា៖

- ក្រោយពេលផ្តល់អាជ្ញា ប្រសិនបើអគ្គនាយកពិនិត្យឃើញថា អ្នកកាន់អាជ្ញាបណ្ណមានបំពានលក្ខខណ្ឌណាមួយនៃអាជ្ញាបណ្ណ ឬលក្ខខណ្ឌដែលបានកំណត់ក្នុងបទប្បញ្ញត្តិដោយអនុលោមដោយច្បាប់ អគ្គនាយកអាចចាត់វិធានការ

[8] ឧបសម្ព័ន្ធ

[9] ឧបសម្ព័ន្ធ

- ដឹងនាំកែតម្រូវទៅលើអ្នកកាន់អាជ្ញាបណ្ណ
- ដាក់កំហិតលើអាជ្ញាបណ្ណ
- ព្យួរអាជ្ញាបណ្ណ រហូតដល់បានបំពេញ និងគោរពតាមលក្ខខណ្ឌបានពេញលេញ
- អាចដល់ការដកហូរអាជ្ញាបណ្ណមកវិញ

❖ អគ្គនាយកនឹងផ្តល់មូលហេតុ ហើយក៏នៅតែទុកឱកាស ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើការពន្យល់។

### ៣.២.១. លក្ខខណ្ឌបរិមាណ

#### ៣.២.១.១. ក្រុមហ៊ុនធានាទិញមូលបត្រ

ដើម្បីក្លាយជាក្រុមហ៊ុនធានាទិញបាន ក្រុមហ៊ុនត្រូវមានមូលធនអប្បបរមា ៤០ ពាន់លានរៀល មូលធនសុទ្ធអប្បបរមា ២ ពាន់លានរៀល និងប្រាក់តម្កល់ធានាអាជីវកម្មនៅធនាគារជាតិ ១០% ស្មើនឹង ៤ ពាន់លានរៀល។

#### ៣.២.១.២. ក្រុមហ៊ុនជួញដូរមូលបត្រ

ដើម្បីក្លាយជាក្រុមហ៊ុនជួញដូរបាន បុគ្គលស្នើសុំត្រូវមានមូលធនអប្បបរមា ២៥ ពាន់លានរៀល មូលធនសុទ្ធអប្បបរមា ១,២៥ ពាន់លានរៀល និងប្រាក់តម្កល់ធានាអាជីវកម្មនៅធនាគារជាតិ ១០% ស្មើនឹង ២,៥ ពាន់លានរៀល ។

#### ៣.២.១.៣. ក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ

ដើម្បីក្លាយជាក្រុមហ៊ុនឈ្មួញជើងសា បុគ្គលស្នើសុំត្រូវមានមូលធនអប្បបរមា ៦ពាន់លានរៀល មូលធនសុទ្ធអប្បបរមា ៣០០ លានរៀល និងប្រាក់តម្កល់ធានាអាជីវកម្មនៅធនាគារជាតិ

១ពាន់លាន ។

#### ៣.២.១.៤. ក្រុមហ៊ុនផ្តល់ប្រឹក្សាយោបល់

ដើម្បីក្លាយជាក្រុមហ៊ុនផ្តល់ប្រឹក្សាយោបល់ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមា ៤០០លានរៀល និងតម្កល់ប្រាក់នៅធានាជាតិ ២០%។

### ៣.២.២. លក្ខខណ្ឌគុណភាព

តម្រូវការធនធាន៖

– យ៉ាងហោចណាស់នាយកប្រតិបត្តិ និងអភិបាល ឬសហាកម្មសិទ្ធិករ

- មានចំណេះដឹង ឬបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ឬវិស័យហិរញ្ញវត្ថុយ៉ាងតិច៣ ឆ្នាំ
- មានគុណវឌ្ឍិគ្រប់គ្រាន់ដើម្បីទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ

– យ៉ាងហោចណាស់ប្រធានភ្នាក់ងារមូលបត្រមួយរូប
  - មានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មក្នុងវិស័យហិរញ្ញវត្ថុយ៉ាងតិច ៣ឆ្នាំ
  - មានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ
– ប្រធានប្រតិបត្តិការ
  - ធ្លាប់កាន់តំណែងគ្រប់គ្រងជាន់ខ្ពស់រយៈពេលយ៉ាងតិច ២ ឆ្នាំ
  - ធ្លាប់កាន់តំណែងគ្រប់គ្រងថ្នាក់កណ្ដាលរយៈពេលយ៉ាងតិច ៣ ឆ្នាំ
  - ធ្លាប់ជាអ្នកចូលរួមក្នុងទីផ្សារមូលបត្ររយៈពេលយ៉ាងតិច ៣ ឆ្នាំ
  - ចូលរួមវគ្គបណ្ដុះបណ្ដាល និងការប្រលងដែលរៀបចំដោយគ.ម.ក
– ត្រូវមានបុគ្គលិកជំនាញផ្នែកច្បាប់
  - សញ្ញាបត្រយ៉ាងតិចកម្រិតឧត្ដមសិក្សាផ្នែកច្បាប់ ឬលិខិតបញ្ជាក់វិជ្ជាជីវៈផ្នែកច្បាប់
  - បទពិសោធន៍ក្នុងវិស័យហិរញ្ញវត្ថុយ៉ាងតិច ៣ ឆ្នាំ
  - ចូលរួមវគ្គបណ្ដុះបណ្ដាល និងការប្រលងដែលរៀបចំដោយគ.ម.ក
– ត្រូវមានបុគ្គលិកជំនាញទៅតាមទំហំនៃប្រភេទអាជីវកម្មនីមួយៗ
– និងត្រូវមានបុគ្គលិកដែលមានគុណវុឌ្ឍិមួយចំនួនទៀត

តម្រូវការផ្សេងៗទៀតដូចជាក្រុមហ៊ុនត្រូវមាននូវប្រព័ន្ធ ឧបករណ៍ សម្ភារៈ ជារូបវន្តផែនអាជីវកម្មរយៈពេល ៣ឆ្នាំ ផែនការគ្រប់ក្រងហានិភ័យ និងលក្ខខណ្ឌផ្សេងៗទៀតដែលមានចែងក្នុងប្រកាសស្ដីពី ការផ្ដល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

– ប្រព័ន្ធកុំព្យូទ័រសម្រាប់អាជីវកម្មដែលមិនមានវិសមភាពជាមួយប្រព័ន្ធកុំព្យូទ័ររបស់ប្រតិបត្តិករទីផ្សារមូលបត្រ
– ប្រព័ន្ធកុំព្យូទ័រសម្រាប់ការគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុង
– តំឡើងប្រព័ន្ធទ្រទ្រង់ និងប្រព័ន្ធដែលអាចការពារលើសហួសសម្ថតភាព ឬការខូចប្រព័ន្ធ

- លក្ខខណ្ឌនៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង
- មានអគារ និងបរិវេណ និងបំពាក់ឧបករណ៍គ្រប់គ្រាន់ ឬមានភស្តុតាងដែលអាចទទួលយកបាន
- ផែនការអាជីវកម្មរយៈពេល ៣ឆ្នាំ
- ផែនការគ្រប់គ្រងហានិភ័យ
- បំពេញលក្ខខណ្ឌតម្រូវផ្សេងទៀតដូចមានចែងក្នុងមាត្រា ៤០ នៃអនុក្រឹត និងប្រការ ១៧ នៃប្រកាស។

អាជ្ញាបណ្ណភ្នាក់ងារក្រុមហ៊ុនមូលបត្រ (មាត្រា ៤១នៃអនុក្រិត និងប្រការ ៣៣ នៃប្រកាស)

- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ
- ជានីតិជនដែលមានតាំងទីលំនៅកម្ពុជា
- ចូលរួមវគ្គបណ្តុះបណ្តាល និង/ ឬការប្រលងដែលរៀបចំដោយគ.ម.ក
- ផ្តល់លិខិតយល់ព្រមឱ្យធ្វើជាភ្នាក់ងារពីក្រុមហ៊ុនមូលបត្រមានគុណវុឌ្ឍិ
- សញ្ញាបត្រយ៉ាងតិចឧត្តមសិក្សាក្នុងជំនាញពាក់ព័ន្ធនឹងមូលបត្រ ឬហិរញ្ញវត្ថុ
- លិខិតបញ្ជាក់ជំនាញវិជ្ជាជីវៈពាក់ព័ន្ធនឹងមូលបត្រ ឬហិរញ្ញវត្ថុ និងបទពិសោធន៍យ៉ាង ៣ឆ្នាំក្នុងទីផ្សារហិរញ្ញវត្ថុ
- ធ្លាប់ទទួលបានអាជ្ញាបណ្ណ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងរយៈពេលយ៉ាងតិច ៣ ឆ្នាំ
- មិនធ្លាប់ធ្វើជាមន្ត្រី ឬសមាជិកនៃគ.ម.ក ឬបុគ្គលិកជាន់ខ្ពស់ ឬសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ប្រតិបត្តិករ ក្នុងរយៈពេល ២ ឆ្នាំចុងក្រោយ
- លក្ខខណ្ឌតម្រូវផ្សេងៗទៀត

### ៣.២.៣. តម្លៃក្នុងការផ្តល់អាជ្ញាបណ្ណ

ចំពោះក្រុមហ៊ុនមូលបត្រ តម្លៃស្នើសុំ ២លានរៀលនៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណតាមប្រភេទក្រុមហ៊ុនមូលបត្រ៖

❖ **ក្រុមហ៊ុនធានាទិញមូលបត្រ**

តម្លៃ ៨០ លានរៀលសម្រាប់ ២ឆ្នាំដំបូង និង១២០លានរៀលសម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល៣ឆ្នាំ។

❖ **ក្រុមហ៊ុនជួញដូរមូលបត្រ**

កម្រៃ ៦០ លានរៀលសម្រាប់ ២ឆ្នាំដំបូង និង៩០លានរៀលសម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល៣ឆ្នាំ។

- **ក្រុមហ៊ុនឈ្មួញជើងសារមូលបត្រ**

កម្រៃ ៤០ លានរៀលសម្រាប់ ២ឆ្នាំដំបូង និង៦០លានរៀលសម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល៣ឆ្នាំ។

- **ក្រុមហ៊ុនទីប្រឹក្សាមូលបត្រ**

កម្រៃ ១០ លានរៀលសម្រាប់ ២ឆ្នាំដំបូង និង១៥លានរៀលសម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល៣ឆ្នាំ។

ចំពោះតម្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតរបស់ក្រុមហ៊ុនដែលធ្វើអាជីវកម្មក្រុមហ៊ុនធានាទិញ ក្រុមហ៊ុនជួញដូរ និងជាក្រុមហ៊ុនឈ្មួញជើងសា ត្រូវបង់ ២ លានរៀល ចំណែកឯក្រុមហ៊ុនទីប្រឹក្សាវិនិយោគវិញត្រូវបង់ ១លានរៀល។

រាល់ថ្លៃពាក្យស្នើសុំ និងសាហ៊ុយសិក្សាសំណុំលិខិតមិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះជាអាជ្ញាបណ្ណបដិសេធមិនផ្តល់ឱ្យ ឬមិនបន្តឱ្យក៏ដោយ។

## ៣.៣. ការបដិសេធលើការស្នើសុំអាជ្ញាបណ្ណ

មូលហេតុនៃការបដិសេធ

- បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញនូវលក្ខខណ្ឌណាមួយដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀត ដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែល ពាក់ព័ន្ធផ្សេងទៀត។
- ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ គ.ម.ក. មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស
- បុគ្គលដាក់ពាក្យស្នើសុំ ស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។
- សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុលមិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។
- បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំ៖
- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ចឬមិនត្រឹមត្រូវដោយប្រការណាមួយ។
- បានប្រព្រឹត្តល្មើស និងច្បាប់ និងបទប្បញ្ញត្តិដែលការពារសាធារណជន ឱ្យចៀសផុតពី

ការខាងបង់ផ្នែកហិរញ្ញវត្ថុ

- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹត្យភាពនៃសេចក្តីសម្រេចរបស់ខ្លួន។
- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។
- ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌនៃការអនុញ្ញាតប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។
- អភិបាល ឬបុគ្គលជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុបរបស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។
- នៅពេលកើតមានហេតុការណាមួយដែលអាច ៖ នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំឬអភិ-បាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។
- ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ គ.ម.ក. មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យបុគ្គលពាក្យស្នើសុំធ្វើការពន្យល់។

ចំពោះក្រុមហ៊ុនមូលបត្រ (ប្រការ ២៨)

- មិនបានអនុវត្តទាំងស្រុង ឬមួយផ្នែកនូវសេចក្តីសម្រេចរបស់តុលាការឱ្យទូទាត់សងបំណុល
- មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- ការផ្តល់អាជ្ញាបណ្ណអាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ
- មូលហេតុផ្សេងៗដូចក្នុងប្រការ ២៨

## ៣.៤. ការត្រួតពិនិត្យមុនផ្តល់អាជ្ញាបណ្ណ

### ៣.៤.១.ភាពរឹងមាំនៃហិរញ្ញវត្ថុ

#### ៣.៤.១.១. លក្ខខណ្ឌតម្រូវមូលធនភាគហ៊ុនិក

មូលធនភាគហ៊ុនិក និងប្រាក់តម្កល់ធានាអាជីវកម្ម នឹង/ ឬឧបករណ៍តម្កល់ធានាអាជីវកម្ម មិនត្រូវតិចជាង ( ប្រការ ៤ និង ប្រការ៥)

ក្រុមហ៊ុនមូលបត្រមិនត្រូវប្រើប្រាស់ប្រាក់តម្កល់ធានាអាជីវកម្ម នឹង/ ឬឧបករណ៍តម្កល់ធានាអាជីវកម្មជាការធានាផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងអាជីវកម្ម លើកលែងតែការដកសម្រាប់ការប្រើប្រាស់ក្នុងគោលបំណងដូចមានកំណត់ក្នុងប្រកាសផ្តល់អាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រ និងមានការអនុញ្ញាតពី គ.ម.ក. ។ ( ប្រការ ៦)

ក្រុមហ៊ុនមូលបត្រមានកាតព្វកិច្ចជូនដំណឹងភ្លាមដល់អគ្គនាយកនៃ គ.ម.ក. ក្នុងករណីក្រុមហ៊ុនមិនអាចបំពេញ ឬដឹងថាមិនអាចបំពេញកាតព្វកិច្ចក្នុងប្រការ ៤ ៥ ៦ នៃប្រកាសនេះ។

#### ៣.៤.១.២. លក្ខខណ្ឌតម្រូវលើមូលធនសុទ្ធ

គណនាមូលធនសុទ្ធដូចមានកំណត់ក្នុងប្រការ ៩ រក្សាមូលធនសុទ្ធគ្រប់ពេលវេលាមិនឱ្យតិចជាងមូលធនសុទ្ធកាតព្វកិច្ច ត្រូវគោរពតាមអនុបាតមូលធនសុទ្ធដូចមានកំណត់ក្នុងប្រការ ១៧ ។ មួយវិញទៀតករណីដែលមិនគោរពតាមកាតព្វកិច្ចក្នុងប្រការនេះ ត្រូវជូនដំណឹងដល់អគ្គនាយកនសគ.ម.ក។

មូលធនសុទ្ធ = ទ្រព្យសកម្មរយៈពេលខ្លី - បំណុលក្រៅសរុប

#### ៣.៤.១.៣. កម្រិតមូលធនសុទ្ធកាតព្វកិច្ច

**ក្នុងប្រការទ១៧ កម្រិតមូលធនសុទ្ធកាតព្វកិច្ច និងអនុបាតមូលធនសុទ្ធ**

- កម្រិតមូលធនសុទ្ធកាតព្វកិច្ចរបស់ក្រុមហ៊ុនមូលបត្រ គឺជាចំនួនដែលខ្ពស់ជាងគេរវាង ៥% នៃមូលធនរចស់ភាគហ៊ុនិគ ឬផលបូកនៃ ១០% បំណុលសរុប និង ១០%នៃកាតព្វកិច្ចធានាទិញ និង/ឬកាតព្វកិច្ចធានាទិញបន្ត និង/ឬកាតព្វកិច្ចបំណុលលើការធ្វើបរិវិសកម្មរបស់វិនិយោគិនដែលជាអតិថិជនរបស់ក្រុមហ៊ុន។

អនុបាតមូលធនសុទ្ធ = មូលធនសុទ្ធ / កម្រិតមូលធនសុទ្ធកាតព្វកិច្ច

(Net Capital Ratio) (Net Capital ) (Prescribed Level of Net Capital)

- ក្រុមហ៊ុនមូលបត្រ ត្រូវរក្សារមូលធនសុទ្ធរបស់ខ្លួនឱ្យបានគ្រប់ពេលវេលាមិនឱ្យទាបជាងកម្រិតមូលធនសុទ្ធកាតព្វកិច្ច។

- ក្រុមហ៊ុនមូលបត្រ ត្រូវរក្សាអនុបាតមូលធនសុទ្ធរបស់ខ្លួន មិនឱ្យទាបជាង ១៥០%។

ក្នុងប្រការ១៨ កាតព្វកិច្ចរៀបចំរបាយការណ៍មូលធនសុទ្ធប្រចាំថ្ងៃ

ក្រុមហ៊ុនមូលបត្រត្រូវគណនា មូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចជាប្រចាំថ្ងៃ និងត្រូវផ្ញើជូនគ.ម.ក ជាប្រចាំថ្ងៃនូវរបាយការណ៍មូលធនសុទ្ធប្រចាំថ្ងៃតាមរយៈសារអេឡិចត្រូនិច ដែលកំណត់ដោយគ.ម.ក ។

- គ.ម.ក មានឆន្ទានុសិទ្ធិកែប្រែកម្រិតមូលធនសុទ្ធកាតព្វកិច្ច និងតម្រូវឱ្យក្រុមហ៊ុនមូលបត្របង្កើតមូលធនសុទ្ធ ដោយពិចារណាទៅលើកត្តាមួយចំនួនដូចប្រការ ១៩ ដោយមើលលើទ្រព្យសកម្មដែលមានលក្ខណៈអសន្ទនីយភាព ព័ត៌មានហានិភ័យ និងហានិភ័យផ្សេងៗ

### ៣.៤.១.៤. កាតព្វកិច្ចផ្តល់របាយការណ៍ស្ថានភាពមូលធនសុទ្ធ

អគ្គនាយកនៃ គ.ម.ក អាចតម្រូវឱ្យក្រុមង៊ុនមូលបត្រធ្វើការគណនា និងធ្វើរបាយការណ៍ស្ថានភាពមូលធនសុទ្ធ និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចគ្រប់ពេលវេលាទៅតាមការចាំបាច់។ ក្រុមហ៊ុនមូលបត្រត្រូវដាក់ជូនគ.ម.ក នូវរបាយការណ៍ដូចជា របាយការណ៍ប្រចាំខែ មានរបាយការណ៍តុល្យភាពសាកល្បងសង្ខេប ( Trail Balance in summary) និងរបាយកាណ៍សន្ទនីយភាព ( Liquidity Statement ) នៅថ្ងៃទី ១០នៃខែបន្ទាប់។

### ៣.៤.១.៥. វិធានការកែតម្រូវបន្ទាន់

ជំពូក ៦មាន ១១ ប្រការដែលចែងអំពីៈ

- អនុបាត ក្រោម ១៥០% អនុសាសន៍ពង្រឹងការគ្រប់គ្រង បើក្រោម ១២០% ការតម្រូវពង្រឹងការគ្រប់គ្រង បើក្រោម ១០០% ការបង្គាប់បញ្ជាពង្រឹងការគ្រប់គ្រង។
- អនុសាសន៍ពង្រឹងការគ្រប់គ្រង វិធាន មានពង្រឹងធនធានមនុស្ស និងការគ្រប់គ្រងស្ថាប័នកាត់បន្ថយចំណាយដាក់កម្រិតលើសកម្មភាពនានាដែលនាំឱ្យមានការធ្លាក់ចុះមូលធនសុទ្ធ។
- ការតម្រូវពង្រឹងការគ្រប់គ្រង វិធាន ការដាក់កំហិតលើការកាន់កាប់ទ្រព្យសកម្មដែលមានហានិភ័យខ្ពស់ និងការលក់ឬដោះដូរទ្រព្យសកម្ម ការបិទ នងការបង្រួមបញ្ចូលគ្នានូវការិយាល័យអាជីវកម្ម ឬការដាក់កំហិតលើការបើកការិយាល័យអាជីវកម្មថ្មី ការទាមទារឱ្យមានការផ្លាស់ប្តូរបុគ្គលិក។
- ការបង្គាប់បញ្ជាពង្រឹងការគ្រប់គ្រង វិធាន មិនបង្កើន ឬបន្ថយភ្លាមៗនូវការជួញដូរមូលបត្រ ឬសកម្មភាពហោរញ្ញប្បទាន ផ្ទេរទាំងអស់ ឬមួយផ្នែកនៃមូលបត្រ វត្ថុបញ្ចាំ ទ្រព្យសកម្ម និងគណនីរបស់អតិថិជនទៅក្រុមហ៊ុនមូលបត្រមួយ ឬច្រើនផ្សេងៗទៀត បន្តប្រតិបត្តិការអាជីវ-

កម្មទៅតាមលក្ខខណ្ឌ ដែលកំណត់ដោយអគ្គនាយកនៃគ.ម.ក. ផ្អាកជាបណ្តោះអាសន្ននូវការគ្រប់គ្រងប្រតិបត្តិការអាជីវកម្មដោយអ្នកគ្រប់គ្រង និងតែងតាំងអភិបាលបណ្តោះអាសន្ន វិធានការចាំបាច់ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃគ.ម.ក។

**ប្រការ ២៧ ការដាក់ជូន និងការវាយតម្លៃលើផែនការពង្រឹងការគ្រប់គ្រង**

- ត្រូវដាក់ជូនអគ្គនាយកនៃគ.ម.ក ក្នុងរយៈពេល១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទទទួលបានអនុសាសន៍ ឬតម្រូវ ឬការបង្គាប់បញ្ជាឱ្យពង្រឹងការគ្រប់គ្រងនោះ ឬក្នុងរយៈពេលជាក់លាក់ណាមួយកំណត់ដោយអគ្គនាយកនៃ គ.ម.ក
- .អគ្គនាយកនៃគ.ម.ក. ត្រូវសម្រេចលើផែនការពង្រឹងការគ្រប់គ្រងក្នុងរយៈពេល ១ (មួយ) ខែយ៉ាងយូរ គិតចាប់ពីកាលបរិច្ឆេទទទួលបានផែនការពង្រឹងការគ្រងគ្រងនោះ។
- ករណីផែនការពង្រឹងការគ្រប់គ្រងមិនមានលក្ខណៈសមស្រប អគ្គនាយកនៃ គ.ម.ក. អាចចាត់វិធានកែតម្រូវបន្ទាន់ដូចមានចែងក្នុងប្រការ ២៣ ឬប្រការ ២៤។
- ក្រុមហ៊ុនមូលបត្រត្រូវដាក់ជូនអគ្គនាយកនៃ គ.ម.ក. ឡើងវិញនូវផែនការពង្រឹងការគ្រប់គ្រងក្នុងរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃ គ.ម.ក.
- ករណីក្រុមហ៊ុននៅតែមិនអាចបំពេញតាមការតម្រូវ ឬការបញ្ជា អគ្គនាយកនៃ គ.ម.ក អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៣៥ នៃប្រការនេះ។

**ប្រការ ២៨ រយៈពេលអនុវត្តផែនការពង្រឹងការគ្រប់គ្រង**

- វិធានការកែតម្រូវបន្ទាប់លើអនុសាសន៍ពង្រឹងការគ្រប់គ្រង មានរយៈពេលអនុវត្ត ០៦ខែ
- វិធានការកែតម្រូវបន្ទាប់លើការតម្រូវពង្រឹងការគ្រប់គ្រងមានរយៈពេលអនុវត្ត ០១ ឆ្នាំ
- វិធានការកែតម្រូវបន្ទាប់លើការបង្គាប់បញ្ជា ពង្រឹងការគ្រប់គ្រង មានរយៈពេលអនុវត្តកំណត់ដោយអគ្គនាយកនៃ គ.ម.ក.

**ប្រការ ២៩ ការស្នើសុំកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រងដែលបានសម្រេច**

- ករណីផែនការពង្រឹងការគ្រប់គ្រងមិនបានសម្រេចតាមគោលដៅគ្រោងទុក ឬមានការលំបាកក្នុងការអនុវត្តតាមផែនការពង្រឹងការគ្រប់គ្រង ដោយសារមានការប្រែប្រួលបរិយាកាសអាជីវ-កម្ម ក្រុមហ៊ុនមូលបត្រអាចស្នើសុំជាលាយលក្ខណ៍អក្សរ មកអគ្គនាយកនៃគ.ម.ក. ដើម្បីកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រង ដោយភ្ជាប់មកជាមួយផែនការពង្រឹងការគ្រប់គ្រងថ្មី។
- អគ្គនាយកនៃ គ.ម.ក. ត្រូវជូនដំណឹងអំពីការសម្រេចទទួលយកសំណើកែប្រែមាតិកាផែនការពង្រឹងការគ្រប់គ្រងក្រោយពីការវាយតម្លៃទៅតាមករណីនីមួយៗ

**ប្រការ ៣០ របាយការណ៍លទ្ធផលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រង**

- ក្រុមហ៊ុនមូលបត្រត្រូវដាក់ជូនអគ្គនាយកនៃគ.ម.ក. នូវលទ្ធផលអនុវត្តផែនការពង្រឹងការគ្រប់គ្រង
    - ប្រចាំត្រីមាសក្នុងរយៈពេល ១៥( ដប់ប្រាំ) ឬរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃគ.ម.ក. គិតចាបពីចុងត្រីមាស
    - ក្នុងរយៈពេល ១៥( ដប់ប្រាំ) ឬរយៈពេលជាក់លាក់មួយកំណត់ដោយអគ្គនាយកនៃគ.ម.ក. បន្ទាប់ពីរយៈពេលនៃការអនុវត្តផែនការនោះបានបញ្ចប់

**ប្រការ៣១ ការសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់**

- ក្នុងកំឡុងពេលនៃការអនុវត្តផែនការពង្រឹងការគ្រប់គ្រង ករណីក្រុមហ៊ុនមូលបត្រដែលបានទទួលអនុសាសន៍ ឬការតម្រូវ ឬការបង្គាប់បញ្ជាពង្រឹងការគ្រប់គ្រង បានរក្សាអនុបាតមូលធនសុទ្ធលើសពី ១៥០% នៃកម្រិតមូលធនកាតព្វកិច្ច អគ្គនាយកនៃគ.ម.ក. អាចពិចារណាសម្រេចបញ្ចប់វិធានការកែតម្រូវបន្ទាន់។

### ៣.៥.២. ក្រមសីលធម៌វិជ្ជាជីវៈ:

[10]ក្រុមហ៊ុនទាំងអស់ដែលទទួលបានអាជ្ញាបណ្ណត្រូវតែមានក្រមសីលធមិដូចជា៖

#### ៣.៥.២.១. គោលការណ៍អាជីវកម្ម

ក្រុមហ៊ុនដែលទទួលអាជ្ញាបណ្ណត្រូវ៖

- មានភាពសុចរិតក្នុងការប្រកបអាជីវកម្ម និងធ្វើការប្រកួតប្រជែងដោយស្មោះត្រង់
- ដំណើការអាជីវកម្មប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់
- យកចិត្តទុកដាក់ចំពោះការគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចការទទួលខុសត្រូវ
- មានធនធានមនុស្ស បំពាក់ឧបករណ៍គ្រប់គ្រាន់ និងមាននីតិវិធី
- រក្សាលក្ខខណ្ឌតម្រូវហិរញ្ញវត្ថុអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ
- បំពេញកាតព្វកិច្ចក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងប្រាក់របស់អតិថិជនជាចម្បង
- ផ្តល់ប្រឹក្សាវិនិយោគទៅអតិថិជនឱ្យបានត្រឹមត្រូវសោយស្វែងយល់ពីព័ត៌មានរបស់អតិថិជន
- ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជនធ្វើការសម្រេចចិត្ត

[10] ឧបសម្ព័ន្ធ

- ប្រុងប្រយ័ត្នកុំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន
- គោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ និងធានាថារាល់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគគោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ
- រក្សាការសម្ងាត់ និងធានាថារាល់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគរបស់ក្រុមហ៊ុនរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់អតិថិជន និងមិនត្រូវផ្សព្វផ្សាយដល់អតិថិជន លើកលែងតែមានការតម្រូវដោយច្បាប់ ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់អតិថិជន។

**៣.៥.២.២. គណនីអតិថិជន**

អតិថិជនដែលបានបើកគណនីសម្រាប់ប្រតិបត្តិការជួញដូរមូលបត្រ អាចបើកបានតែមួយប៉ុណ្ណោះ នៅក្រុមហ៊ុនមូលបត្រមួយ។ មុនពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវ៖

- សិក្សាពីព័ត៌មានទាក់ទងនឹងអតិថិជន
- បំពេញតាមទម្រង់សុំបើកគណនី
- ចុះកិច្ចព្រមព្រៀងជាមួយអតិថិជន

គណនីត្រូវបានអនុញ្ញាតឱ្យបើកមុនធ្វើប្រតិបត្តិការយ៉ាងហោចមួយថ្ងៃនៃថ្ងៃធ្វើការ ហើយរាល់កិច្ចព្រមព្រៀងរបស់អតិថិជនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាត្រឹមត្រូវរវាងអតិថិជន និងក្រុមហ៊ុន តាមទម្រង់និងកិច្ចព្រមព្រៀងអតិថិជនកំណត់ដោយ គ.ម.ក។ ហើយភ្នាក់ងារត្រូវពន្យល់ខ្លឹមសារនីមួយៗ នៅក្នុងកិច្ចព្រមព្រៀងដល់អតិថិជនមុនចុះហត្ថលេខា។

ចំពោះប្រាក់ក្នុងគណនីសាច់ប្រាក់អតិថិជនដែលក្រុមហ៊ុនមូលបត្រទទួលបានរួមមាន៖

- ប្រាក់សម្រាប់ធ្វើការទិញមូលបត្រ
- ប្រាក់បានពីការលក់មូលបត្រសម្រាប់ផលប្រយោជន៍អតិថិជន
- រាល់ប្រាក់ផ្សេងទៀតដែលទទួលពី ឬសម្រាប់ផលប្រយោជន៍អតិថិជន

**៣.៥.២.៣. ការផ្តល់ព័ត៌មានទៅកាន់អតិថិជន**

ក្រុមហ៊ុនមូលបត្រត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរ ទៅកាន់អតិថិជនមុននឹងអនុវត្តការជួញដូរមូលបត្ររបស់អតិថិជន ដោយមើលទៅលើសកម្មភាពអាជីវកម្ម របស់ក្រុមហ៊ុនទទួលបានអជ្ញាបណ្ណ ជាពិសេសកម្រៃជើងសារ និងពន្ធដែលត្រូវបង់ ព្រមទាំងវិធីសាស្ត្រគណនា និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ដោយត្រូវស្នើសុំ ឬជូនដំណឹងដល់ គ.ម.ក

ដើម្បីការពារផលប្រយោជន៍ដល់អតិថិជន និងធ្វើឱ្យអតិថិជនមានទំនុកចិត្ត នៅពេលដែលអតិថិជនទទួលបានភាពច្បាស់លាស់។ នៅពេលដែលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត ក្រុមហ៊ុន និងភ្នាក់ងារមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដល់អតិថិជនឱ្យបានឆាប់បំផុតនៅថ្ងៃធ្វើប្រតិបត្តិការទាំងនោះ ហើយក្រុមហ៊ុនត្រូវមានការព្រមព្រៀងជាមួយអតិថិជនជាមុន អំពីវិធីសាស្ត្រនៃការជូនដំណឹង។ យ៉ាងណាមិញក្រុមហ៊ុនមូលបត្រត្រូវផ្តល់ដំណឹងជូនអតិថិជន នូវរបាយការណ៍ប្រតិបត្តិការប្រចាំការក្នុងខែរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការនៃខែបន្ទាប់។ ហើយសម្រាប់គណនីដែលពុំមានសកម្មភាពជួញ ក្រុមហ៊ុនត្រូវផ្តល់ជូនអតិថិជនរបាយការណ៍គណនីយ៉ាងហោចណាស់មួយដងរៀងរាល់ ៦ខែ។

**៣.៥.២.៤. ការផ្តល់ប្រឹក្សាវិនិយោគ**

ការផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជនត្រូវធ្វើឡើងដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផល និងដោយផ្អែកលើព័ត៌មានដែលផ្តល់ឱ្យដោយអតិថិជន។ ក្រុមហ៊ុនត្រូវបង្កើត និងអនុវត្តវិធានត្រួតពិនិត្យផ្ទៃក្នុងដើម្បីគោរពតាមគោលការណ៍តម្រូវដោយបទប្បញ្ញត្តិ។ ក្រុមហ៊ុនត្រូវស្នើសុំជារៀងរាល់ឆ្នាំទៅអតិថិជន ឱ្យជូនដំណឹងទៅដល់ក្រុមហ៊ុនអំពីព័ត៌មានថ្មីៗរបស់អតិថិជន។ ហើយក្រុមហ៊ុននិងភ្នាក់ងាររបស់ខ្លួនមិនត្រូវជំរុញឱ្យអតិថិជនជួញដូរមូលបត្រច្រើនហួសហេតុ អាចនិយាយបានថាខុសសីលធម៌ដោយអោយគេទិញច្រើននោះក្រុមហ៊ុននិងបានប្រាក់កម្រៃ (commission) ច្រើននោះនឹងចូលលក្ខខណ្ឌដែលក្រុមហ៊ុនគិតតែពីផលប្រយោជន៍របស់ខ្លួន ប៉ុន្តែគួរតែគិតថាសុខចិត្តចំណេញតិចអោយតែមានអតិថិជនច្រើនវិញ និងមិនត្រូវផ្តល់ប្រឹក្សាវិនិយោគចំពោះមូលបត្រ៖

- ដែលមិនចុះបញ្ជីលក់នៅទីផ្សារមូលបត្រប្រតិស្រុត
- ដែលស្ថិតនៅក្រោមការចាត់វិធានការរដ្ឋបាល ឬការស៊ើបអង្កេត
- សញ្ញាបណ្ណសាជីវកម្មដែលមានហានិភ័យខ្ពស់

**៣.៥.២.៥ .ការអនុវត្តការជួញដូរមូលបត្រ**

ក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងារក្រុមហ៊ុនមូលបត្ររបស់ខ្លួន មិនត្រូវធ្វើប្រតិបត្តិការឆន្ទានុសិទ្ធិ និងរាល់ការអនុវត្តបញ្ជាទិញ-លក់របស់អតិថិជនឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា និងមិនលំអៀង។ ក្រុមហ៊ុនអាចធ្វើការអនុវត្តបញ្ជាទិញ-លក់ក្នុងនាមអតិថិជនបានលុះត្រាតែ ក្រុមហ៊ុនទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអតិថិជន និងអតិថិជនមានប្រាក់ និងមូលបត្រគ្រប់គ្រាន់សម្រាប់ទូទាត់ប្រតិបត្តិការជួញដូរ។ រាល់ការបញ្ជាទិញ-លក់អាចធ្វើឡើងតាមរយៈ៖

- ឯកសារជាលាយលក្ខណ៍អក្សរ

- សម្លេង
- សារអេឡិចត្រូនិក
- មធ្យោបាយអេឡិចត្រូនិកផ្សេងទៀត

មួយវិញទៀតក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ឬថតចម្លង ឬតាមប្រព័ន្ធអេឡិចត្រូនិក។ ម្យ៉ាងទៀតក្រុមហ៊ុនមូលបត្រ ត្រូវទទួលបញ្ជាតែជាបុគ្គលដែលមានសិទ្ធិដែលជាអតិថិជនដែលជាម្ចាស់គណនី ជាអ្នកតំណាងអតិថិជនបានជ្រើសរើស ជាលាយលក្ខណ៍អក្សរនៅពេលបើកគណនី និងត្រូវតែជាបុគ្គលដែលបានទទួលសិទ្ធិស្របច្បាប់ ក្នុងការបញ្ចេញតាមលិខិតផ្ទេរសិទ្ធិ។ នូវរាល់ពេលអនុវត្តបញ្ជារបស់អតិថិជនក្រុមហ៊ុនមិនត្រូវ បញ្ជូនបញ្ជាក្នុងគណនីក្រុមហ៊ុន ឬបញ្ជាមិនមែនអតិថិជនទៅក្នុងទីផ្សារ មិនបញ្ចុះបញ្ចូលបុគ្គលផ្សេងទៀតឱ្យបញ្ជាទិញ-លក់មូលបត្រនោះ និងផ្តល់ដំណឹងពីបញ្ជារបស់អតិថិជនទៅឱ្យបុគ្គលផ្សេងទៀត ដែលធ្វើឱ្យបែកធ្លាយការសម្ងាត់របស់ក្រុមហ៊ុន និងធ្វើអោយខូចដល់ផលប្រយោជន៍បុគ្គលដទៃទៀត។

#### ៣.៥.៣.៦. ភាតព្វកិច្ចដែលត្រូវហាមឃាត់ក្នុងការប្រកបអាជីវកម្ម

ក្រុមហ៊ុនទទួលអជ្ញាបណ្ណមិនត្រូវអនុញ្ញាតឱ្យបុគ្គលណាមួយ ធ្វើជាភ្នាក់ងារក្នុងនាមក្រុនហ៊ុនឡើយ លើកលែងតែបុគ្គលនោះបំពេញតាមលក្ខខណ្ឌ ដោយទទួលបានអជ្ញាបណ្ណជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និងមិនមែនជាភ្នាក់ងារនៃក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគដទៃទៀត។ ក្រុមហ៊ុនមូលបត្រមិនត្រូវយកព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួន និងត្រូវបែងចែកផ្នែកនីមួយៗ ឱ្យដាច់ដោយឡែកពីគ្នា ស្របតាមប្រភេទអាជីវកម្ម។ ចំពោះបុគ្គលដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកមានសិទ្ធិកាន់កាប់តំណែងជាអភិបាល ឬបុគ្គលជាន់ខ្ពស់ ឬកាន់កាប់ភាគហ៊ុនក្នុងក្រុមហ៊ុនទទួលបាលអាជ្ញាបណ្ណមួយផ្សេងទៀត។ ក្រុមហ៊ុន និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្តល់ដល់អតិថិជននូវការធានាប្រាក់ចំណេញ ឬទូទាត់សងនៃការទូទាត់សងនៃការខាតបង់ ដែលកើតឡើងដោយសារការវិនិយោគមូលបត្រ។ ករណីមានការទូទាត់សង ក្រុមហ៊ុន ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលជាន់ខ្ពស់ ឬនិយោជិត ត្រូវរាយការណ៍ជាមុនទៅបុគ្គលិកជំនាញផ្នែកច្បាប់។ ហើយក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្តល់ឱ្យ ឬទទួលនូវគ្រឿងលើកទឹកចិត្ត អំណោយ ឬអត្ថ-ប្រយោជន៍ផ្សេងៗ ឬពីអតិថិជន និងមិនត្រូវស្នើក្រុមហ៊ុនដទៃទៀត ឱ្យកែប្រែនូវថ្លៃស្នើលក់ និងថ្លៃស្នើទិញ ឬកែប្រែអត្រាកម្រៃជើងសារឡើយ។

#### ៣.៥.៣.៧. ការផ្សាយពាណិជ្ជកម្ម

សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ៖

- អាជីវកម្មដែលក្រុមហ៊ុនមូលបត្រអាចធ្វើ : អាជីវកម្មធានាទិញមូលបត្រ អាជីវកម្មជួញដូរមូលបត្រ អាជីវកម្មជើងសារមូលបត្រ អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ និងអាជីវកម្មផ្សេងទៀតពាក់ព័ន្ធនឹងមូលបត្រ។
- អាជីវកម្មរបស់ក្រុមហ៊ុនធានាទិញមូលបត្រ : ក្រុមហ៊ុនមូលបត្រ អាចធ្វើអាជីវកម្មធានាទិញមូលបត្រ អាជីវកម្មជួញដូរមូលបត្រ អាជីវកម្មជើងសាមូលបត្រ, អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ
- អាជីវកម្មរបស់ពាណិជ្ជករមូលបត្រ : ពាណិជ្ជករមូលបត្រអាចធ្វើតែអាជីវកម្មជួញដូរមូលបត្រ ជើងសារមូលបត្រ និងផ្តល់ប្រឹក្សាវិនិយោគប៉ុណ្ណោះ។
- សកម្មភាពអាជីវកម្មរបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ : បើក និងគ្រប់គ្រងគណនីឱ្យអតិថិជន ទទួល និងអនុវត្តបញ្ជាទិញ ឬលក់មូលបត្រក្នុងនាមអតិថិជន និងសកម្មភាពផ្សេងទៀតតាមការឯកភាពរបស់ក្រុមហ៊ុនមូលបត្រ។

**ការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ**

- សុពលភាពអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រ : អាជ្ញាបណ្ណមានសុពលភាព **០២ ឆ្នាំ**គិតចាប់ពីកាលបរិច្ឆេទដែលបានផ្តល់អាជ្ញាបណ្ណ។ អាជ្ញាបណ្ណដែលសុំបន្តមានសុពលភាព **០៣ ឆ្នាំ**។

**បទប្បញ្ញត្តិផ្សេងៗ**

- ការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណ
- ការកែប្រែបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ ក្នុងអំឡុងពេលកំពុងពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណ
- ការផ្សព្វផ្សាយជាសាធារណៈនូវការផ្តល់អាជ្ញាបណ្ណ ការបន្តអាជ្ញាបណ្ណ ឬការចាត់វិធានការ និង/ឬ ការដាក់ទណ្ឌកម្មផ្សេងៗ
- បុគ្គលដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ គ.ម.ក. តិចជាងរយៈពេលដែលបានកំណត់ ត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ក្នុងមួយថ្ងៃដូចខាងក្រោម

| ប្រភេទអាជីវកម្ម | ពិន័យអន្តរការណ៍ |
|---|---|
| ក្រុមហ៊ុនមូលបត្រ | ១.០០០.០០០ រៀល |
| ភ្នាក់ងារក្រុមហ៊ុនមូលបត្រ | ៦០០.០០០ រៀល |
| ទីប្រឹក្សាវិនិយោគជារូបវន្តបុគ្គល | ២០០.០០០ រៀល |
| ក្រុមប្រឹក្សាវិនិយោគ | ៤០០.០០០ រៀល |

**បទប្បញ្ញត្តិទូទៅ**

- គ្រប់បុគ្គលទាំងអស់ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ឬលក្ខខណ្ឌណាមួយដែលចែងដោយអនុលោមតាមប្រកាសនេះ គឺថាការប្រព្រឹត្តបទល្មើសដែលត្រូវទទួលពិន័យ និងផ្តន្ទាទោសដោយយោងទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។
- សិទ្ធិអំណាចក្នុងការអនុម័តសេចក្តីណែនាំ
- បទប្បញ្ញត្តិដែលផ្ទុយនឹងប្រកាសនេះ

**មូលហេតុនៃការបដិសេធ**

- បុគ្គលដាក់ពាក្យស្នើសុំ មិនបានបំពេញនូវលក្ខខណ្ឌណាមួយដែលមានចែងក្នុងប្រកាសនេះ ឬសេចក្តីណែនាំផ្សេងទៀត ដែលធ្វើនៅក្រោមប្រកាសនេះ ឬបទប្បញ្ញត្តិជាធរមានដែល ពាក់ព័ន្ធផ្សេងទៀត។
- ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ទៅ គ.ម.ក. មានលក្ខណៈក្លែងបន្លំ ឬដែលនាំឱ្យយល់ខុស
- បុគ្គលដាក់ពាក្យស្នើសុំ ស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬរំលាយអាជីវកម្ម។
- សេចក្តីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុលមិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។
- បុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលជាន់ខ្ពស់របស់បុគ្គលដាក់ពាក្យស្នើសុំៈ
- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ចឬមិនត្រឹមត្រូវដោយប្រការណាមួយ។
- បានប្រព្រឹត្តល្មើស និងច្បាប់ និងបទប្បញ្ញត្តិដែលការពារសាធារណជន ឱ្យចៀសផុតពីការខាងបង់ផ្នែកហិរញ្ញវត្ថុ
- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀត ដែលធ្វើឱ្យមានការសង្ស័យ

ចំពោះសមត្ថភាព និងសុក្រឹត្យភាពនៃសេចក្តីសម្រេចរបស់ខ្លួន។

- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បី ផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលលក្ខណៈ សេចក្តីសុចរិត និងភាពដែលអាចទុកចិត្តបានផ្នែកហិរញ្ញវត្ថុរបស់បុគ្គលទាំងនោះ។
- ស្តែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបានក្រោមលក្ខខណ្ឌនៃការអនុញ្ញាត ប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។
- អភិបាល ឬបុគ្គលជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលុបរបស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។
- នៅពេលកើតមានហេតុការណាមួយដែលអាចៈ នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ ឬអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិក ដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។
- ការផ្តល់ការអនុញ្ញាតដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

អគ្គនាយកនៃ គ.ម.ក. មិនត្រូវបដិសេធផ្តល់ការអនុញ្ញាតលើពាក្យស្នើសុំ ដោយមិនបានផ្តល់មូលហេតុជាលាយលក្ខណ៍អក្សរជាមុន និងមិនបានផ្តល់ឱកាសឱ្យបុគ្គលពាក្យស្នើសុំធ្វើការពន្យល់។

**ការផ្តល់ការអនុញ្ញាត**

- បន្ទាប់ពីបុគ្គលដាក់ពាក្យស្នើសុំបានបំពេញតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ បទប្បញ្ញត្តិជាធរមាន និងប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ គ.ម.ក. ត្រូវពិនិត្យ និងសម្រេចលើការស្នើសុំនោះ។
- អគ្គនាយកនៃ គ.ម.ក. ត្រូវផ្តល់ការអនុញ្ញាត ឬជូនដំណឹងអំពីការបដិសេធដល់បុគ្គលដាក់ពាក្យស្នើសុំតាមការសម្រេចរបស់ គ.ម.ក.។
- សុពលភាពនៃការអនុញ្ញាតលើកដំបូងមានរយៈពេល ០៨ (ប្រាំបី) ឆ្នាំ។
- ក្នុងរយៈពេល ១២ (ដប់ពីរ) ខែមុនការអនុញ្ញាតអស់សុពលភាព ប្រតិបត្តិករត្រូវសុំបន្តការអនុញ្ញាត ដោយគោរពតាមលក្ខខណ្ឌនៃការផ្តល់ការអនុញ្ញាតដូចមានចែងក្នុងប្រកាសនេះ។

- សុពលភាពនាការអនុញ្ញាតបន្ត មានរយៈពេល ០៨ (ប្រាំបី) ឆ្នាំ ឬមិនកំណត់
- ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០.០០០.០០០ (ដប់លាន) រៀល ត្រូវបង់សម្រាប់ពាក្យស្នើសុំធ្វើជាប្រតិបត្តិករនីមួយៗ។
- ពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតនេះ មិនត្រូវបានប្រគល់ជូនបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាមានការបដិសេធលើពាក្យស្នើសុំក៏ដោយ។
- ថ្លៃការអនុញ្ញាត ប្រចាំឆ្នាំចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល សម្រាប់ប្រតិបត្តិករនីមួយៗ។
- ករណីមានការយឺតយ៉ាវក្នុងការបង់ថ្លៃការអនុញ្ញាត ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់និងទូទាត់មូលបត្រ និងប្រតិបត្តិកររក្សាទុកមូលបត្រ ត្រូវទទួលការផាកពិន័យអន្តរការណ៍ជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ថ្ងៃ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ មិនត្រូវផ្សព្វផ្សាយជាសាធារណៈដែលការផ្សាយផ្សាយនោះ

- ➢ ផ្ទុយនូវការសន្យាមិនសមហេតុផលជាក់លាក់ណាមួយ
- ➢ ផ្ទុយូបយោបល់ ឬការព្យាករណ៍អនាគតដែលមិនបានបញ្ជាក់ច្បាស់លាស់
- ➢ មិនបានបង្ហាញឱ្យបានត្រឹមត្រូវពីហានិភ័យ
- ➢ មិនត្រូបផ្សាយពាណិជ្ជកម្មលទ្ធផលវាយតម្លៃការគ្រប់គ្រង និងកម្រិតមូលធនសុទ្ធកាតព្វកិច្ចរបស់ខ្លួន ដើម្បីធ្វើការប្រៀបធៀបជាមួយក្រុមហ៊ុនមូលបត្រដទៃទៀត។

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាស្រាវជ្រាវ និងព្រមទាំងចុះកម្មសិក្សាដោយផ្ទាល់នៅគណៈ-កម្មការមូលបត្ររយៈពេល ១ខែ និងធ្វើការស្រាវជ្រាវដោយផ្ទាល់អស់មួយរយៈពេលកន្លងមក យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើនដែលពាក់ព័ន្ធទៅនឹងវិស័យមូលបត្រ ជាពិសេសគឺ ការត្រួតពិនិត្យក្រុមហ៊ុនមូលបត្រ ដើម្បីស្វែងយល់ពីបទប្បញ្ញត្តិ និងលក្ខខណ្ឌក្នុងការត្រួតពិនិត្យ និងផ្តល់អាជ្ញាបណ្ណ ដល់ក្រុមហ៊ុនមូលបត្រក្នុងវិស័យមូលបត្រ។ យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធទៅនឹងវិស័យមូលបត្រ ជាពិសេសគឺក្រុមហ៊ុនមូលបត្រ។ ដើម្បីធានាឱ្យបាននូវដំណើរការបោះលក់មូលបត្រ ជាសាធារណៈ និងប្រព្រឹត្តទៅដោយរលូន គឺត្រូវការចាំបាច់បំផុតនោះគឺ ក្រុមហ៊ុនធានាទិញមូលបត្រ ដែលជាក្រុមហ៊ុនមូលបត្រមួយក្នុ ងចំនោមក្រុមហ៊ុនទាំងបួនដែលសំខាន់បន្ទាប់នោះគឺ ក្រុមហ៊ុនពាណិជ្ជករមូលបត្រ ឈ្មួញជើងសារមូលបត្រ និងក្រុមហ៊ុនប្រឹក្សាវិនិយោគ ដែលដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យមូលបត្រ ក្នុងការជួយរៀបចំចាត់ចែងដើម្បីឱ្យឧបករណ៍នេះ មានចលនានិងមានការវិនិយោគ និងដំណើរការនៅលើទីផ្សារ។ មិនតែប៉ុណ្ណោះក្រុមហ៊ុនមូលបត្របានជួយយ៉ាងច្រើនដល់វិនិយោគិន និងសាធារណជន តាំងពីការចាត់ចែងផ្តល់ប្រឹក្សាយោបល់ រៀបចំនូវរាល់ឯកសារដែលពាក់ព័ន្ធ ជួយរៀបចំដំណើរការបោះផ្សាយ និងវិនិយោគ និងថែមទាំងជួយធានាទិញមូលបត្រ ដើម្បីចៀសវាងពីហានិភ័យរបស់វិនិយោគិន។

ទោះបីជាវិស័យមូលបត្រនៅកម្ពុជា មិនជាសូវមានការយល់ដឹងច្រើន ពីសំណាក់សាធារណជន ប៉ុន្តែជាចំនុចដែលកំពុងតែរីករាលដាល និងចង់ដឹងលឺ ដែលជាចំនុចរសើបមួយដែលកើតឡើងនៅក្នុងវិស័យសេដ្ឋកិច្ច។ ហើយ គ.ម.ក មិនទាន់សូវមានការទុកចិត្ត និងផ្តល់ទំនុកចិត្តដល់វិនិយោគិននានាដែលអាចការពារ និងទាក់ទាញវិនិយោគិន ប៉ុន្តែច្បាប់ និងបទប្បញ្ញត្តិ អនុក្រឹត្យ ប្រកាស និងលក្ខខណ្ឌផ្សេងៗ ស្តែងចេញនូវទំនុកចិត្ត និងការការពារផ្សេង និងការផ្តល់ទំនុកចិត្ត។ ក្រៅពីប្រព័ន្ធច្បាប់រឹងមាំ គ.ម.ក ក៏មានការបង្កើតនាយកដ្ឋានត្រួតពិនិត្យអន្តរការី ដែលមានតួនាទីត្រួតពិនិត្យ និងឃ្លាំមើលក្រុមហ៊ុនមូលបត្រដែលជាអន្តរ-ការីដ៏សំខាន់ ក្នុងការជួញដូរមូលបត្រ ដើម្បីទប់ស្កាត់ការជួញដូរមិនប្រក្រតី។ ថ្វីបើក្រុមហ៊ុនមូលបត្រមិនទាន់ជាសូវមានទំនុកចិត្ត ពីសំណាក់អ្នកវិនិយោគ និងមិនសូវជាមានវិធីសាស្ត្រ ក្នុងការផ្តល់ផលប្រយោជន៍ដល់អ្នកវិនិយោគទាំងឡាយ ប៉ុន្តែមានតួនាទីជាភ្នាក់ងារទីផ្សារមូលបត្រដ៏សំខាន់ ក្នុងការវិនិយោគនៅក្នុងវិស័យមូលបត្រ។ ហើយជាអ្នកផ្តល់ប្រឹក្សា និងត្រួសត្រាយផ្លូវដ៏ជំនាញក្នុងការលូកដៃចូលទីផ្សារមួយនេះ។ មិនត្រឹមតែប៉ុណ្ណោះ គ.

ម.ក ក៏មានការតាមដាន និងត្រួតពិនិត្យដល់ទីកន្លែង ទៅតាមក្រុមហ៊ុននីមួយៗ និងដាក់លក្ខខណ្ឌផ្សេងៗ ដើម្បីក្លាយជាក្រុមហ៊ុនមូលបត្រដែលមានសុពលភាព និងការទុកចិត្ត ពីអតិថិជន។

ដោយសព្វថ្ងៃក្រុមហ៊ុនដែលចុះបញ្ជីមានរហូតដល់ទៅ៥ (ប្រាំ)ក្រុមហ៊ុន ពីព្រោះតែការចាប់អារម្មណ៍ពីសំណាក់សាធារណៈទៅលើវិស័យនេះនិងការខិតខំប្រឹងប្រែងរបស់ គ.ម.ក ក្នុងការផ្សព្វផ្សាយ និងមិនថាតែនៅក្នុងប្រព័ន្ធព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយតាមបណ្តាញសង្គមនានា ដូចជាតាមគេហទំព័រ ដល់សាធារណជន និងវិនិយោគិន ឱ្យកាន់តែយល់ច្បាស់ពីវិស័យមូលបត្រ ដោយតាមរយៈការរៀបចំសិក្ខាសិលានានាជាច្រើន និងបានបញ្ចូលនៅក្នុងប្រព័ន្ធអប់រំដែលជាមុខវិជ្ជាមួយសំខាន់ផងដែរ។ ដូច្នេះគ.ម.ក ក៏កាន់តែយកការទុកដាក់ទៅលើការត្រួតពិនិត្យ ទៅលើក្រុមហ៊ុនទាំងនោះ។ ទាំងនេះសុទ្ធតែជាមធ្យោបាយដ៏ល្អរបស់គណៈកម្មការមូលបត្រ ដែលបានចូលរួមជាមួយក្រុមហ៊ុនទីផ្សារមូលបត្រ។ តែទោះបីជាយ៉ាងណាការផ្សព្វផ្សាយរបស់ គ.ម.ក និង ផ.ម.ក មិនអាចចែកចាយ និងផ្សព្វផ្សាយទៅដល់សាធារណៈជនទូទៅ និងវិនិយោគិនគ្រប់រូបឡើយ បើទោះបីជាខំព្យាយាមផ្សព្វផ្សាយជាច្រើនទាក់ទងនិងវិស័យមូលបត្រ ក៏នូវតែហាក់បីដូចជាមិនទាំងអស់ទេ។ ម្យ៉ាងវិញទៀតកម្ពុជាហាក់ដូចជានៅមានការជះឥទ្ធិពលពីដុល្លារនីយកម្មយ៉ាងខ្លាំងផងដែរ។

ទោះជាយ៉ាងណាក៏ គ.ម.ក នូវតែមានចំនុចខ្វះខាត និងត្រូវកែលម្អ បើទោះបីជាមានចំនុចទាក់ទាញ និងចាប់អារម្មណ៍ច្រើនជាងមុននៅពេលឥឡូវនេះ។

# អនុសាសន៍

ដើម្បីត្រួតពិនិត្យទៅលើក្រុមហ៊ុនមូលបត្រ ដែលបានដើរតួនាទីយ៉ាងសំខាន់ ចូលរួមនៅក្នុងវិស័យទីផ្សារមូលបត្រ ដើម្បីឱ្យដំណើរការទៅបានកាន់តែល្អ និងកាន់តែមានការទុកចិត្តពីសំណាក់វិនិយោគិន ដើម្បីទទួលយកសេវាកម្មរបស់អ្នក យើងខ្ញុំសូមផ្ដល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- គ.ម.ក ត្រូវតែពង្រឹងទៅលើការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយជាងនេះ និងគួរតែព្យាយាមផ្សព្វផ្សាយ និងផ្ដល់អត្ថប្រយោជន៍ និងភាពងាយស្រួលដល់ក្រុមហ៊ុន ក៏ដូចជាវិនិយោគិន ក្នុងការស្វែងរកព័ត៌មានបន្ថែម ដែលទាក់ទងនឹងវិស័យមួយនេះ។ ពីព្រោះថាបើព័ត៌មានទាំងនេះទទួលបានពុំច្បាស់លាស់ និងមិនត្រឹមត្រូវក៏វិនិយោគិនទាំងនោះ មិនអាចបណ្ដាក់ទុន និងវិនិយោគនោះទេ ព្រោះថាគេខ្លាចបំផុតគឺការកើតមានហានិភ័យ។
- គ.ម.ក គួរតែពង្រឹង និងអនុវត្តន៍យ៉ាងម៉ឺងម៉ាត់ទៅលើក្រុមហ៊ុនមូលបត្រ ទាំងនោះជាពិសេសគួរតែបន្ថែមលក្ខខណ្ឌមួយចំនួន បន្ថែមទៀតដល់ក្រុមហ៊ុនមូលបត្រ និងដាក់ពិន័យជាកំហិតដល់ក្រុមហ៊ុនដែលពុំបានអនុវត្តន៍ពុំបានត្រឹមត្រូវ និងមិនត្រូវបន្ធូរបន្ថយឡើយ។
- គ.ម.ក ត្រូវតែឧបករណ៍សម្បូរបែបដើម្បីទាក់ទាញដល់វិនិយោគិន និងបំពេញតម្រូវការរបស់អ្នកចង់ទិញ
- ជាពិសេសត្រូវតែមានប្រព័ន្ធជួញដូរប្រកបដោយប្រសិទ្ធភាព និងបញ្ជូនព័ត៌មានឱ្យបានច្បាស់លាស់ និងទាន់ពេលវេលា។

សរុបសេចក្ដីមក វិស័យមូលបត្រកម្ពុជាអាចរីកចម្រើនទៅបានដោយការចូលរួមពីសំណាក់សមាសធាតុទាំងបួន ដែលរួមមាន ពាណិជ្ជករមូលបត្រ ធានាទិញមូលបត្រ ឈ្មួញជើងសារមូលបត្រ និងរក្សាទុកមូលបត្រដែលអាចហៅម្យ៉ាងទៀតថា ក្រុមហ៊ុនមូលបត្រ និងវិធីសាស្ត្រផ្សេងៗទៀតដែលសមស្រប និងធ្វើឱ្យលមានប្រសិទ្ធភាពនៃការជួញដូរមូលបត្រ ដែលអាចទាក់ទាញឱ្យវិនិយោគិនចូលរួមក្នុងទីផ្សារមូលបត្រកាន់តែច្រើន។

# ឯកសារយោង

## ប្រភពឯកសារដកស្រង់ពីសៀវភៅ


១. គណៈកម្មការមូលបត្រកម្ពុជា(២០០៩)ប្រកាសស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និង ភ្នាក់ងារក្រុមហ៊ុនមូលបត្រ

២. គណៈកម្មការមូលបត្រកម្ពុជា(២០១៦) "ការស្វែងយល់ពីទីផ្សារមូលបត្រនៅកម្ពុជា"

៣. រ៉ាត រតនា និង អ៊ាង ឡៃហេង(២០១៥) "យុទ្ធសាស្ត្រទាក់ទាញការវិនិយោគក្នុងទីផ្សារមូលបត្រ"

៤. សួន ចំរើន(២០១៥-២០១៦) "ទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ"

៥. អ៊ឹង អ៊ូ (២០១៦-២០១៧) "ទីផ្សារមូលបត្រកម្ពុជា"

៦. ឈាង ហ៊ុយ (២០១៥-២០១៧) "មូលដ្ឋានគ្រឹះស្ថានវិនិយោគ"

៧. លន់ សិទ្ធី និង យី គីមចេង (២០១២) "សេវាធានាទិញមូលបត្ររបស់ក្រុមហ៊ុនតុងយ៉ាង ស៊ីយូរីធី (ខេមបូឌា) ភីអិលស៊ី"


## ប្រភពឯកសារយោងដកស្រង់ចេញពីគេហទំព័រ


១. http://www.secc.gov.kh

២. http://csx.com.kh

៣. www.acledaback.com.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខៈ..០០៩..............គ ម ក

# ប្រកាស

## ស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធាននៃគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ/បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៩

រាស្ដយដ្ឋានបណ្ដោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលដៅចែងពីបទប្បញ្ញត្តិដើម្បីផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណ ដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ប្រការ ២.-**

និយមន័យនៃពាក្យបច្ចេកទេស ដែលប្រើប្រាស់នៅក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ៖

**ការចាប់ផ្តើមធ្វើអាជីវកម្ម** (Commencement of Business) : សំដៅដល់ការចាប់ផ្តើមធ្វើអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ក្រោយពីទទួលបានអាជ្ញាបណ្ណ ដោយគិតចាប់ពីពេលដែលក្រុមហ៊ុនចាប់ផ្តើមជួលបុគ្គលិកដើម្បីបំពេញការងារ សម្រាប់អាជីវកម្មដែលបានសុំអាជ្ញាបណ្ណ ឬចាប់ពីពេលដែលភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ចាប់ផ្តើមធ្វើសកម្មភាពពេលទទួលបានអាជ្ញាបណ្ណ។

**ច្បាប់** (Law) : សំដៅដល់ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**បុគ្គលិកជាន់ខ្ពស់** (Senior Staff) : សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុន ដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងសវនករផ្ទៃក្នុង។

**បុគ្គលមានទំនាក់ទំនងពិសេស** (Specially-Related Person) : សំដៅដល់បុគ្គលដូចខាងក្រោម ÷

១-ករណីបុគ្គលដើមជារូបវន្តបុគ្គល បុគ្គលដែលមានទំនាក់ទំនងពិសេសអាចជា ÷

ក-សហព័ទ្ធ។

ខ-សាខាញាតិលោហិតរហូតដល់ថ្នាក់ទី ៤។

គ-ខ្សែផ្ទាល់នៃបុព្វញាតិ ឬបច្ឆាញាតិរហូតដល់ថ្នាក់ទី ៣។

ឃ-សាខាញាតិពន្ធរហូតដល់ថ្នាក់ទី ៣។

ង-ខ្សែផ្ទាល់នៃបុព្វញាតិ ឬបច្ឆាញាតិរបស់បុគ្គលដែលចូលក្នុងគ្រួសាររបស់បុគ្គលដើមក្នុងនាមជាកូនចិញ្ចឹម និងសហព័ទ្ធរបស់បុគ្គលនោះ។

ច-ម្តាយរបស់បុគ្គលដែលកើតឥតខាន់ស្លា ដែលបុគ្គលឥតខាន់ស្លានោះត្រូវជាជីដូន ជីតា ឪពុក ម្តាយ កូន ចៅ ឬចៅទួតរបស់បុគ្គលដើម។

ឆ-បុគ្គលដែលរស់នៅដោយពឹងផ្អែកលើប្រាក់ ឬទ្រព្យសម្បត្តិរបស់បុគ្គលដើម និងបុគ្គលដែលរួមរស់ជាមួយបុគ្គលដើម។

ជ-ក្រុមហ៊ុនណាមួយដែលក្នុងនោះ បុគ្គលដើមធ្វើការវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុច (ក) រហូតដល់ (ឆ) នៃចំណុចទី ១ ខាងលើនេះ ឬបុគ្គលដើមមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រង ដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់ក្រុមហ៊ុននោះ ឬក្រុមហ៊ុនពាក់ព័ន្ធ។

ឈ-ក្រុមហ៊ុនណាមួយដែលក្នុងនោះ បុគ្គលដើមធ្វើការវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុច (ក) រហូតដល់ (ជ) នៃចំណុចទី ១ ខាងលើនេះ ឬបុគ្គលដើមមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រង ដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់ក្រុមហ៊ុននោះ ឬក្រុមហ៊ុនពាក់ព័ន្ធ។

២-ករណីបុគ្គលដើមជាក្រុមហ៊ុន បុគ្គលដែលមានទំនាក់ទំនងពិសេសអាចជា ÷

ក-នាយកប្រតិបត្តិ ឬអភិបាល ឬសហកម្មសិទ្ធិករ។

ខ-សាខាក្រុមហ៊ុន ឬអភិបាល ឬសហកម្មសិទ្ធិកររបស់សាខាក្រុមហ៊ុននោះ។

គ-រូបវន្តបុគ្គលដែលវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះ ក្នុងបុគ្គលដើមតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុចទី ១ ខាងលើ ឬរូបវន្តបុគ្គលនេះមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រងដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់បុគ្គលដើម។

ឃ-ក្រុមហ៊ុនណាមួយដែលក្នុងនោះ បុគ្គលដើមធ្វើការវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងនៅក្នុងចំណុច (ក) រហូតដល់ (គ) នៃចំណុចទី ២ ខាងលើនេះ ឬបុគ្គលដើមនេះមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រងដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់ក្រុមហ៊ុន ឬក្រុមហ៊ុនពាក់ព័ន្ធ។

**ប្រធានប្រតិបត្តិការ** (Head of Operations) : សំដៅដល់រូបវន្តបុគ្គលដែលត្រួតពិនិត្យប្រតិបត្តិការនៃការបើកគណនី កម្រិតឥណទាន និងដាក់កម្រិតលើការជួញដូរ ការទូទាត់នៃការជួញដូរ បញ្ជូនរបាយការណ៍ទៅប្រតិបត្តិករ និងគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) និងត្រួតពិនិត្យប្រតិបត្តិការផ្សេងទៀតនៅក្នុងការិយាល័យជួរក្រោយ។

**ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ** (Head of Securities Representatives) : សំដៅដល់រូបវន្តបុគ្គលដែលមានអំណាចក្នុងការណែនាំ និងត្រួតពិនិត្យភ្នាក់ងារក្រុមហ៊ុនមូលបត្រនៅក្នុងក្រុមហ៊ុនមូលបត្រ។

**ប្រាក់តម្កល់ធានារបស់ក្រុមហ៊ុនមូលបត្រ ឬប្រាក់តម្កល់ធានាអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ** (Security Bond in Relation to a Securities Firm) : សំដៅដល់ចំនួនទឹកប្រាក់ ដែលក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់ សម្រាប់ជាប្រាក់ធានាដែលត្រូវយកមកប្រើប្រាស់ ក្នុងករណីដែលក្រុមហ៊ុនមូលបត្រនោះ មិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុបាន រួមទាំងពុំមានលទ្ធភាពក្នុងការផ្តល់ជូនអតិថិជនវិញនូវមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិដទៃទៀត ដែលអតិថិជនបានប្រគល់ឱ្យក្រុមហ៊ុនមូលបត្រថែរក្សាទុក។

**មូលធនសុទ្ធរបស់ក្រុមហ៊ុនមូលបត្រ** (Net Capital of a Securities Firm) : សំដៅ

ដល់ទ្រព្យសកម្មចរន្ត រួមទាំងមូលនិធិរបស់ភាគហ៊ុនិកនៅក្នុងក្រុមហ៊ុន និងអចលនទ្រព្យរបស់ក្រុមហ៊ុននោះ ដោយដកចេញនូវ ៖

ក-ទ្រព្យសកម្មមិនមែនចរន្ត និងចំណាយដែលបានបង់មុនរបស់ក្រុមហ៊ុន។

ខ-ឥណទានដែលគ្មានការធានា និងប្រាក់បុរេប្រទានដែលផ្តល់ដោយក្រុមហ៊ុន ហើយដែលត្រូវបានចាត់ទុកជាទ្រព្យសកម្មចរន្ត។

គ-ចំនួនទឹកប្រាក់ដែលត្រូវបង់ដោយអភិបាល សហកម្មសិទ្ធិករ ឬសមាគារីទៅឱ្យក្រុមហ៊ុន ហើយដែលត្រូវបានចាត់ទុកជាទ្រព្យសកម្មចរន្ត។

ឃ-តម្លៃលើសពីតម្លៃមូលបត្រ ដែលបានកត់ត្រាក្នុងបញ្ជី ដែលកាន់ទុកក្នុងគណនីផ្ទាល់ខ្លួនរបស់ក្រុមហ៊ុន ទៅតាមតម្លៃទីផ្សារ។

ង-ឱនភាពគណនីអតិថិជន ដោយដកចេញនូវសំវិធានធនបំណុលទារមិនបាន ឬពិបាកទារ ហើយរៀបចំក្នុងទម្រង់មួយទៅតាមការកំណត់របស់ **គ.ម.ក.**។

ច-សមាសធាតុផ្សេងទៀតក្នុងការគណនាមូលធនសុទ្ធរបស់ក្រុមហ៊ុនមូលបត្រត្រូវកំណត់ក្នុងប្រកាសដោយឡែករបស់ **គ.ម.ក.**។

**អនុក្រឹត្យ** (Sub-decree) : សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**អនុរូបសញ្ញា** (Composition) : សំដៅដល់កិច្ចព្រមព្រៀងជាផ្លូវការរវាងកូនបំណុល និងម្ចាស់បំណុល ដែលតាមរយៈកិច្ចព្រមព្រៀងនេះម្ចាស់បំណុលព្រមទទួលយកសំណងតិចជាងចំនួនទឹកប្រាក់ទាំងអស់ដែលជំពាក់។

**អ្នកវិនិយោគសាធារណៈ** (Public Investor) : សំដៅដល់សាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានសិទ្ធិទិញ ឬលក់មូលបត្រដែលបានបោះផ្សាយ និងធ្វើសំណើលក់ជាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជាដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ដែលមិនមែនជាសមាគារី ឬក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬនីតិបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុតនោះ។

**ឧបករណ៍តម្កល់ធានាអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ** (Security Instrument in Relation to a Securities Firm) : សំដៅដល់មូលបត្ររដ្ឋ ឬ/និងធនបត្ររបស់ធនាគារជាតិ

នៃកម្ពុជា ដែលក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់ សម្រាប់ធានាអាជីវកម្ម និងត្រូវបានយកមកប្រើប្រាស់ ក្នុងករណីដែលក្រុមហ៊ុនមូលបត្រនោះ មិនអាចបំពេញកាតព្វកិច្ចហិរញ្ញវត្ថុបាន រួមទាំងពុំមានលទ្ធភាពក្នុងការផ្តល់ជូនអតិថិជនវិញនូវមូលបត្រ មូលនិធិ ឬទ្រព្យសម្បត្តិដទៃទៀត ដែលអតិថិជនបានប្រគល់ឱ្យក្រុមហ៊ុនមូលបត្រថែរក្សាទុក។

## ជំពូកទី ២

## សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

**ប្រការ ៣.-**

ក្រុមហ៊ុនមូលបត្រអាចធ្វើអាជីវកម្មមូលបត្រដូចខាងក្រោម ៖

-អាជីវកម្មធានាទិញមូលបត្រ (Securities underwriting business)

-អាជីវកម្មជួញដូរមូលបត្រ (Securities dealing business)

-អាជីវកម្មជើងសាមូលបត្រ (Securities brokerage business)។

**ប្រការ ៤.-**

ក្រុមហ៊ុនមូលបត្រអាចធ្វើអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ និងអាជីវកម្មផ្សេងទៀតពាក់ព័ន្ធនឹងមូលបត្រដែលមានការអនុញ្ញាតពី **គ.ម.ក.**។ ចំពោះអាជីវកម្មផ្តល់ប្រឹក្សាវិនិ-យោគ ក្រុមហ៊ុនមូលបត្រមិនតម្រូវឱ្យមានអាជ្ញាបណ្ណដោយឡែកដូចមានចែងក្នុងជំពូកទី ៥ នៃប្រកាសនេះទេ ប៉ុន្តែក្រុមហ៊ុនមូលបត្រត្រូវមានភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគដែលទទួលបានអាជ្ញាបណ្ណដូចមានចែងក្នុងប្រការ ៤១ នៃប្រកាសនេះ។

**ប្រការ ៥.-**

អាជីវកម្មធានាទិញមូលបត្រ រួមមាន ៖

១-ផ្តល់ប្រឹក្សាសំខាន់លើការបោះផ្សាយលក់មូលបត្រជាសាធារណៈ ដូចជាការដាក់តម្លៃមូលបត្រ (Pricing) ការកំណត់ទំហំទឹកប្រាក់ (Issue amount) និងចំនួនមូលបត្រ

(Number of securities to be issued) នៃសំណើបោះផ្សាយលក់មូលបត្រ និងការកំណត់ពេលវេលានៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ (Distribution timeline) ជាដើម។

២-ទិញមូលបត្រទាំងអស់ ឬមួយផ្នែកពីក្រុមហ៊ុនបោះផ្សាយមូលបត្រក្នុងគោលដៅចែកចាយ ឬលក់បន្ត។

៣-ទិញមូលបត្រដែលលក់មិនអស់ នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ក្នុងគោលដៅធានានូវភាពជោគជ័យនៃការបោះផ្សាយ។

៤-ចាត់ចែងរៀបចំដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ ឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬចូលរួមដោយផ្ទាល់ ឬមិនផ្ទាល់នៅក្នុងដំណើរការបោះផ្សាយលក់មូលបត្រជាសាធារណៈ។

**ប្រការ ៦.-**

អាជីវកម្មជួញដូរមូលបត្រ គឺជាការជួញដូរមូលបត្រលើគណនីផ្ទាល់ខ្លួន ដោយរ៉ាប់រងហានិភ័យដោយខ្លួនឯង។

**ប្រការ ៧.-**

អាជីវកម្មជើងសាមូលបត្រ គឺជាការទិញ ឬលក់មូលបត្រក្នុងនាម និងតាមបញ្ជាអតិថិជនរបស់ខ្លួន ដោយទទួលបាននូវកម្រៃជើងសា។

**ប្រការ ៨.-**

អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ រួមមាន ÷

១-ការផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រដល់អ្នកវិនិយោគសាធារណៈ ដោយទទួលបាននូវកម្រៃសេវា។

២-ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនដល់អ្នកវិនិយោគសាធារណៈ។

**ប្រការ ៩.-**

បុគ្គលដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រពី **គ.ម.ក.** ធ្វើជាក្រុមហ៊ុនធានាទិញមូលបត្រ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ អាចធ្វើសកម្មភាពអាជីវកម្មមូលបត្រដូចមានចែងក្នុងប្រការ ៥ ប្រការ ៦ ប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះ។

**ប្រការ ១០.-**

បុគ្គលដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រពី **គ.ម.ក.** ធ្វើជាពាណិជ្ជករមូលបត្រ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ អាចធ្វើសកម្មភាពអាជីវកម្មមូលបត្រដូចមានចែងក្នុងប្រការ ៦ ប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះប៉ុណ្ណោះ។

**ប្រការ ១១.-**

បុគ្គលដែលទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនមូលបត្រពី **គ.ម.ក.** ធ្វើជាឈ្មួញជើងសាមូលបត្រ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ អាចធ្វើសកម្មភាពអាជីវកម្មមូលបត្រដូចមានចែងក្នុងប្រការ ៧ និងប្រការ ៨ នៃប្រកាសនេះប៉ុណ្ណោះ។

**ប្រការ ១២.-**

រូបវន្តបុគ្គលដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ អាចធ្វើសកម្មភាពអាជីវកម្មមូលបត្រដូចខាងក្រោម ÷

១-បើក និងគ្រប់គ្រងគណនីឱ្យអតិថិជនរបស់ក្រុមហ៊ុនមូលបត្រ។

២-ទទួល និងអនុវត្តបញ្ជាទិញ ឬលក់មូលបត្រក្នុងនាមអតិថិជនរបស់ក្រុមហ៊ុនមូលបត្រ។

៣-បំពេញនូវមុខងារ ឬសកម្មភាពផ្សេងទៀតតាមការឯកភាពរបស់ក្រុមហ៊ុនមូលបត្រដែលតម្រូវឱ្យមានអាជ្ញាបណ្ណ។

## ជំពូកទី ៣
## ការផ្ដល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ

**ប្រការ ១៣.-**

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រ មានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណដែលសុំបន្តដោយក្រុមហ៊ុនមូលបត្រ មានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។

**ប្រការ ១៤.-**

បុគ្គលដែលមានបំណងធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនៅ **គ.ម.ក.** ទៅតាមទម្រង់បែបបទដែលបានកំណត់។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ក្រុមហ៊ុនមូលបត្រត្រូវដាក់ពាក្យស្នើសុំនៅ **គ.ម.ក.** ទៅតាមទម្រង់បែបបទដែលបានកំណត់ ក្នុងរយៈពេលយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។ ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ **គ.ម.ក.** នៅក្រោយកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ត្រូវបានចាត់ទុកជាការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មី។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់ចែងការចុះពិនិត្យដល់ទីកន្លែង ដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬពាក្យស្នើសុំបន្តអាជ្ញាបណ្ណ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្ដល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីសេចក្ដីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំអាជ្ញាបណ្ណដូចមានចែងក្នុងកថា-

ខណ្ឌទី ១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ១២០ (មួយរយម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំពេញលេញ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីសេចក្តីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំបន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំពេញលេញ។

### ប្រការ ១៥.-

ករណីបុគ្គលដាក់ពាក្យស្នើសុំ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយបុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងដំណើរការក្តីនៃបទមជ្ឈិម ឬបទឧក្រិដ្ឋ ហើយអគ្គនាយកនៃ **គ.ម.ក.** យល់ឃើញថា ដំណើរការក្តីនេះអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ការពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ អគ្គនាយកនៃ **គ.ម.ក.** អាចផ្អាកការពិនិត្យនេះជាបណ្តោះអាសន្នរហូតដល់ភាពស្អាតស្អំត្រូវបានបញ្ជាក់។

### ប្រការ ១៦.-

ដើម្បីការពារផលប្រយោជន៍សាធារណៈ អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការជាមួយនឹងបុគ្គលដាក់ពាក្យស្នើសុំ ដូចខាងក្រោម ៖

១-ផ្សព្វផ្សាយជាសាធារណៈ អំពីគោលបំណងនៃការដាក់ពាក្យស្នើសុំ និងព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងបុគ្គលដាក់ពាក្យស្នើសុំនោះ តាមរយៈសារព័ត៌មាន គេហទំព័ររបស់ **គ.ម.ក.** និង/ឬមធ្យោបាយផ្សេងទៀត ដើម្បីប្រមូលមតិយោបល់។

២-ស្នើសុំអាជ្ញាធរ និងភាគីពាក់ព័ន្ធ ឱ្យផ្តល់មតិយោបល់លើសំណើសុំអាជ្ញាបណ្ណ។

៣-ផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ នូវរាល់មតិយោបល់ដែលប្រមូលបាន ដែលអាចខូចផលប្រយោជន៍ដល់បុគ្គលដាក់ពាក្យស្នើសុំនោះ ដោយយោងតាមចំណុចទី ១ និងទី ២ នៃប្រការនេះ និងត្រូវផ្តល់ឱកាសដល់បុគ្គលដាក់

ពាក្យស្នើសុំ ដើម្បីធ្វើការបកស្រាយបំភ្លឺអំពីបញ្ហាពាក់ព័ន្ធក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលជូនដំណឹងដល់បុគ្គលដាក់ពាក្យស្នើសុំ។

៤-បើកការពិគ្រោះយោបល់ជាសាធារណៈ នៅពេលដែលការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនេះ អាចមានឥទ្ធិពលយ៉ាងខ្លាំងដល់ទីផ្សារមូលបត្រ។

**ប្រការ ១៧.–**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា ៤០ នៃអនុក្រឹត្យ។

២-ត្រូវបំពេញលក្ខខណ្ឌតម្រូវមូលធន និងត្រូវដាក់នៅធនាគារជាតិនៃកម្ពុជា នូវប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មដែលកំណត់ដោយ **គ.ម.ក.** ទៅតាមប្រភេទអាជីវកម្មមូលបត្រនីមួយៗដូចខាងក្រោម ៖

ក-ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមាចំនួន ៤០.០០០.០០០.០០០ (សែសិបពាន់លាន) រៀល ដែលក្នុងនោះមូលធនសុទ្ធអប្បបរមាចំនួន ២.០០០.០០០.០០០ (ពីរពាន់លាន) រៀល និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មចំនួន ៤.០០០.០០០.០០០ (បួនពាន់លាន) រៀល។

ខ-ដើម្បីធ្វើអាជីវកម្មជាពាណិជ្ជករមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមាចំនួន ២៥.០០០.០០០.០០០ (ម្ភៃប្រាំពាន់លាន) រៀល ដែលក្នុងនោះមូលធនសុទ្ធអប្បបរមាចំនួន ១.២៥០.០០០.០០០ (មួយពាន់ពីររយហាសិបលាន) រៀល និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មចំនួន ២.៥០០.០០០.០០០ (ពីរពាន់ប្រាំរយលាន) រៀល។

គ-ដើម្បីធ្វើអាជីវកម្មជាឈ្មួញជើងសាមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានមូលធនអប្បបរមាចំនួន ៦.០០០.០០០.០០០ (ប្រាំមួយពាន់លាន) រៀល ដែលក្នុងនោះមូលធនសុទ្ធអប្បបរមាចំនួន ៣០០.០០០.០០០ (បីរយលាន) រៀល និងត្រូវដាក់ប្រាក់

តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មចំនួន ១.០០០.០០០.០០០ (មួយពាន់លាន) រៀល។

៣-ត្រូវបំពេញលក្ខខណ្ឌតម្រូវធនធានមនុស្សដូចខាងក្រោម ÷

ក-ត្រូវមានយ៉ាងហោចណាស់នាយកប្រតិបត្តិ និងអភិបាល ឬសហកម្មសិទ្ធិករម្នាក់ដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ១៨ នៃប្រកាសនេះ។

ខ-ត្រូវមានយ៉ាងហោចណាស់ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រម្នាក់ដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ១៩ នៃប្រកាសនេះ។

គ-ត្រូវមានប្រធានប្រតិបត្តិការដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ២០ នៃប្រកាសនេះ។

ឃ-ត្រូវមានបុគ្គលិកជំនាញផ្នែកច្បាប់ ដែលបានបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ ២១ នៃប្រកាសនេះ។

ង-ត្រូវមានបុគ្គលិកជំនាញទៅតាមទំហំនៃប្រភេទអាជីវកម្មនីមួយៗដូចមានចែងក្នុងប្រការ ២៥ នៃប្រកាសនេះ។

ច-ត្រូវមានបុគ្គលិកជាន់ខ្ពស់ និងនិយោជិតផ្សេងទៀត។

៤-ត្រូវមានប្រព័ន្ធ ឧបករណ៍ សម្ភារៈជារូបវន្ត ដូចមានចែងក្នុងប្រការ ២៧ នៃប្រកាសនេះ។

៥-ត្រូវរៀបចំផែនការអាជីវកម្មសម្រាប់រយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៦-ត្រូវបំពេញលក្ខខណ្ឌនៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង ដូចខាងក្រោម ÷

ក-លទ្ធផលរួមនៃការវាយតម្លៃត្រូវមានកម្រិតល្អ ឬល្អណាស់ដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ខ-ពិន្ទុនៃការវាយតម្លៃលើធាតុនីមួយៗ ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ មិនត្រូវលើសពី ២,៤ ឡើយ។

៧-ត្រូវមានផែនការគ្រប់គ្រងហានិភ័យដែលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងដែលអាចអនុវត្តបាន ដើម្បីគ្រប់គ្រងហានិភ័យដែលអាចកើតមាន។

៨-មិនធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនមូលបត្រ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់តុលាការថាពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននេះ។

៩-មិនធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនមូលបត្រ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនមូលបត្រ ឬស្ថាប័នហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថា ពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

១០-មិនធ្លាប់ជាបុគ្គលជាប់ពាក់ព័ន្ធនឹងនីតិវិធីដូចជា ការក្ស័យធន ការជំរះបញ្ជី អនុរូបសញ្ញា ឬនីតិវិធីផ្សេងៗទៀតនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

**ប្រការ ១៨.–**

នាយកប្រតិបត្តិ និងអភិបាល ឬសហកម្មសិទ្ធិករដូចដែលមានចែងក្នុងចំណុចទី ៣ (ក) នៃប្រការ ១៧ នៃប្រកាសនេះ ត្រូវមានចំណេះដឹង ឬមានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មមូលបត្រ ឬវិស័យហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ និងត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

**ប្រការ ១៩.–**

ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រដូចដែលមានចែងក្នុងចំណុចទី ៣ (ខ) នៃប្រការ ១៧ នៃប្រកាសនេះ ត្រូវមានបទពិសោធន៍ពាក់ព័ន្ធនឹងអាជីវកម្មក្នុងវិស័យហិរញ្ញវត្ថុយ៉ាងតិច

តិច ០៣ (បី) ឆ្នាំ ដើម្បីដឹកនាំភ្នាក់ងារក្រុមហ៊ុនមូលបត្រ។ ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវមានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

**ប្រការ ២០.–**

ប្រធានប្រតិបត្តិការដូចមានចែងក្នុងចំណុចទី ៣ (គ) នៃប្រការ ១៧ នៃប្រកាសនេះ ត្រូវមានបទពិសោធន៍យ៉ាងហោចណាស់មួយក្នុងចំណោមបទពិសោធន៍ដូចខាងក្រោម ÷

១-ធ្លាប់បម្រើការងារនៅក្នុងតំណែងគ្រប់គ្រងជាន់ខ្ពស់រយៈពេលយ៉ាងតិច ០២ (ពីរ) ឆ្នាំ នៅក្នុងក្រុមហ៊ុនដែលធ្វើអាជីវកម្មក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

២-ធ្លាប់បម្រើការងារនៅក្នុងតំណែងគ្រប់គ្រងថ្នាក់កណ្តាលរយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ នៅក្នុងក្រុមហ៊ុនដែលធ្វើអាជីវកម្មក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

៣-ធ្លាប់ជាអ្នកចូលរួមនៅក្នុងទីផ្សារមូលបត្រណាមួយរយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ។

**ប្រការ ២១.–**

បុគ្គលិកជំនាញផ្នែកច្បាប់ដូចមានចែងក្នុងចំណុចទី ៣ (ឃ) នៃប្រការ ១៧ នៃប្រកាសនេះ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ ឬលិខិតបញ្ជាក់ជំនាញវិជ្ជាជីវៈពាក់ព័ន្ធផ្នែកច្បាប់ និងមានបទពិសោធន៍ការងារក្នុងវិស័យហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ។

**ប្រការ ២២.–**

បេក្ខជនធ្វើជាប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ត្រូវចូលរួមវគ្គបណ្តុះបណ្តាល និង/ឬការប្រលងដែលរៀបចំដោយ **គ.ម.ក.** ហើយលទ្ធផលប្រលងមានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ប្រកាសលទ្ធផលប្រលងនេះ។ មុនពេលលទ្ធផលប្រលងអស់សុពលភាព ប្រធានប្រតិបត្តិការ និងបុគ្គលិក

ជំនាញផ្នែកច្បាប់ត្រូវចូលរួមវគ្គបណ្តុះបណ្តាល ឬការប្រលងឡើងវិញដែលរៀបចំឡើងដោយ **គ.ម.ក.** ដើម្បីរក្សាគុណវុឌ្ឍិរបស់ខ្លួន។

**ប្រការ ២៣.–**

ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់មិនត្រូវបានអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រឡើយ ដើម្បីចៀសវាងនូវទំនាស់ផលប្រយោជន៍។

**ប្រការ ២៤.–**

ក្រុមហ៊ុនមូលបត្រដែលមានអាជ្ញាបណ្ណ ត្រូវសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរនាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់។ ប្រសិនបើតំណែងសម្រាប់នាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រធានប្រតិបត្តិការ ឬបុគ្គលិកជំនាញផ្នែកច្បាប់នៅទំនេរ ក្រុមហ៊ុនមូលបត្រត្រូវជ្រើសរើសបេក្ខជនថ្មីក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនៅទំនេរ។

**ប្រការ ២៥.–**

យោងតាមចំណុចទី ៣ (ង) នៃប្រការ **១៧** នៃប្រកាសនេះ បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានបុគ្គលិកជំនាញដែលមានបទពិសោធន៍យ៉ាងហោចណាស់មួយក្នុងចំណោមបទពិសោធន៍ដូចខាងក្រោម ÷

១-បុគ្គលិកដែលមានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុយ៉ាងតិច ០៣ (បី) ឆ្នាំ។

២-បុគ្គលិកដែលបានប្រលងបញ្ចប់វគ្គសិក្សាជំនាញវិជ្ជាជីវៈមូលបត្រ ឬវគ្គបណ្តុះបណ្តាល ដែលរៀបចំដោយ **គ.ម.ក.** ។

៣-បុគ្គលិកដែលអាចត្រូវបានចាត់ទុកថាមានបទពិសោធន៍ ឬគុណវុឌ្ឍិប្រហាក់ប្រហែលនឹងចំណុចទី ១ ឬទី ២ នៃកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនមូលបត្រត្រូវគិតពិចារណាលើចំនួនបុគ្គលិកជំនាញ ស្របតាមកថាខណ្ឌទី ១ នៃប្រការនេះ ឱ្យសមាមាត្រទៅនឹងប្រភេទ និងទំហំអាជីវកម្មដែលត្រូវធ្វើ ដើម្បីបំពេញភារកិច្ចពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ សវនកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យ ការស្រាវជ្រាវ និងផ្នែកជំនាញផ្សេងទៀត។

**ប្រការ ២៦.-**

គ្រប់បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ក្រុមហ៊ុនមូលបត្រដូចមានចែងក្នុងចំណុចទី ៣ (ច) នៃប្រការ ១៧ នៃប្រកាសនេះ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-មិនមែនជាអនីតិជន ឬបុគ្គលអសមត្ថភាព។

២-មិនមែនជាបុគ្គលដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៣-មានលក្ខណសម្បត្តិ និងអត្តចរិតល្អដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ។

៤-មិនធ្លាប់ជាបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតនៃក្រុមហ៊ុននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ដែលអាជ្ញាបណ្ណ ឬការអនុញ្ញាតរបស់ក្រុមហ៊ុននោះត្រូវបានដកហូតក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណ ឬការអនុញ្ញាតរបស់ក្រុមហ៊ុននោះត្រូវបានដកហូត លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថា ពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

៥-មិនធ្លាប់ជាបុគ្គលដែលត្រូវបានបណ្តេញចេញពីក្រុមហ៊ុនមូលបត្រនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៦-មិនធ្លាប់ជាបុគ្គលិកជាន់ខ្ពស់ ឬនិយោជិតដែលធ្លាប់ត្រូវបានព្យួរភារកិច្ច ឬត្រូវបានដាក់ទណ្ឌកម្មវិន័យដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

**ប្រការ ២៧.–**

តាមចំណុចទី ៤ នៃប្រការ ១៧ នៃប្រកាសនេះ បុគ្គលដាក់ពាក្យស្នើសុំត្រូវមាន ប្រព័ន្ធ ឧបករណ៍ និងសម្ភារៈ ដូចខាងក្រោម ÷

១-ត្រូវរៀបចំប្រព័ន្ធកុំព្យូទ័រ សម្រាប់ធ្វើអាជីវកម្មដែលសុំអាជ្ញាបណ្ណឱ្យមានលក្ខណៈ ស្ថិរភាព និងសុវត្ថិភាព និងមិនមានវិសមិតភាពជាមួយប្រព័ន្ធកុំព្យូទ័ររបស់ប្រតិបត្តិករ ទីផ្សារមូលបត្រដែលបុគ្គលដាក់ពាក្យស្នើសុំនោះជាសមាជិក ឬជាអ្នកចូលរួមក្នុងទីផ្សារ។

២-ត្រូវមានប្រព័ន្ធកុំព្យូទ័រសម្រាប់ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង។

៣-ត្រូវមានប្រព័ន្ធដែលមានសមត្ថភាពគ្រប់គ្រាន់ អាចទទួលបញ្ជាទិញ-លក់មូល-បត្រដែលរំពឹងទុកនាពេលអនាគត និងត្រូវធ្វើតេស្តសាកល្បងប្រព័ន្ធនោះឱ្យបានត្រឹមត្រូវ។

៤-ត្រូវរៀបចំវិធានការសុវត្ថិភាព ដើម្បីទប់ស្កាត់សាធារណជនពីខាងក្រៅដែលមិន មានការអនុញ្ញាតឱ្យចូលក្នុងកន្លែងហាមឃាត់។

៥-ត្រូវជំឡើងឱ្យបានពេញលេញនូវប្រព័ន្ធទ្រទ្រង់ (Backup System) និងប្រព័ន្ធដែល អាចការពារភាពលើសហួសសមត្ថភាព (Exceeded Capacity) ឬការខូចប្រព័ន្ធ (System Failure) និងដែលអាចដោះស្រាយរាល់បញ្ហាដែលអាចកើតមាន។

ក្រុមហ៊ុនមូលបត្រត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ **គ.ម.ក.** ក្នុងការ បំពេញភារកិច្ចត្រួតពិនិត្យលើប្រព័ន្ធ ឧបករណ៍ និងសម្ភារៈចម្បងរបស់ក្រុមហ៊ុន។

**ប្រការ ២៨.–**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណ របស់បុគ្គលដាក់ពាក្យស្នើសុំ ដោយផ្អែកលើមូលហេតុដូចខាងក្រោម ÷

១-ការដាក់ពាក្យស្នើសុំមិនបានធ្វើឡើងស្របតាមប្រការ ១៤ នៃប្រកាសនេះ។

២-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញលក្ខខណ្ឌតម្រូវដែលមានចែងក្នុងប្រការ ១៧ នៃប្រកាសនេះ។

៣-បុគ្គលដាក់ពាក្យស្នើសុំមិនបានគោរពតាមលក្ខខណ្ឌតម្រូវ ឬសេចក្តីណែនាំផ្សេង ទៀតដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ ពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំ។

៤-ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំ បានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

៥-បុគ្គលដាក់ពាក្យស្នើសុំស្ថិតក្នុងស្ថានភាពឈានទៅរកការបញ្ឈប់ ឬការរំលាយអាជីវកម្ម។

៦-សេចក្ដីសម្រេចរបស់តុលាការ ដែលតម្រូវឱ្យបុគ្គលដាក់ពាក្យស្នើសុំទូទាត់សងបំណុល មិនត្រូវបានអនុវត្តទាំងស្រុង ឬមួយផ្នែកដោយបុគ្គលដាក់ពាក្យស្នើសុំនោះ។

៧-បុគ្គលដាក់ពាក្យស្នើសុំ អភិបាល ឬសហកម្មសិទ្ធិករណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ។

ខ-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិដែលការពារសាធារណជនឱ្យចៀសផុតពីការខាតបង់ផ្នែកហិរញ្ញវត្ថុ ដោយសារតែភាពមិនស្មោះត្រង់ ឬអសមត្ថភាព ឬការប្រព្រឹត្តមិនត្រឹមត្រូវរបស់បុគ្គលនោះក្នុងការផ្ដល់សេវាហិរញ្ញវត្ថុ ឬការគ្រប់គ្រងក្រុមហ៊ុន។

គ-បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្ដីសម្រេចរបស់ខ្លួន។

ឃ-បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ង-ស្ដែងចេញនូវភាពមិនអាចធ្វើសកម្មភាព ដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្ដិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្ដីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ច-ស្ដែងចេញនូវភាពមិនអាចធ្វើអាជីវកម្មបាន ក្រោមលក្ខខណ្ឌអាជ្ញាបណ្ណប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌។

៨-អភិបាល ឬសហកម្មសិទ្ធិករណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់បុគ្គលដាក់ពាក្យស្នើសុំ ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជាក្នុង

រយៈពេល ០៥ (ប្រាំ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៩-ស្ថានភាពហិរញ្ញវត្ថុ ឬវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ មិនទាន់មានលក្ខណៈគ្រប់គ្រាន់។

១០-នៅពេលកើតមានហេតុការណ៍ណាមួយដែលអាច ៖

ក-នាំឱ្យបុគ្គលដាក់ពាក្យស្នើសុំ អភិបាល ឬសហកម្មសិទ្ធិករណាម្នាក់ នាយកប្រតិបត្តិ អ្នកគ្រប់គ្រង ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ របស់បុគ្គលដាក់ពាក្យស្នើសុំ មិនអាចធ្វើអាជីវកម្មបានត្រឹមត្រូវ។

ខ-ឆ្លុះបញ្ចាំងពីភាពមិនអាចជឿជាក់បានលើវិធីធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំ។

១១-បុគ្គលដាក់ពាក្យស្នើសុំ មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

**ប្រការ ២៩.-**

ក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណ ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

**ប្រការ ៣០.-**

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការដូចមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ចំពោះអ្នកកាន់អាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនមូលបត្រ ប្រសិនបើអ្នកកាន់អាជ្ញាបណ្ណ ៖

១-ស្ថិតក្នុងស្ថានភាពត្រូវបញ្ឈប់ ឬរំលាយអាជីវកម្ម។

២-បញ្ឈប់ដំណើរការ ឬមិនអាចធ្វើអាជីវកម្មទាំងអស់ ឬអាជីវកម្មណាមួយដែលទទួលបានអាជ្ញាបណ្ណក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែជាប់គ្នា។

៣-មិនអនុវត្តតាមលក្ខខណ្ឌតម្រូវណាមួយដែលមានចែងក្នុងប្រការ ១៧ នៃប្រកាសនេះ។

៤-បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌ ឬការដាក់កំហិតលើអាជ្ញាបណ្ណ ឬសេចក្តីណែនាំណាមួយរបស់អគ្គនាយកនៃ **គ.ម.ក.** ដែលស្ថិតនៅក្រោមច្បាប់ អនុក្រឹត្យ និង ប្រកាសនេះ។

៥-បានប្រព្រឹត្តល្មើសនឹងវិធានរបស់ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធផាត់ទាត់ និងទូទាត់ ឬប្រតិបត្តិកររក្សាទុកមូលបត្រ។

៦-បានប្រព្រឹត្តល្មើសនឹងប្រការ ២៤ នៃប្រកាសនេះ។

៧-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ករណីអគ្គនាយកនៃ **គ.ម.ក.** បានចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាបន្ទាន់ តាមរយៈការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ ដល់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និង អតិថិជនទាំងអស់របស់ខ្លួន អំពីវិធានការទាំងនោះ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

ក្រុមហ៊ុនមូលបត្រដែលអាជ្ញាបណ្ណរបស់ខ្លួនត្រូវបានព្យួរ ឬដកហូត ចាត់ទុកថាគ្មានអាជ្ញាបណ្ណ ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណនោះត្រូវបានព្យួរ ឬដកហូត។

## ជំពូកទី ៤
## ការផ្តល់អាជ្ញាបណ្ណដល់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ

**ប្រការ ៣១.-**

អាជ្ញាបណ្ណរបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ត្រូវមានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណនោះ។

អាជ្ញាបណ្ណដែលសុំបន្តដោយភ្នាក់ងារក្រុមហ៊ុនមូលបត្រ មានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។

**ប្រការ ៣២.-**

គ្រប់បុគ្គលដែលមានបំណងធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ

ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនៅ **គ.ម.ក.** ទៅតាមទម្រង់បែបបទដែលបានកំណត់។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវដាក់ពាក្យស្នើសុំនៅ **គ.ម.ក.** ទៅតាមទម្រង់បែបបទដែលបានកំណត់ ក្នុងរយៈពេលយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។ ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ **គ.ម.ក.** នៅក្រោយកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ត្រូវបានចាត់ទុកជាការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មី។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីសេចក្តីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំអាជ្ញាបណ្ណនៅក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំពេញលេញ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីសេចក្តីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំបន្តអាជ្ញាបណ្ណនៅក្នុងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំពេញលេញ។

**ប្រការ ៣៣.-**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-បំពេញតាមគ្រប់លក្ខខណ្ឌតម្រូវដែលមានចែងក្នុងមាត្រា ៤១ នៃអនុក្រឹត្យ។

២-ជានីតិជនដែលតាំងទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម ៖

ក-មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាក្នុងជំនាញពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលនៅក្នុងវិស័យហិរញ្ញវត្ថុ។

ខ-មានលិខិតបញ្ជាក់ជំនាញវិជ្ជាជីវៈពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ និងមានបទពិសោធន៍យ៉ាងតិច ០៣ (បី) ឆ្នាំ នៅក្នុងទីផ្សារហិរញ្ញវត្ថុ។

គ-ធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្នុងរយៈពេលយ៉ាងតិច ០៣ (បី) ឆ្នាំ ពីយុត្តាធិការដែលទទួលស្គាល់ដោយ **គ.ម.ក.** ។

៤-ឆ្លងកាត់ការប្រលងដែលរៀបចំឡើងដោយ **គ.ម.ក.** ហើយលទ្ធផលប្រលងមានសុពលភាព ០២ (ពីរ) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ប្រកាសលទ្ធផលប្រលង។

៥-មិនធ្លាប់ធ្វើជាមន្ត្រី ឬសមាជិកនៃ **គ.ម.ក.** ឬជាបុគ្គលិកជាន់ខ្ពស់ ឬសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់ប្រតិបត្តិករ ក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៦-បំពេញលក្ខខណ្ឌដែលមានចែងក្នុងចំណុចទី ៨ ដល់ទី ១០ នៃប្រការ ១៧ នៃប្រកាសនេះ។

**ប្រការ ៣៤.-**

ស្របតាមចំណុចទី ៤ នៃប្រការ ៣៣ នៃប្រកាសនេះ បុគ្គលដាក់ពាក្យស្នើសុំ ឬអ្នកកាន់អាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ត្រូវឆ្លងកាត់ការប្រលងឡើងវិញ ឬចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំឡើងដោយ **គ.ម.ក.** មុនពេលលទ្ធផលប្រលងអស់សុពល-ភាព ដើម្បីរក្សាគុណវុឌ្ឍិរបស់ខ្លួន។

**ប្រការ ៣៥.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណរបស់បុគ្គលដាក់ពាក្យស្នើសុំ ដោយផ្អែកលើមូលហេតុដូចខាងក្រោម ÷

១-ការដាក់ពាក្យស្នើសុំមិនបានធ្វើឡើងស្របតាមប្រការ ៣២ នៃប្រកាសនេះ។

២-បុគ្គលដាក់ពាក្យស្នើសុំមិនបានបំពេញលក្ខខណ្ឌតម្រូវដែលមានចែងក្នុងប្រការ ៣៣ នៃប្រកាសនេះ។

៣-មានមូលហេតុដូចមានចែងក្នុងចំណុចទី៣ ទី៤ ទី៦ ទី៧ ទី១០ ឬទី១១ នៃប្រការ ២៨ នៃប្រកាសនេះ។

**ប្រការ ៣៦.-**

ភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណ ត្រូវចាប់ផ្តើមធ្វើសកម្មភាពអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

**ប្រការ ៣៧.-**

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការដូចដែលមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ ចំពោះអ្នកកាន់អាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រសិនបើ ÷

១-អ្នកកាន់អាជ្ញាបណ្ណទទួលមរណភាព ឬក្លាយជាជនអសមត្ថភាព។

២-អ្នកកាន់អាជ្ញាបណ្ណបញ្ឈប់ ឬមិនអាចធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងរយៈពេល ០៣ (បី) ខែជាប់គ្នា។

៣-អាជ្ញាបណ្ណនៃក្រុមហ៊ុនមូលបត្ររបស់ភ្នាក់ងារនោះត្រូវបានព្យួរ ឬដកហូត។

៤-អ្នកកាន់អាជ្ញាបណ្ណមិនអនុវត្តតាមលក្ខខណ្ឌតម្រូវណាមួយដែលមានចែងក្នុងប្រការ ៣៣ នៃប្រកាសនេះ។

៥-អ្នកកាន់អាជ្ញាបណ្ណបានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌ ឬការដាក់កំហិតលើអាជ្ញាបណ្ណ ឬសេចក្តីណែនាំណាមួយរបស់អគ្គនាយកនៃ **គ.ម.ក.** ដែលស្ថិតនៅក្រោមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

៦-អ្នកកាន់អាជ្ញាបណ្ណបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ករណីអគ្គនាយកនៃ **គ.ម.ក.** បានចាត់វិធានការដែលមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាបន្ទាន់ដល់អតិថិជនទាំងអស់របស់ក្រុមហ៊ុនមូលបត្រ តាមរយៈការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ អំពីវិធានការទាំងនោះ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

ភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលអាជ្ញាបណ្ណរបស់ខ្លួនត្រូវបានព្យួរ ឬដកហូត ចាត់ទុក

ថាគ្មានអាជ្ញាបណ្ណ ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណត្រូវបានព្យួរ ឬដកហូត។

## ជំពូកទី ៥
## ការផ្តល់អាជ្ញាបណ្ណដល់ទីប្រឹក្សាវិនិយោគ

**ប្រការ ៣៨.-**

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ មានសុពលភាព ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណដែលសុំបន្តដោយក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ មានសុពលភាព ០៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។

**ប្រការ ៣៩.-**

បុគ្គលដែលមានបំណងធ្វើជាក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ឬធ្វើជាភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនៅ **គ.ម.ក.** ទៅតាមទម្រង់បែបបទដែលបានកំណត់។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ត្រូវដាក់ពាក្យស្នើសុំនៅ **គ.ម.ក.** ទៅតាមទម្រង់បែបបទដែលបានកំណត់ក្នុងរយៈពេលមិនតិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព។ ការដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ **គ.ម.ក.** នៅក្រោយកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ត្រូវបានចាត់ទុកជាការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មី។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីសេចក្តីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំពេញលេញ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដល់បុគ្គលដាក់ពាក្យស្នើសុំ អំពីសេចក្តីយល់ព្រម ឬបដិសេធលើពាក្យស្នើសុំបន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថា-ខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាល-បរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំពេញលេញ។

**ប្រការ ៤០.-**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនទីប្រឹក្សាវិនិយោគ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែជាក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឬច្បាប់ផ្សេងទៀត។

២-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានមូលធនអប្បបរមា ៤០០.០០០.០០០ (បួនរយលាន) រៀល ដែលក្នុងនោះត្រូវដាក់នៅធនាគារជាតិនៃកម្ពុជា នូវប្រាក់តម្កល់ធានាអាជីវកម្ម និង/ឬឧបករណ៍តម្កល់ធានាអាជីវកម្មដែលកំណត់ដោយ **គ.ម.ក.** ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល។

៣-បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគលើមូលបត្រ ដែលត្រូវទទួលអាជ្ញាបណ្ណស្របតាមប្រកាសនេះ។

៤-នាយកប្រតិបត្តិ និងអភិបាល ឬ សហកម្មសិទ្ធិករ របស់បុគ្គលដាក់ពាក្យស្នើសុំ ÷

ក-មិនធ្លាប់ត្រូវបានប្រកាសក្ស័យធន ឬ ប្រសិនបើនាយកប្រតិបត្តិ និងអភិបាល ឬសហកម្មសិទ្ធិករណាម្នាក់ធ្លាប់ត្រូវបានប្រកាសក្ស័យធន កាលបរិច្ឆេទប្រកាសក្ស័យធនមិនត្រូវមានរយៈពេលតិចជាង ០៥ (ប្រាំ) ឆ្នាំឡើយ គិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ខ-មិនធ្លាប់ធ្វើជានាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ របស់ក្រុមហ៊ុនដែលធ្លាប់ត្រូវបានបដិសេធការផ្តល់អាជ្ញាបណ្ណដោយអគ្គនាយកនៃ **គ.ម.ក.** ឬស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពី **គ.ម.ក.**។

គ-មិនធ្លាប់ធ្វើជានាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ របស់ក្រុម-ហ៊ុន ដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះត្រូវបានដកហូតយកវិញដោយអគ្គនាយកនៃ **គ.ម.ក.** ឬស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពី **គ.ម.ក.**។

៥-នាយកប្រតិបត្តិ និងអភិបាល ឬសហកម្មសិទ្ធិករ និងនិយោជិតគ្រប់រូបដែលបំពេញភារកិច្ចពាក់ព័ន្ធនឹងការកាន់អាជ្ញាបណ្ណ របស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវតែមានលក្ខណសម្បត្តិ និងអត្តចរិតល្អដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យ។

៦-យ៉ាងហោចណាស់មានអភិបាលម្នាក់ ឬសហកម្មសិទ្ធិករម្នាក់ និងនិយោជិតម្នាក់របស់បុគ្គលដាក់ពាក្យស្នើសុំ ត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីទទួលអាជ្ញាបណ្ណធ្វើជាភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ។

៧-បុគ្គលដាក់ពាក្យស្នើសុំត្រូវមានអគារ និងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងមានបំពាក់ឧបករណ៍គ្រប់គ្រាន់ ដើម្បីផ្តល់សេវាកម្មសមស្របដល់អតិថិជននូវសកម្មភាពនានាដែលមានចែងក្នុងអាជ្ញាបណ្ណ ឬមានភស្តុតាងដែលអាចទទួលយកបានដោយអគ្គនាយកនៃ **គ.ម.ក.** ដែលបញ្ជាក់ថា អគារ និងបរិវេណនោះនឹងអាចប្រើប្រាស់បាន ប្រសិនបើអាជ្ញាបណ្ណត្រូវបានផ្តល់ឱ្យ។

៨-បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដែលមានចែងក្នុងចំណុចទី ៨ ដល់ទី ១០ នៃប្រការ ១៧ នៃប្រកាសនេះ។

**ប្រការ ៤១.-**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគក្នុងក្របខណ្ឌក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ រូបវន្តបុគ្គលដែលស្នើសុំ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

១-ជានីតិជនដែលតាំងទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-មានលក្ខណសម្បត្តិ និងអត្តចរិតល្អដូចមានចែងក្នុងប្រការ ៤២ នៃអនុក្រឹត្យ។

៣-មានបទពិសោធន៍ការងារពាក់ព័ន្ធនឹងវិស័យមូលបត្រយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ ដែលក្នុងនោះ យ៉ាងតិច ០៣ (បី) ឆ្នាំពាក់ព័ន្ធនឹងការផ្តល់ប្រឹក្សាវិនិយោគលើមូលបត្រ។

៤-ផ្តល់ជូនអគ្គនាយកនៃ **គ.ម.ក.** នូវការយល់ព្រមជាលាយលក្ខណ៍អក្សរ ពីក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគនោះបានទទួលយល់ព្រមឱ្យបុគ្គលនោះធ្វើជាភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគនៅក្នុងក្រុមហ៊ុន។

៥-បំពេញលក្ខខណ្ឌដែលមានចែងក្នុងចំណុចទី ៨ ដល់ទី ១០ នៃប្រការ ១៧ និងចំណុចទី ៤ និងទី ៥ នៃប្រការ ៣៣ នៃប្រកាសនេះ។

**ប្រការ ៤២.-**

ស្របតាមប្រការ ៤១ នៃប្រកាសនេះ បុគ្គលដាក់ពាក្យស្នើសុំ ឬអ្នកកាន់អាជ្ញាបណ្ណធ្វើជាភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ត្រូវឆ្លងកាត់ការប្រលង ឬចូលរួមវគ្គបណ្តុះបណ្តាលដែលរៀបចំដោយ **គ.ម.ក.** មុនកាលបរិច្ឆេទដែលលទ្ធផលប្រលងអស់សុពលភាព ដើម្បីរក្សាគុណវុឌ្ឍិរបស់ខ្លួន។

**ប្រការ ៤៣.-**

អគ្គនាយកនៃ **គ.ម.ក.** អាចបដិសេធលើពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណរបស់ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ដោយផ្អែកលើមូលហេតុដូចខាងក្រោម ៖

១-ពាក្យស្នើសុំមិនបានធ្វើឡើងស្របតាមប្រការ ៣៩ នៃប្រកាសនេះ។

២-បុគ្គលដាក់ពាក្យស្នើសុំមិនបានគោរពតាមលក្ខខណ្ឌតម្រូវដែលមានចែងក្នុងប្រការ ៤០ ឬប្រការ ៤១ នៃប្រកាសនេះ។

៣-មានមូលហេតុដូចមានចែងក្នុងចំណុចទី ៣ ដល់ទី ១១ នៃប្រការ ២៨ នៃប្រកាសនេះ។

**ប្រការ ៤៤.-**

ក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលទទួលបានអាជ្ញាបណ្ណ ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

ភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគដែលទទួលបានអាជ្ញាបណ្ណ ត្រូវចាប់ផ្ដើមធ្វើសកម្មភាពអាជីវកម្មក្នុងក្របខណ្ឌក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ខែ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

**ប្រការ ៤៥.-**

ក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណីដែលកើតចេញពីសកម្មភាពរបស់ភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគ ដែលទទួលបានការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រោមលក្ខខណ្ឌនៃអាជ្ញាបណ្ណរបស់ខ្លួន ឬធ្វើសកម្មភាពផ្សេងទៀតដែលទទួលបានការអនុញ្ញាតពីក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ។

សកម្មភាពរបស់ភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគ ដែលនាំឱ្យក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគទទួលខុសត្រូវចំពោះបណ្ដឹងរដ្ឋប្បវេណី រាប់បញ្ចូលទាំងការគេចវេះមិនចាត់វិធានការក្នុងស្ថានភាពជាក់ស្ដែងណាមួយផងដែរ។

សកម្មភាពរបស់ភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគ ដែលអនុញ្ញាតដោយក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ត្រូវគិតទាំងសកម្មភាពដែលទទួលបានការអនុញ្ញាតដោយតុណ្ហីភាព ដោយឈរលើមូលដ្ឋានដែលក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគដឹង ឬគួរតែដឹង ភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគនោះបានធ្វើសកម្មភាពនានា ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់ ឬបដិសេធសកម្មភាពទាំងនោះ។

**ប្រការ ៤៦.-**

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការដែលមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ចំពោះអ្នកកាន់អាជ្ញាបណ្ណធ្វើជាភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគ ប្រសិនបើ ÷

១-អ្នកកាន់អាជ្ញាបណ្ណទទួលមរណភាព ឬក្លាយជាជនអសមត្ថភាព។

២-អ្នកកាន់អាជ្ញាបណ្ណបញ្ឈប់ដំណើរការ ឬមិនអាចធ្វើសកម្មភាពអាជីវកម្មដែលទទួលបានអាជ្ញាបណ្ណក្នុងរយៈពេល ០៣ (បី) ខែជាប់គ្នា។

៣-អាជ្ញាបណ្ណនៃក្រុមហ៊ុនមូលបត្រ ឬទីប្រឹក្សាវិនិយោគរបស់ភ្នាក់ងារផ្ដល់ប្រឹក្សា

វិនិយោគនោះត្រូវបានព្យួរ ឬដកហូត។

៤-អ្នកកាន់អាជ្ញាបណ្ណមិនអនុវត្តតាមលក្ខខណ្ឌតម្រូវណាមួយដែលមានចែងក្នុងប្រការ ៤១ នៃប្រកាសនេះ។

៥-អ្នកកាន់អាជ្ញាបណ្ណបានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌ ឬការដាក់កំហិតលើអាជ្ញាបណ្ណ ឬសេចក្តីណែនាំណាមួយរបស់អគ្គនាយកនៃ **គ.ម.ក.** ដែលស្ថិតនៅក្រោមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

៦-អ្នកកាន់អាជ្ញាបណ្ណបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ករណីអគ្គនាយកនៃ **គ.ម.ក.** បានចាត់វិធានការដែលមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគត្រូវជូនដំណឹងជាបន្ទាន់ តាមរយៈការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ ដល់អតិថិជនទាំងអស់របស់ក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ដែលទទួលប្រឹក្សាវិនិយោគ អំពីវិធានការទាំងនោះ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគដែលអាជ្ញាបណ្ណរបស់ខ្លួនត្រូវបានព្យួរ ឬដកហូត ចាត់ទុកថាគ្មានអាជ្ញាបណ្ណ ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណត្រូវបានព្យួរ ឬដកហូត។

**ប្រការ ៤៧.-**

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់វិធានការដែលមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ចំពោះអ្នកកាន់អាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ប្រសិនបើអ្នកកាន់អាជ្ញាបណ្ណ ៖

១-ស្ថិតក្នុងស្ថានភាពត្រូវបញ្ឈប់ ឬរំលាយអាជីវកម្ម។

២-បញ្ឈប់ដំណើរការ ឬមិនអាចធ្វើសកម្មភាពអាជីវកម្មដែលទទួលបានអាជ្ញាបណ្ណក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែជាប់គ្នា។

៣-មិនអនុវត្តតាមលក្ខខណ្ឌតម្រូវណាមួយដែលមានចែងក្នុងប្រការ ៤០ នៃប្រកាសនេះ។

៤-បានប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌ ឬការដាក់កំហិតលើអាជ្ញាបណ្ណ ឬសេចក្តីណែនាំណាមួយរបស់អគ្គនាយកនៃ **គ.ម.ក.** ដែលស្ថិតនៅក្រោមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ។

៥-បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

ករណីអគ្គនាយកនៃ **គ.ម.ក.** បានចាត់វិធានការដែលមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគត្រូវជូនដំណឹងជាបន្ទាន់ តាមរយៈការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ ដល់ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និងអតិថិជនទាំងអស់របស់ខ្លួន អំពីវិធានការទាំងនោះ លើកលែងតែមានការកំណត់ផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

ក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលអាជ្ញាបណ្ណរបស់ខ្លួនត្រូវបានព្យួរ ឬដកហូត ចាត់ទុកថាគ្មានអាជ្ញាបណ្ណ ចាប់ពីកាលបរិច្ឆេទដែលអាជ្ញាបណ្ណត្រូវបានព្យួរ ឬដកហូត។

**ប្រការ ៤៨.-**

ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ឬក្រុមហ៊ុនមូលបត្រ ត្រូវយកកម្រៃសេវានៃការផ្តល់ប្រឹក្សាវិនិយោគតាមការកំណត់របស់ **គ.ម.ក.**។

## ជំពូកទី ៦
## កម្រៃក្នុងការផ្តល់អាជ្ញាបណ្ណ

**ប្រការ ៤៩.-**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មជាក្រុមហ៊ុនមូលបត្រ ត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងត្រូវបង់ថ្លៃអាជ្ញាបណ្ណនៅ **គ.ម.ក.** ទៅតាមប្រភេទអាជីវកម្មមូលបត្រដូចខាងក្រោម ÷

១-ជាសាច់ប្រាក់ចំនួន ៨០.០០០.០០០ (ប៉ែតសិបលាន) រៀល សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំដំបូង និង ១២០.០០០.០០០ (មួយរយម្ភៃលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ០៣ (បី) ឆ្នាំ ចំពោះអាជីវកម្មជាក្រុមហ៊ុនធានាទិញមូលបត្រ។

២-ជាសាច់ប្រាក់ចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំដំបូង និង ៩០.០០០.០០០ (កៅសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ០៣ (បី) ឆ្នាំ ចំពោះអាជីវកម្មជាពាណិជ្ជករមូលបត្រ។

៣-ជាសាច់ប្រាក់ចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំដំបូង និង ៦០.០០០.០០០ (ហុកសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ០៣ (បី) ឆ្នាំ ចំពោះអាជីវកម្មជាឈ្មួញជើងសាមូលបត្រ។

**ប្រការ ៥០.-**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើសកម្មភាពអាជីវកម្មជាភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបង់ថ្លៃអាជ្ញាបណ្ណនៅ **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ២.៥០០.០០០ (ពីរលានប្រាំសែន) រៀល សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំដំបូង និង ៣.៧៥០.០០០ (បីលានប្រាំពីរសែនហាសិបម៉ឺន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ០៣ (បី) ឆ្នាំ។

**ប្រការ ៥១.-**

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាក្រុមហ៊ុនទីប្រឹក្សាវិនិយោគត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបង់ថ្លៃអាជ្ញាបណ្ណនៅ **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ១០.០០០.០០០ (ដប់លាន) រៀលសម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំដំបូង និង ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ០៣ (បី) ឆ្នាំ។

បុគ្គលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជាសាច់ប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបង់ថ្លៃអាជ្ញាបណ្ណនៅ

**គ.ម.ក.** ជាសាច់ប្រាក់ចំនួន ១.៥០០.០០០ (មួយលានប្រាំសែន) រៀល សម្រាប់រយៈពេល ០២ (ពីរ) ឆ្នាំដំបូង និង ២.២៥០.០០០ (ពីរលានពីរសែនប្រាំម៉ឺន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ០៣ (បី) ឆ្នាំ។

**ប្រការ ៥២.-**

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិត ស្របប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីអាជ្ញាបណ្ណត្រូវបានបដិសេធមិនផ្តល់ឱ្យ ឬមិនបន្តឱ្យក៏ដោយ។

## ជំពូកទី ៧
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ៥៣.-**

ករណីបុគ្គលដាក់ពាក្យស្នើសុំមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណ បុគ្គលដាក់ពាក្យស្នើសុំត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ អំពីការកែប្រែនោះជាបន្ទាន់ទៅ **គ.ម.ក.**។

**ប្រការ ៥៤.-**

ករណីមានការកែប្រែបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណក្នុងអំឡុងពេលកំពុងពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ ឬពាក្យស្នើសុំបន្តអាជ្ញាបណ្ណ បទប្បញ្ញត្តិថ្មីនេះត្រូវអនុវត្តចំពោះពាក្យស្នើសុំដែលកំពុងពិនិត្យនោះ។

**ប្រការ ៥៥.-**

អគ្គនាយកនៃ **គ.ម.ក.** ត្រូវផ្សព្វផ្សាយជាសាធារណៈ តាមរយៈគេហទំព័ររបស់ **គ.ម.ក.** និង/ឬមធ្យោបាយផ្សេងទៀត អំពីការផ្តល់អាជ្ញាបណ្ណ ការបន្តអាជ្ញាបណ្ណ ឬ

ការចាត់វិធានការ និង/ឬការដាក់ទណ្ឌកម្មផ្សេងៗស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ លើកលែងតែមានការសម្រេចផ្សេងពីនេះដោយ **គ.ម.ក.**។

## ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**ប្រការ ៥៦.-**

ករណីក្រុមហ៊ុនមូលបត្រដែលទទួលបានអាជ្ញាបណ្ណដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ **គ.ម.ក.** តិចជាង ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ក្រុមហ៊ុនមូលបត្រនោះត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ០១ (មួយ) ថ្ងៃចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ករណីភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ដែលទទួលបានអាជ្ញាបណ្ណ ដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណទៅ **គ.ម.ក.** តិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគនោះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះក្នុង ០១ (មួយ) ថ្ងៃ ជាសាច់ប្រាក់ចំនួន ÷

- ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ
- ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ
- ២០០.០០០ (ពីររយពាន់) រៀល សម្រាប់ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ។

នៅពេលអាជ្ញាបណ្ណអស់សុពលភាព ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ត្រូវបញ្ឈប់អាជីវកម្មភ្លាម។ ករណីនៅតែបន្តអាជីវកម្ម ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សា

វិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៥៧.-**

បុគ្គលដែលមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** អនុលោមតាមមាត្រា ៣៧ នៃច្បាប់ ចំពោះការចាត់វិធានការលើមូលហេតុដូចមានកំណត់ក្នុងប្រការ ៣០ ប្រការ ៣៧ ប្រការ ៤៦ និងប្រការ ៤៧ នៃប្រកាសនេះ ត្រូវទទួលពិន័យអន្តរការណ៍ពី **គ.ម.ក.** តាមមាត្រា ៥៣ នៃច្បាប់។

**ប្រការ ៥៨.-**

គ្រប់បុគ្គលទាំងអស់ដែលប្រព្រឹត្តល្មើសនឹងប្រកាសនេះ ឬលក្ខខណ្ឌណាមួយដែលចែងដោយអនុលោមតាមប្រកាសនេះ គឺជាការប្រព្រឹត្តបទល្មើសដែលត្រូវទទួលពិន័យ និងផ្តន្ទាទោសទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**ប្រការ ៥៩.-**

ករណីដែល **គ.ម.ក.** មិនទាន់កំណត់អំពីការដាក់ឧបករណ៍តម្កល់ធានាអាជីវកម្មដូចមានចែងក្នុងប្រការ ១៧ និងប្រការ ៤០ នៃប្រកាសនេះ បុគ្គលដាក់ពាក្យស្នើសុំ ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មជាសាច់ប្រាក់សុទ្ធនៅធនាគារជាតិនៃកម្ពុជា។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**ប្រការ ៦០.-**

**គ.ម.ក.** អាចចេញសេចក្តីណែនាំ ស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្ត។

**ប្រការ ៦១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦២.-**

អគ្គនាយក អគ្គនាយករងនៃ **គ.ម.ក.** នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានកិច្ចការគតិយុត្ត នាយកដ្ឋាន អង្គភាពដទៃទៀតដែលចំណុះឱ្យ **គ.ម.ក.** និង បុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៩

**គាត ឈន់**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៦២

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធប្រកាសលេខ.................
ស្តីពីការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ
ចុះថ្ងៃទី ខែ ឆ្នាំ២០០៩
ស្តង់ដារវាយតម្លៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង

១-ធាតុដែលត្រូវវាយតម្លៃ

| ធាតុ (៣) | ធាតុរង (១២) |
|---|---|
| ១-ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង | -ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្សនៃការគ្រប់គ្រងហានិភ័យ<br>-ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្សនៃការត្រួតពិនិត្យផ្ទៃក្នុង<br>-ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្សនៃការិយាល័យជួរមុខ<br>-ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្សនៃការិយាល័យជួរក្រោយ |
| ២-នីតិវិធីនៃការគ្រប់គ្រងហា-និភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង | -វិធានសម្រាប់ការគ្រប់គ្រងហានិភ័យ<br>-វិធានសម្រាប់ការត្រួតពិនិត្យផ្ទៃក្នុង<br>-ផែនការ និង/ឬ ការអនុវត្តពាក់ព័ន្ធនឹងការគ្រប់គ្រង និងការវាស់វែងហានិភ័យនៅក្នុងអាជីវកម្ម<br>-ផែនការ និង/ឬ ការអនុវត្តពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុងនៅក្នុងអាជីវកម្ម<br>-ការចាត់វិធានការទប់ទល់ភាពអាសន្ន |
| ៣-ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ និងការ | -មូលដ្ឋានទិន្នន័យ (Database) និងប្រព័ន្ធកុំព្យូទ័រទាំងមូល |

| | |
|---|---|
| ត្រួតពិនិត្យផ្ទៃក្នុង | -ប្រព័ន្ធកុំព្យូទ័រសម្រាប់ការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង<br>-ស្ថិរភាព និងសុវត្ថិភាពនៃប្រព័ន្ធកុំព្យូទ័រ |

**២-វិធីវាយតម្លៃ**

ក-ធាតុរងនីមួយៗដូចមានចែងខាងលើ ត្រូវវាយតម្លៃដោយគិតលើលទ្ធផលនៃការពិនិត្យឯកសារ និងការពិនិត្យដល់ទីកន្លែង ទៅតាមស្តង់ដារនៃការវាយតម្លៃលម្អិតក្នុងធាតុនីមួយៗ។ ការវាយតម្លៃនេះត្រូវផ្អែកលើមាត្រដ្ឋានពិន្ទុដែលមានពី ១,០ ពិន្ទុដល់ ៥,០ ពិន្ទុ។

| ស្តង់ដារ | ល្អណាស់ | ល្អ | ធម្មតា | ខ្សោយ | គ្រោះថ្នាក់ |
|---|---|---|---|---|---|
| ពិន្ទុនៃការវាយតម្លៃ | ១,០-១,៤ | ១,៥-២,៤ | ២,៥-៣,៤ | ៣,៥-៤,៤ | ៤,៥-៥,០ |

ខ-ពិន្ទុរបស់ធាតុនីមួយៗ ត្រូវគណនាដោយប្រើរូបមន្តមធ្យមភាគធម្មតា (Simple Average) នៃពិន្ទុរបស់ធាតុរងនីមួយៗ។

គ-ពិន្ទុសរុបនៃការវាយតម្លៃ ត្រូវគណនាដោយប្រើរូបមន្តមធ្យមភាគតាមទម្ងន់ (Weighted Average) នៃពិន្ទុរបស់ធាតុនីមួយៗតាមរយៈទម្ងន់ដូចខាងក្រោម ÷

| ធាតុ | ការរៀបចំរចនាសម្ព័ន្ធ និងធនធានមនុស្សពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង | នីតិវិធីនៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង | ប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធនឹងការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង |
|---|---|---|---|
| ទម្ងន់ | ៣០% | ៤០% | ៣០% |

ឃ-លទ្ធផលរួមនៃការវាយតម្លៃត្រូវកំណត់ទៅតាមពិន្ទុសរុបនៃការវាយតម្លៃដូចខាងក្រោម ៖

| ពិន្ទុសរុបនៃការវាយតម្លៃ | ១,០-១,៤ | ១,៥-២,៤ | ២,៥-៣,៤ | ៣,៥-៤,៤ | ៤,៥-៥,០ |
|---|---|---|---|---|---|
| លទ្ធផលរួមនៃការវាយតម្លៃ | ល្អណាស់ | ល្អ | ធម្មតា | ខ្សោយ | គ្រោះថ្នាក់ |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មការមូលបត្រកម្ពុជា
SECURITIES AND EXCHANGE COMMISSION OF CAMBODIA

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ........០០៥/១១....គ.ម.ក ប្រ.ក.

# ប្រកាស
## ស្តីពី
## ក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ចុះថ្ងៃទី១០ ខែមករា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០១១

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១
Phone : 855-23-885-611
E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Fax : 855-23-885-622

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-គោលបំណង**

ប្រកាសនេះមានគោលបំណងកំណត់បទប្បញ្ញត្តិអំពីក្រមសីលធម៌វិជ្ជាជីវៈក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្ដល់ប្រឹក្សាវិនិយោគដែលធ្វើសកម្មភាពអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ២.-និយមន័យ**

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះ ត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្ដីពីការអនុវត្តច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ការអនុវត្តប្រសើរបំផុត** (Best Execution) ៖ សំដៅដល់កិច្ចខិតខំប្រឹងប្រែងដើម្បីទទួលបានសម្រាប់អតិថិជននូវថ្លៃប្រសើរបំផុតចំពោះទំហំ និងប្រភេទនៃការជួញដូរពាក់ព័ន្ធនឹងបញ្ជាដែលទទួលពីអតិថិជន។

**គណនីឆន្ទានុសិទ្ធិ** (Discretionary Account) ៖ សំដៅដល់គណនីរបស់អតិថិជនដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមានឆន្ទានុសិទ្ធិក្នុងការធ្វើសេចក្ដីសម្រេចចិត្តទិញ ឬលក់មូលបត្រដោយមិនចាំបាច់ទទួលបានបញ្ជាពីអតិថិជន។

**ការត្រួតពិនិត្យផ្ទៃក្នុង** (Internal Control) ៖ សំដៅដល់ប្រព័ន្ធ គោលនយោបាយ នីតិវិធី វិធាន និងការត្រួតពិនិត្យផ្ទៃក្នុងផ្សេងទៀតដែលអនុវត្តដើម្បីធានានូវការគោរពតាមច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

គ.ម.ក. (SECC) ៖ សំដៅដល់គណៈកម្មការមូលបត្រកម្ពុជា។

**ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ** (Licensed Firm) ៖ សំដៅដល់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើអាជីវកម្មមូលបត្រដូចមានកំណត់ក្នុងសន្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្ដីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ** (Licensed Representative) ៖ សំដៅដល់ភ្នាក់ងារដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា ដើម្បីធ្វើភ្នាក់ងាររបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ។

**លក្ខខណ្ឌអាជ្ញាបណ្ណ** (License Conditions) ៖ សំដៅដល់លក្ខខណ្ឌ ឬការកម្រិតផ្សេងទៀតដែល គ.ម.ក. បានដាក់ទៅលើលក្ខខណ្ឌអាជ្ញាបណ្ណរបស់ក្រុមហ៊ុន។

ប្រឹក្សាវិនិយោគ (Investment Advice) : សំដៅដល់ប្រឹក្សា ឬសេចក្តីថ្លែងយោបល់ ឬរបាយការណ៍ណាមួយដែល ÷

១- មានគោលបំណងជះឥទ្ធិពលដល់បុគ្គលម្នាក់ ឬច្រើននាក់ក្នុងការធ្វើសេចក្តីសម្រេចចិត្តលើមូលបត្រ ឬប្រភេទនៃមូលបត្រណាមួយ។

២- អាចមានគោលបំណងជះឥទ្ធិពលដូចមានចែងក្នុងចំណុច (១) ខាងលើ។

ប្រតិបត្តិការមូលបត្រ (Securities Transaction) : សំដៅលើការជួញដូរ ការលក់ ឬការដោះដូរមូលបត្រ។

អនុក្រឹត្យ (Anukret) : សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**កម្មវិធីប្រព័ន្ធជួញដូរ** (System Trading Program) : សំដៅដល់កម្មវិធីផ្នែកទន់របស់កុំព្យូទ័រដែលមិនគិតទៅដល់សេចក្តីវិនិច្ឆ័យដោយខ្លួនឯងរបស់អតិថិជនឡើយ ប៉ុន្តែវាផ្តល់នូវព័ត៌មានសម្រាប់ធ្វើការសម្រេចចិត្តលើប្រភេទជួញដូរ ពេលវេលានៃប្រតិបត្តិការ និងការដាក់តម្លៃជួញដូរជាដើម។

**ការទូទាត់ដោយផ្អែកតាមគុណសម្បត្តិ** (Merit Based Payment) : សំដៅដល់ការទូទាត់ដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណទទួលពីអតិថិជននៅក្នុងសំណងសម្រាប់សេវាកម្មរបស់ខ្លួន ដែលត្រូវបានគណនាដោយផ្អែកលើប្រាក់ចំណេញបានមកពីការវិនិយោគរបស់អតិថិជននោះ។

បញ្ជាមិនមែនអតិថិជន (Non-Client Order) : សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រដែលទទួលបានពី ឬផ្តួចផ្តើមដោយក្រុមហ៊ុនមូលបត្រសម្រាប់គណនីរបស់ ÷

១-សហកម្មសិទ្ធិករ អភិបាល បុគ្គលិកជាន់ខ្ពស់ ឬបុគ្គលដែលមានតំណែងប្រហាក់ប្រហែល ឬបុគ្គលមានគុណវុឌ្ឍិប្រហាក់ប្រហែលនៃក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនមូលបត្រ ឬ

២- និយោជិតនៃក្រុមហ៊ុនមូលបត្រ ប៉ុន្តែមិនរាប់បញ្ចូលគណនីក្រុមហ៊ុន។

**បញ្ជា** (Order) : សំដៅដល់បញ្ជាទិញ ឬលក់មូលបត្រ។

គណនីក្រុមហ៊ុន (Principal Account) : សំដៅដល់គណនីដែលក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធនៃក្រុមហ៊ុនមូលបត្រកាន់កាប់នូវផលប្រយោជន៍ផ្ទាល់ ឬមិនផ្ទាល់ជាជាងផលប្រយោជន៍កម្រៃជើងសាដែលទទួលពីប្រតិបត្តិការ។

**បុគ្គលិកជាន់ខ្ពស់** (Senior Staff) : សំដៅដល់បុគ្គលិកបម្រើការងារនៅក្នុងក្រុមហ៊ុនដែលមានតំណែងចាប់ពីប្រធានផ្នែករហូតដល់នាយកប្រតិបត្តិ រួមទាំងប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងសវនកម្មផ្ទៃក្នុង។

## ជំពូកទី ២
## គោលការណ៍អាជីវកម្ម

**ប្រការ ៣.-គោលការណ៍ទូទៅនៃអាជីវកម្ម**

ដើម្បីឱ្យអតិថិជនទទួលបានអត្ថប្រយោជន៍ជាអតិបរមា និងធានាឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវក្នុងការជួញដូរមូលបត្រនៅលើទីផ្សារ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណត្រូវ ÷

១-មានភាពសុចរិតក្នុងការប្រកបអាជីវកម្ម និងធ្វើការប្រកួតប្រជែងដោយស្មោះត្រង់។

២-ដំណើរការអាជីវកម្មប្រកបដោយជំនាញ សេចក្តីព្យាយាម និងការយកចិត្តទុកដាក់។

៣-យកចិត្តទុកដាក់ចំពោះការគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចការទទួលខុសត្រូវឱ្យមានប្រសិទ្ធភាពខ្ពស់ ដោយមានការគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យដែលសមស្រប។

៤-មានធនធានមនុស្ស និងមានបំពាក់ឧបករណ៍គ្រប់គ្រាន់ ព្រមទាំងមាននីតិវិធីដែលចាំបាច់សម្រាប់ប្រកបអាជីវកម្ម។

៥- រក្សាលក្ខខណ្ឌតម្រូវហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៦-បំពេញកាតព្វកិច្ចយ៉ាងយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិ និងប្រាក់របស់អតិថិជនឱ្យបានល្អ។

៧- បំពេញភារកិច្ចដោយគិតដល់ផលប្រយោជន៍របស់អតិថិជនជាចម្បង។

៨-ផ្តល់ប្រឹក្សាវិនិយោគទៅអតិថិជនឱ្យបានត្រឹមត្រូវ ដោយស្វែងយល់ឱ្យបានច្បាស់ពីព័ត៌មានរបស់អតិថិជន។

៩- ជូនដំណឹងដល់អតិថិជន អំពីព័ត៌មានចាំបាច់សម្រាប់អតិថិជនធ្វើការសម្រេចចិត្ត។

១០-ប្រុងប្រយ័ត្នកុំឱ្យកើតមានទំនាស់ផលប្រយោជន៍ជាមួយអតិថិជន។ ក្នុងករណី មិនអាចចៀសវាងបាន ក្រុមហ៊ុនត្រូវជូនដំណឹងជាមុនដល់អតិថិជននោះ ឬមានវិធានការសមស្របដើម្បីការពារដល់ផលប្រយោជន៍អតិថិជន។

១១- គោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ គ.ម.ក. និងត្រូវធានាថារាល់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគរបស់ក្រុមហ៊ុនគោរពច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ ព្រមទាំងបទប្បញ្ញត្តិផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

១២- រក្សាការសម្ងាត់ និងធានាថារាល់ភ្នាក់ងារបានទទួលអាជ្ញាបណ្ណ រក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់អតិថិជន និងមិនត្រូវផ្សព្វផ្សាយដល់តតិយជន លើកលែងតែមានការតម្រូវដោយច្បាប់ សេចក្តីសម្រេចរបស់តុលាការ អាជ្ញាធរមានសមត្ថកិច្ច គ.ម.ក. ឬការព្រមព្រៀងជាលាយលក្ខណ៍អក្សររបស់អតិថិជន។

## ជំពូកទី ៣
## គណនីអតិថិជន

### ប្រការ ៤.- ការបើកគណនីអតិថិជន

អតិថិជនអាចបើកគណនីសម្រាប់ប្រតិបត្តិការជួញដូរមូលបត្របានមួយប៉ុណ្ណោះ នៅក្រុមហ៊ុនមូលបត្រមួយ។

មុនពេលធ្វើប្រតិបត្តិការជាមួយអតិថិជន ឬក្នុងនាមអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវ ៖

១-បំពេញកាតព្វកិច្ចតាមច្បាប់ក្នុងការសិក្សាឱ្យបានច្បាស់លាស់ពីព័ត៌មានទាក់ទងនឹងអតិថិជន និងបំពេញតាមទម្រង់សុំបើកគណនីដែលមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

២-បំពេញ និងចុះកិច្ចព្រមព្រៀងជាមួយអតិថិជន ដោយអនុលោមតាមមាត្រា ៥៤ នៃអនុក្រឹត្យ និងប្រការ ៦ នៃប្រកាសនេះ។

### ប្រការ ៥.- ការអនុម័តការបើកគណនី

ក្រុមហ៊ុនមូលបត្រត្រូវចាត់តាំងអ្នកគ្រប់គ្រងគណនី ដើម្បីទទួលខុសត្រូវលើការអនុញ្ញាតឱ្យបើកគណនីថ្មី និងគ្រប់គ្រងប្រតិបត្តិការគណនី។

អតិថិជនអាចធ្វើប្រតិបត្តិការដំបូងលើគណនីនេះបាន លុះត្រាតែគណនីនេះត្រូវបានអនុញ្ញាតឱ្យបើកមុនយ៉ាងហោច ០១ (មួយ) ថ្ងៃនៃថ្ងៃធ្វើការ។

អ្នកគ្រប់គ្រងគណនីត្រូវធ្វើការអនុញ្ញាតលើការបើកគណនីជាលាយលក្ខណ៍អក្សរ និងត្រូវរក្សាកំណត់ត្រានៃការអនុញ្ញាត។

### ប្រការ ៦.-កិច្ចព្រមព្រៀងអតិថិជន

កិច្ចព្រមព្រៀងអតិថិជនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងមានហត្ថលេខាត្រឹមត្រូវរវាងអតិថិជន និងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណតាមទម្រង់កិច្ចព្រមព្រៀងអតិថិជនកំណត់ដោយ គ.ម.ក. ដូចមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ ភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណដែលទាក់ទងដោយផ្ទាល់ជាមួយអតិថិជនត្រូវពន្យល់ពីខ្លឹមសារនីមួយៗនៃកិច្ចព្រមព្រៀងដល់អតិថិជនមុនចុះហត្ថលេខាជាមួយអតិថិជន។

កិច្ចព្រមព្រៀងអតិថិជនត្រូវមាននិទ្ទេសអប្បរមាដូចខាងក្រោម ៖

១-ឈ្មោះ និងអាសយដ្ឋានរបស់អតិថិជន ដោយភ្ជាប់មកជាមួយនូវឯកសារថតចំលងជាភស្តុតាងដូចជាអត្តសញ្ញាណបណ្ណ លិខិតឆ្លងដែន អត្តសញ្ញាណវិនិយោគិនដែលទទួលបានពី គ.ម.ក. វិញ្ញាបនបត្រ

ចុះបញ្ជីពាណិជ្ជកម្ម ឯកសារស្តីអំពីសាជីវកម្ម ឬឯកសារផ្លូវការផ្សេងទៀតដែលបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជន។

២-នាមករណ៍ និងអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ។

៣-ស្ថានភាពអាជ្ញាបណ្ណបច្ចុប្បន្នរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ហើយត្រូវផ្តល់ព័ត៌មានអំពីប្រភេទអាជីវកម្មក្នុងក្របខណ្ឌនៃអាជ្ញាបណ្ណក្រុមហ៊ុនទទួលបាន។

៤-កាតព្វកិច្ចផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមករវាងក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងអតិថិជនអំពីរាល់ការកែប្រែព័ត៌មានដែលមានចែងក្នុងកិច្ចព្រមព្រៀងជាសារវន្ត។

៥-ការពិពណ៌នាពីប្រភេទសេវាកម្មដែលផ្តល់ជូនអតិថិជន ឬសេវាកម្មផ្សេងទៀតដែលមានសម្រាប់អតិថិជន។

៦-ការពិពណ៌នាពីចំណាយផ្សេងៗ និងមូលដ្ឋានសម្រាប់ទូទាត់ដែលជាបន្ទុករបស់អតិថិជន រួមមានកម្រៃជើងសាមូលបត្រ និងថ្លៃសេវាផ្សេងៗទៀត។

៧-សេចក្តីថ្លែងដែលបញ្ជាក់នូវកាលៈទេសៈណាដែលក្រុមហ៊ុនមូលបត្រធ្វើការជួញដូរក្នុងនាមក្រុមហ៊ុន (Principal) និងកាលៈទេសៈផ្សេងទៀតដែលក្រុមហ៊ុនមូលបត្រនឹងដើរតួជាភ្នាក់ងារ (Agent) របស់អតិថិជន ក្នុងករណីក្រុមហ៊ុនមូលបត្រទទួលអាជ្ញាបណ្ណជាពាណិជ្ជករមូលបត្រ និងជើងសាមូលបត្រ។

៨- សេចក្តីថ្លែងព័ត៌មានហានិភ័យពាក់ព័ន្ធនឹងប្រតិបត្តិការមូលបត្រដែលអតិថិជននឹងធ្វើការជួញដូរ។

៩-របាយការណ៍ដែលអតិថិជនត្រូវទទួលបាន និងវិធីសាស្ត្រនៃការទទួលរបាយការណ៍ និងការជូនដំណឹងអំពីប្រតិបត្តិការជួញដូរមូលបត្រ។

១០-សេចក្តីលម្អិតពីនីតិវិធីនៃការតវ៉ារបស់អតិថិជន។

១១-សេចក្តីលម្អិតពីផលប្រយោជន៍ ឬទំនាក់ទំនងណាមួយដែលអាចជះឥទ្ធិពលដល់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និង/ ឬ ភ្នាក់ងាររបស់ខ្លួន។

១២-សេចក្តីលម្អិតអំពីបែបបទដែលបញ្ជារបស់អតិថិជនត្រូវបានទទួលយក រួមមាននីតិវិធីសម្រាប់បញ្ជា ការបង្គាប់ផ្សេងទៀតដែលនឹងត្រូវអនុវត្ត របៀបដែលអតិថិជនធ្វើការកែប្រែនូវបញ្ជាដែលនឹងត្រូវអនុវត្ត និងសេចក្តីលម្អិតនៃបុគ្គលដែលត្រូវតែងតាំងដោយអតិថិជនធ្វើជាភ្នាក់ងារ ឬតាមលិខិតផ្ទេរសិទ្ធិក្នុងការធ្វើប្រតិបត្តិការជួញដូរមូលបត្រ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងារក្រុមហ៊ុនត្រូវអនុវត្តតាមកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិនេះ និងកិច្ចព្រមព្រៀងអតិថិជន ហើយកិច្ចព្រមព្រៀងមិនត្រូវមានការលុបចោល ឬដាក់កម្រិតលើសិទ្ធិរបស់អតិថិជន ឬកាតព្វកិច្ចរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណដែលទទួលស្គាល់ដោយច្បាប់។

**ប្រការ ៧.- ការបន្លំសិទ្ធិប្រើប្រាស់គណនីអតិថិជន**

ការប្រើប្រាស់គណនីអតិថិជនដោយគ្មានការអនុញ្ញាតត្រូវបានហាមឃាត់។

ដើម្បីចៀសវាងការប្រើប្រាស់គណនីអតិថិជនដោយគ្មានការអនុញ្ញាត ក្រុមហ៊ុនមូលបត្រត្រូវ ÷

១-មានគោលនយោបាយ និងនីតិវិធីច្បាស់លាស់ចំពោះការកែប្រែទិន្នន័យរបស់អតិថិជន។ ការស្នើសុំកែប្រែព័ត៌មានផ្ទាល់របស់អតិថិជន ឬសេចក្តីណែនាំលើការទូទាត់ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ ក្រុមហ៊ុនត្រូវមានកិច្ចខិតខំយ៉ាងសមស្របដើម្បីធានាថា សំណើកែប្រែនេះបានធ្វើឡើងដោយអតិថិជនពិតប្រាកដមែន។

២-ធានាថាគ្រប់ប្រតិបត្តិការលក់ត្រូវបានទូទាត់ទៅឱ្យអតិថិជនជាអ្នកលក់ និងមិនត្រូវទូទាត់ឱ្យបុគ្គលណាផ្សេងទេ វៀរលែងតែមានការអនុញ្ញាតដែលមានចែងក្នុងប្រការ ៤៤ នៃប្រកាសនេះ។

## ជំពូកទី ៤
## ការផ្តល់ប្រឹក្សាវិនិយោគ

**ប្រការ ៨.- ការផ្តល់ប្រឹក្សាវិនិយោគ**

ការផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជនត្រូវ ÷

១-ធ្វើឡើងដោយផ្អែកលើមូលដ្ឋានត្រឹមត្រូវ និងសមហេតុផល និង

២-ធ្វើឡើងដោយផ្អែកលើព័ត៌មានដែលផ្តល់ឱ្យដោយអតិថិជន ហើយត្រូវមានហេតុផលជាមូលដ្ឋានឆ្លុះបញ្ចាំងនូវព័ត៌មានគោលដូចមានកំណត់ក្នុងកថាខណ្ឌទី ២ នៃប្រការនេះ។

មុនពេលផ្តល់ប្រឹក្សាវិនិយោគ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគត្រូវគោរពតាមគោលការណ៍ [ស្គាល់អតិថិជនរបស់ខ្លួន (Know-Your-Client)] ដោយព្យាយាមស្វែងយល់ពីអតិថិជនតាមរយៈការពិគ្រោះយោបល់ដោយជួបផ្ទាល់ និងបំពេញតាមទម្រង់ពាក្យស្នើសុំការផ្តល់ប្រឹក្សាវិនិយោគដែលមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ដើម្បីទទួលបាននូវព័ត៌មានអតិថិជនដូចខាងក្រោម ÷

១-ស្ថានភាពហិរញ្ញវត្ថុ និងសេចក្តីត្រូវការរបស់អតិថិជន

២-គោលដៅវិនិយោគរបស់អតិថិជន

៣-ឥរិយាបទអតិថិជនចំពោះហានិភ័យដែលអាចកើតមាន និង

៤-បទពិសោធន៍ និងចំណេះដឹងនៃការវិនិយោគរបស់អតិថិជន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរជាមួយអតិថិជនអំពីព័ត៌មានដែលទទួលបាន និងត្រូវគ្រប់គ្រងថែរក្សាព័ត៌មាននោះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវមានវិធានការសមស្រប ដើម្បីធានាថាព័ត៌មានដែលទទួលបានពីអតិថិជនដូចមានចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះមានលក្ខណៈបច្ចុប្បន្នភាព។ ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងារទទួលបានអាជ្ញាបណ្ណបានដឹងថាមានការផ្លាស់ប្តូរនូវព័ត៌មានរបស់អតិថិជនព័ត៌មានរបស់អតិថិជនដែលប្រមូលបានក្នុងកថាខណ្ឌទី ២ នៃប្រការនេះត្រូវធ្វើបច្ចុប្បន្នកម្ម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំជាលាយលក្ខណ៍អក្សរជារៀងរាល់ឆ្នាំទៅអតិថិជន ឱ្យជូនដំណឹងដល់ក្រុមហ៊ុន ប្រសិនបើព័ត៌មានរបស់អតិថិជនមានការកែប្រែ។

ករណីអតិថិជនបដិសេធមិនព្រមផ្តល់ព័ត៌មានដែលមានលក្ខណៈបច្ចុប្បន្នភាពរបស់ខ្លួន តាមការស្នើសុំរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ក្រុមហ៊ុន ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគនឹងផ្តល់ប្រឹក្សាវិនិយោគដោយផ្អែកលើព័ត៌មានដែលបានផ្តល់ឱ្យក្រុមហ៊ុនតែប៉ុណ្ណោះ។ ស្របតាមកថាខណ្ឌទី ១ ដល់ ទី ៥ នៃប្រការនេះ ករណីក្រុមហ៊ុនដឹងថាការផ្តល់ប្រឹក្សាវិនិយោគផ្អែកលើព័ត៌មានមិនពេញលេញ ឬមិនត្រឹមត្រូវ ក្រុមហ៊ុនត្រូវដាស់តឿនអតិថិជន ក្នុងពេលដំណាលគ្នាដែលក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគ ថាមុននឹងអនុវត្តប្រឹក្សានោះ អតិថិជនគួរគិតពិចារណាលើភាពសមស្របនៃការផ្តល់ប្រឹក្សាចំពោះស្ថានភាពពាក់ព័ន្ធរបស់ខ្លួន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគមិនត្រូវផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជនដូចមានចែងក្នុងកថាខណ្ឌទី ៦ នៃប្រការនេះ ចំពោះមូលបត្រដូចខាងក្រោម ៖

១- មូលបត្រដែលមិនបានចុះបញ្ជីលក់នៅទីផ្សារមូលបត្រប្រតិស្រុត។

២- មូលបត្រដែលស្ថិតក្រោមការចាត់វិធានការរដ្ឋបាល ឬស្ថិតក្រោមការស៊ើបអង្កេត។

៣- សញ្ញាបណ្ណសាជីវកម្មដែលមានហានិភ័យខ្ពស់។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវដាក់ឱ្យដាច់ដោយឡែកនូវគណនីអតិថិជនដែលមិនមាន ឬមានបទពិសោធន៍តិចតួចលើប្រតិបត្តិការមូលបត្រ ហើយពឹងផ្អែកទាំងស្រុងទៅលើប្រឹក្សាវិនិយោគដែលផ្តល់ឱ្យដោយក្រុមហ៊ុននឹងត្រូវពិនិត្យជាទៀងទាត់នូវស្ថានភាពនៃការជួញដូររបស់អតិថិជនទាំងនោះ ដើម្បីធានាថាប្រឹក្សាវិនិយោគដែលផ្តល់ដោយភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគត្រូវបានធ្វើឡើងស្របតាមប្រកាសនេះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើត និងអនុវត្តត្រួតពិនិត្យផ្ទៃក្នុង ដើម្បីគោរពតាមគោលការណ៍ដែលមានក្នុងប្រការនេះ។

## ប្រការ ៩.- ការចៀសវាងទំនាស់ផលប្រយោជន៍ទាក់ទងនឹងការផ្តល់ប្រឹក្សាវិនិយោគ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធានាថាក្រុមហ៊ុនផ្ទាល់ និងភ្នាក់ងាររបស់ខ្លួន ៖

១- ត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវទំនាស់ផលប្រយោជន៍ជាសក្តានុពលរបស់ខ្លួនដែលអាចជះឥទ្ធិពលដល់ការផ្តល់ប្រឹក្សាវិនិយោគមិនលំអៀង មុនផ្តល់ប្រឹក្សាវិនិយោគដល់អតិថិជននោះ។

២-ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនមុននឹងផ្តល់ប្រឹក្សាវិនិយោគអំពីអត្ថប្រយោជន៍ដែលមានពាក់ព័ន្ធនឹងថ្លៃ ឬការជួញដូរមូលបត្រណាមួយដែលក្រុមហ៊ុន និង/ឬភ្នាក់ងាររបស់ខ្លួនបានទទួលដោយសារហេតុផលពិសេសដូចខាងក្រោម ÷

ក-កំពុងផ្តល់ ឬនឹងផ្តល់សេវាកម្មធានាទិញមូលបត្រដល់ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ។

ខ-កំពុងផ្តល់ ឬនឹងផ្តល់សេវាហិរញ្ញវត្ថុពាក់ព័ន្ធនឹងការរួមបញ្ចូល និងទិញដល់ក្រុមហ៊ុនបោះផ្សាយ ឬបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយរបស់មូលបត្រនោះ។

គ-កាន់កាប់មូលបត្រច្រើនជាង ០១ (មួយ) ភាគរយនៃក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ។

ឃ-កំពុងជួញដូរ ឬនឹងជួញដូរមូលបត្រនោះដោយក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងាររបស់ខ្លួន។

៣-មិនត្រូវទទួលផលប្រយោជន៍សេដ្ឋកិច្ច ឬផលប្រយោជន៍ផ្សេងទៀតពីក្រុមហ៊ុនបោះផ្សាយមូលបត្រដែលពាក់ព័ន្ធនឹងការផ្តល់ប្រឹក្សាវិនិយោគ ឬពីបុគ្គលពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយមូលបត្រនោះ លើកលែងតែមានការជូនដំណឹងជាមុនពីផលប្រយោជន៍នោះដល់អតិថិជន។

**ប្រការ ១០.- ការហាមឃាត់លើការជំរុញឱ្យធ្វើការជួញដូរច្រើនហួសហេតុ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវជំរុញឱ្យអតិថិជនជួញដូរមូលបត្រច្រើនហួសហេតុពីភាពចាំបាច់ដែលសមល្មមសម្រាប់ផលប្រយោជន៍អតិថិជន ដោយគិតពិចារណាលើកត្តាដូចខាងក្រោម ÷

១-កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗដែលបង់ដោយអតិថិជន។

២- គោលដៅវិនិយោគ ស្ថានភាពហិរញ្ញវត្ថុ សេចក្តីត្រូវការ និងស្ថានភាពជាក់ស្តែងរបស់អតិថិជន។

៣-កម្រិតនៃការយល់ដឹងរបស់អតិថិជនលើហានិភ័យដែលអាចកើតមានឡើង ចំពោះការជួញដូរមូលបត្រដោយផ្អែកលើចំណេះដឹង និង/ឬបទពិសោធន៍វិនិយោគរបស់អតិថិជន។

៤-សុពលភាពនៃការផ្តល់ប្រឹក្សាចំពោះការជួញដូរនីមួយៗ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវជ្រើសរើសយកគណនីដែលត្រូវបានជំរុញឱ្យមានការជួញដូរច្រើនហួសហេតុ និងត្រូវពិនិត្យគណនីអតិថិជននោះ ដើម្បីធានាថាការផ្តល់ប្រឹក្សាវិនិយោគបានអនុវត្តតាមគោលការណ៍ស្របតាមប្រកាសនេះ។ ក្នុងគោលបំណងនេះ ក្រុមហ៊ុនត្រូវរៀបចំត្រួតពិនិត្យផ្ទៃក្នុងសម្រាប់ធ្វើការជ្រើសរើសគណនីដែលមានការជួញដូរច្រើនហួសហេតុមកធ្វើអធិការកិច្ច។

**ប្រការ ១១.- គណនីឈ្មោះសិទ្ធិ**

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្ររបស់ខ្លួន មិនត្រូវធ្វើប្រតិបត្តិការគណនីឈ្មោះសិទ្ធិ ដោយគ្មានការអនុញ្ញាតពី គ.ម.ក.។ ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវទិញ ឬលក់មូលបត្រជំនួសអតិថិជនតាមតែបញ្ជាទិញ-លក់របស់អតិថិជនពាក់ព័ន្ធស្របតាមប្រកាសនេះ។

## ជំពូកទី ៥
## ការអនុវត្តការជួញដូរមូលបត្រ

**ប្រការ ១២.- បញ្ជាទិញ-លក់**

ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវអនុវត្តបញ្ជាទិញ-លក់ពីអតិថិជនឱ្យបានត្រឹមត្រូវ ទាន់ពេលវេលា និងមិនលំអៀង។

ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រអាចអនុវត្តបញ្ជាទិញ-លក់របស់អតិថិជន ក្នុងនាមអតិថិជនបានលុះត្រាតែ ÷

១-ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអតិថិជន ដើម្បីអនុវត្តប្រតិបត្តការជួញដូរ។

២-អតិថិជនមានប្រាក់គ្រប់គ្រាន់សម្រាប់ទូទាត់ប្រតិបត្តិការជួញដូរមូលបត្រ ក្នុងករណីជាបញ្ជាទិញ។

៣-អតិថិជនមានមូលបត្រគ្រប់គ្រាន់សម្រាប់ការទូទាត់ ក្នុងករណីជាបញ្ជាលក់។

បញ្ជាទិញ-លក់អាចធ្វើឡើងតាមរយៈឯកសារជាលាយលក្ខណ៍អក្សរ ឬជាសម្លេង ឬជាសារអេឡិកត្រូនិក ឬមធ្យោបាយអេឡិចត្រូនិកផ្សេងទៀត។ នៅពេលទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនមូលបត្រត្រូវធ្វើកំណត់ត្រាបញ្ជានោះក្នុងទម្រង់ជាឯកសារលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមប្រព័ន្ធអេឡិចត្រូនិច ដើម្បីផ្ទៀងផ្ទាត់បញ្ជារបស់អតិថិជន។ កំណត់ត្រានៃបញ្ជានោះ ត្រូវរក្សាជាប្រចាំថ្ងៃ និងយ៉ាងហោចណាស់ត្រូវបង្ហាញពីឈ្មោះរបស់អតិថិជន ព័ត៌មានលម្អិតនៃបញ្ជា និងកាលបរិច្ឆេទ និងពេលវេលានៃការដាក់បញ្ជា។

ក្រុមហ៊ុនមូលបត្រត្រូវមានប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងសម្រាប់គ្រប់គ្រងបញ្ជាទិញ-លក់របស់អតិថិជនឱ្យបានត្រឹមត្រូវ អនុលោមតាមប្រការនេះ។

**ប្រការ ១៣.- បញ្ជាតាមប្រព័ន្ធអេឡិចត្រូនិក ឬតាមមធ្យោបាយផ្សេងទៀត**

បន្ថែមពីលើលក្ខខណ្ឌតម្រូវដែលមានចែងនៅប្រការ ១២ ក្រុមហ៊ុនមូលបត្រដែលទទួលបញ្ជាពីអតិថិជនតាមរយៈប្រព័ន្ធអេឡិចត្រូនិក តាមសម្លេង ឬជាសារអេឡិចត្រូនិក ឬតាមមធ្យោបាយផ្សេងទៀតក្រៅពីមធ្យោបាយជួបផ្ទាល់ ក្រុមហ៊ុនមូលបត្រត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមទាំងអស់ដូចខាងក្រោម ៖

១-ត្រូវឱ្យអតិថិជនយល់ដឹងនូវដំណើរការបញ្ជា និងការអនុវត្តបញ្ជាតាមមធ្យោបាយបញ្ជានីមួយៗ។

២-ធ្វើការបញ្ជាក់ឱ្យច្បាស់លាស់ថា បុគ្គលដែលបញ្ជានោះពិតជាមានសិទ្ធិក្នុងការបញ្ជា។

នៅពេលក្រុមហ៊ុនមូលបត្រអនុវត្តប្រតិបត្តិការជួញដូរតាមរយៈប្រព័ន្ធអេឡិចត្រូនិក តាមសម្លេង ឬមធ្យោបាយផ្សេងទៀតក្រៅពីមធ្យោបាយជួបផ្ទាល់ ក្រុមហ៊ុនត្រូវធានាថាប្រព័ន្ធនោះស្របតាមវិធាន និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ រួមទាំងលក្ខខណ្ឌតម្រូវទាក់ទងនឹងការរក្សាការសម្ងាត់របស់អតិថិជន។

ក្រុមហ៊ុនមូលបត្រត្រូវបង្កើតវិធានការសមស្រប ដើម្បីចៀសវាងស្ថានភាពដែលបញ្ជាមិនអាចត្រូវបានអនុវត្ត ដោយសារកត្តាមិនប្រក្រតីនៃប្រព័ន្ធអេឡិចត្រូនិក តាមសម្លេង ឬជាសារអេឡិចត្រូនិក ឬមធ្យោបាយផ្សេងទៀតក្រៅពីមធ្យោបាយជួបផ្ទាល់។

**ប្រការ ១៤.- បុគ្គលដែលមានសិទ្ធិបញ្ជា**

ក្រុមហ៊ុនមូលបត្រត្រូវទទួលបញ្ជាតែពីបុគ្គលដែលមានសិទ្ធិដូចខាងក្រោម ៖

១-អតិថិជនជាម្ចាស់គណនី។

២-អ្នកតំណាងដែលអតិថិជនបានជ្រើសរើសជាលាយលក្ខណ៍អក្សរនៅពេលបើកគណនី ឬអ្នកតំណាងដែលត្រូវបានជ្រើសរើសដោយអតិថិជននៅពេលបន្ទាប់ទៀត។

៣-បុគ្គលដែលបានទទួលសិទ្ធិស្របច្បាប់ក្នុងការបញ្ជាតាមលិខិតផ្ទេរសិទ្ធិ។

**ប្រការ ១៥.- ការហាមឃាត់ការទទួលបញ្ជាដែលផ្ទុយនឹងច្បាប់**

ក្រុមហ៊ុនមូលបត្រមិនត្រូវទទួលបញ្ជាដូចខាងក្រោម ៖

១-ពេលក្រុមហ៊ុនដឹងថាការជួញដូររបស់អតិថិជនល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

២-ក្រុមហ៊ុនមានមូលដ្ឋានបង្ហាញថា អតិថិជនមិនអាចទូទាត់ការជួញដូរបាន ដោយពិនិត្យលើប្រវត្តិនៃការជួញដូរ ឬចំនួនមូលបត្រដែលអតិថិជនមាន និងស្ថានភាពហិរញ្ញវត្ថុរបស់អតិថិជន។

៣-ពេលដែលមើលឃើញថា អតិថិជនមិនមានបំណងជួញដូរពិតប្រាកដ ដោយពិនិត្យមើលលើកត្តាដូចខាងក្រោម ៖

ក-ចំនួន និងទំហំជួញដូរជាមធ្យមនៃមូលបត្រចុះបញ្ជីលក់ នៅពេលបោះផ្សាយ។

ខ-ការបែងចែកភាពជាម្ចាស់កម្មសិទ្ធិនៃភាគហ៊ុនរបស់ក្រុមហ៊ុនដែលធ្វើការបោះផ្សាយមូលបត្រចុះបញ្ជី។

គ-ទំហំនៃទ្រព្យសម្បត្តិដាក់តម្កល់របស់អតិថិជន និងវិធីនៃការជួញដូរ។

ឃ-ស្ថានភាពនៃការដាក់តម្លៃនៅពេលបញ្ជា។

## ប្រការ ១៦.- ការអនុវត្តប្រសើរបំផុត

លើកលែងតែមានការណែនាំពីអតិថិជនទាក់ទងនឹងបញ្ជាទៅតាមថ្លៃទីផ្សារ ឬបញ្ជាកម្រិតថ្លៃ ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវធ្វើការដោយប្រឹងប្រែង និងប្រុងប្រយ័ត្នដើម្បីទទួលបាននូវការអនុវត្តប្រសើរបំផុតសម្រាប់បញ្ជារបស់អតិថិជន។ ដើម្បីទទួលបាននូវការអនុវត្តប្រសើរបំផុតសម្រាប់អតិថិជន ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

- ថ្លៃ និងបរិមាណ (Volume) នៃការលក់ចុងក្រោយ និងការជួញដូរពីមុន (Previous Trades)
- ទិសដៅឡើងចុះនៃទីផ្សារចំពោះមូលបត្រនោះ
- ទំហំ (Size) នៃសំណើទិញ និងសំណើលក់
- ទំហំនៃគំលាត (Spread) និង
- សន្ទនីយភាពនៃមូលបត្រនោះ។

នៅពេលក្រុមហ៊ុនមូលបត្រទទួលបញ្ជាពីអតិថិជន ក្រុមហ៊ុនត្រូវបញ្ជូនបញ្ជានោះទៅកាន់ទីផ្សារតាមលក្ខខណ្ឌនៃបញ្ជាភ្លាម និងមិនត្រូវបង្អង់បញ្ជា ដាក់បញ្ជារបស់អតិថិជនបញ្ចូលគ្នា ឬដាក់បញ្ជាជាកញ្ចប់។

ក្រុមហ៊ុនមូលបត្រអាចធ្វើការកែប្រែវិធីសាស្ត្រនៃបញ្ជា ដូចជាពេលវេលានៃការបញ្ជូនបញ្ជាទៅកាន់ទីផ្សារ និងវិធីសាស្ត្រនៃការដាក់ថ្លៃទិញ-លក់ និងអាចប្រតិបត្តិការបញ្ជាជាកញ្ចប់ ដោយដាក់បញ្ជារបស់អតិថិជនបញ្ចូលគ្នា ក្នុងករណីដែលក្រុមហ៊ុនទទួលបានការយល់ព្រមជាមុនជាលាយលក្ខណ៍អក្សរពីអតិថិជនលើការផ្លាស់ប្តូរវិធីសាស្ត្រនៃបញ្ជា ឬអនុវត្តន៍បញ្ជាជាកញ្ចប់ក្នុងគោលបំណងអនុវត្តប្រតិបត្តិការឱ្យបានប្រសើរបំផុត និងត្រូវអនុវត្តតាមការត្រួតពិនិត្យផ្ទៃក្នុងពាក់ព័ន្ធនឹងការកែប្រែវិធីសាស្ត្របញ្ជា ឬបញ្ជាជាកញ្ចប់ និងបញ្ជាក់ថាបានអនុវត្តការត្រួតពិនិត្យនេះដោយត្រឹមត្រូវ។

## ប្រការ ១៧.- ការហាមឃាត់ការជួញដូរមុន

មុនពេលអនុវត្តបញ្ជារបស់អតិថិជន ចំពោះការទិញ ឬលក់មូលបត្រដែលរំពឹងថាមានផលប៉ះពាល់លើថ្លៃទីផ្សារនៃមូលបត្រនោះ ក្រុមហ៊ុនទទួលបញ្ជាពីអតិថិជនមិនត្រូវ ៖

១-បញ្ជូនបញ្ជាក្នុងគណនីក្រុមហ៊ុន ឬបញ្ជាមិនមែនអតិថិជនទៅក្នុងទីផ្សារ ចំពោះការទិញ-លក់មូលបត្រពាក់ព័ន្ធនោះ

២-បញ្ចុះបញ្ចូលបុគ្គលផ្សេងទៀតឱ្យបញ្ជាទិញ-លក់មូលបត្រពាក់ព័ន្ធនោះ និង

៣-ផ្តល់ដំណឹងពីបញ្ជារបស់អតិថិជនទៅឱ្យបុគ្គលផ្សេងទៀតដែលមិនពាក់ព័ន្ធជាចាំបាច់ជាមួយនឹងដំណើការអាជីវកម្ម និងគោរពតាមលក្ខខណ្ឌតម្រូវទាក់ទងនឹងការរក្សាការសម្ងាត់របស់អតិថិជន។

**ប្រការ ១៨.- អាទិភាពរបស់អតិថិជន**

ក្រុមហ៊ុនមូលបត្រត្រូវផ្តល់អាទិភាពដល់បញ្ជាក្នុងគណនីអតិថិជន មុនបញ្ជាផ្សេងទៀតចំពោះមូលបត្រដូចគ្នា និងថ្លៃដូចគ្នា។

នៅពេលដែលអតិថិជនបញ្ជាទិញមូលបត្រ ក្រុមហ៊ុនមូលបត្រមិនត្រូវបញ្ជាទិញមូលបត្រនោះ ដោយប្រើគណនីផ្ទាល់របស់ក្រុមហ៊ុន ឬគណនីមិនមែនអតិថិជន ក្នុងថ្លៃដូច ឬទាបជាងថ្លៃដែលបញ្ជាដោយអតិថិជនឡើយ មុនពេលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត។

នៅពេលដែលអតិថិជនបញ្ជាលក់មូលបត្រ ក្រុមហ៊ុនមិនត្រូវបញ្ជាលក់មូលបត្រនោះ ដោយប្រើគណនីក្រុមហ៊ុន ឬគណនីមិនមែនអតិថិជនក្នុងថ្លៃដូច ឬខ្ពស់ជាងថ្លៃដែលបញ្ជាដោយអតិថិជនឡើយ មុនពេលបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត។

នៅពេលក្រុមហ៊ុនមូលបត្រជួញដូរមូលបត្រជាមួយអតិថិជនជាគូភាគី ក្រុមហ៊ុនមិនត្រូវផ្តល់លក្ខខណ្ឌជួញដូរមិនសមហេតុផលទៅកាន់អតិថិជនដោយបានដឹងពីស្ថានភាពទីផ្សារ និងចំណាយការជួញដូររបស់អតិថិជន។

## ជំពូកទី ៦
## ការផ្តល់ព័ត៌មានទៅកាន់អតិថិជន

**ប្រការ ១៩.- ការផ្តល់ព័ត៌មានមុនពេលធ្វើប្រតិបត្តិការ**

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរដូចខាងក្រោមទៅកាន់អតិថិជនរបស់ខ្លួន មុននឹងអនុវត្តការជួញដូរមូលបត្ររបស់អតិថិជន ÷

១- សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ។

២-កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ និងពន្ធទាក់ទងនឹងការជួញដូរដែលត្រូវបង់ដោយអតិថិជន ព្រមទាំងវិធីសាស្ត្រគណនា។

៣-ព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ ។

**ប្រការ ២០.- ការជូនដំណឹងពីហានិភ័យយុទ្ធសាស្ត្រនៃការជួញដូរ**

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវផ្តល់ព័ត៌មានប្រាសចាកពីការពិត ឬ បំផ្លើស អំពីដំណើរការវិនិយោគ (Investment Performance) ដែលពាក់ព័ន្ធនឹងការប្រើប្រាស់យុទ្ធសាស្ត្រនៃការជួញដូរ (Trading Strategies) វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរ (Sytem Trading Program) ដែលអាចនាំឱ្យអតិថិជនយល់ខុស។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជននូវរាល់ហានិភ័យទាក់ទងនឹងយុទ្ធសាស្ត្រនៃការជួញដូរ វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរ នៅពេលដែលផ្តល់ប្រឹក្សាដល់អតិថិជននោះ។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវផ្តល់ប្រឹក្សាពីយុទ្ធសាស្ត្រនៃការជួញដូរ វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរដល់អតិថិជន ប្រសិនបើយុទ្ធសាស្ត្រនៃការជួញដូរ វិធីសាស្ត្រ ឬកម្មវិធីប្រព័ន្ធជួញដូរមិនសមស្របចំពោះអតិថិជនដោយផ្អែកលើបទពិសោធន៍ជួញដូរ ចំណេះដឹង លក្ខខណ្ឌហិរញ្ញវត្ថុ សេចក្តីត្រូវការ និងគោលដៅវិនិយោគរបស់អតិថិជន។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវបញ្ចុះបញ្ចូលអតិថិជនឱ្យប្រើប្រាស់កម្មវិធីប្រព័ន្ធជួញដូរណាមួយ វៀរលែងតែមានហេតុផលជាមូលដ្ឋានដែលបញ្ជាក់ថា អតិថិជនមានការយល់ដឹងច្បាស់ពីកម្មវិធីប្រព័ន្ធជួញដូរនេះ ដោយផ្អែកលើចំណេះដឹង និងបទពិសោធន៍របស់អតិថិជននោះក្នុងការជួញដូរមូលបត្រ។

**ប្រការ ២១.- ការជូនដំណឹងប្រតិបត្តិការជួញដូរមូលបត្រ**

នៅពេលការបញ្ជារបស់អតិថិជនត្រូវបានអនុវត្ត ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជនឱ្យបានឆាប់បំផុតនៅថ្ងៃធ្វើប្រតិបត្តិការទាំងនោះ។ ការជូនដំណឹងត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម ÷

- ប្រភេទមូលបត្រ
- បរិមាណ
- ថ្លៃក្នុងមួយឯកត្តា និងតម្លៃសរុប
- កាលបរិច្ឆេទនៃការជួញដូរ
- កម្រៃជើងសា ថ្លៃសេវា លាភការផ្សេងៗ និងពន្ធទាក់ទងនឹងការជួញដូរដែលត្រូវបង់ដោយអតិថិជន
- ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រដែលធ្វើសកម្មភាពជួញដូរសម្រាប់អតិថិជន
- សេចក្តីបញ្ជាក់ក្រុមហ៊ុនមូលបត្រធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុន ឬក្នុងនាមអតិថិជន
- ឈ្មោះទីផ្សារមូលបត្រប្រតិស្រុតដែលធ្វើការជួញដូរ និង

- អំពីបញ្ហាដែលផ្អែកលើការអនុវត្តប្រសើរបំផុត (Best Execution) ឬបញ្ហាដែលផ្អែកលើការចង្កូលបង្ហាញរបស់អតិថិជន។

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រត្រូវមានការព្រមព្រៀងជាមួយអតិថិជនជាមុនអំពីវិធីសាស្ត្រនៃការជូនដំណឹង ដូចជាតាមប្រៃសណីយ៍ ការបញ្ជូនទៅដោយផ្ទាល់ ទូរស័ព្ទ ទូរសារ សារអេឡិចត្រូនិក ឬប្រព័ន្ធផ្សេងទៀត ហើយត្រូវធ្វើកំណត់ត្រា និងរក្សាទុកការជូនដំណឹងនេះ។

**ប្រការ ២២.- របាយការណ៍អតិថិជន** (Client Statement)

ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជនអំពីរបាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការនៃខែបន្ទាប់សម្រាប់គណនីដែលមានសកម្មភាពជួញដូរក្នុងអំឡុងខែនោះ។ របាយការណ៍ត្រូវបង្ហាញលម្អិតនូវព័ត៌មានដូចខាងក្រោម ÷

- សមតុល្យដើមគ្រា

- រាល់ឥណពន្ធ និងឥណទានក្នុងអំឡុងពេលប្រតិបត្តិការ

- សមតុល្យចុងគ្រា

-សេចក្តីលម្អិតពីការដាក់ប្រាក់តម្កល់ ឬការដកប្រាក់ក្នុងគណនីសាច់ប្រាក់របស់អតិថិជន ឬពាក់ព័ន្ធនឹងមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន ត្រូវរក្សាទុកនៅកន្លែងតម្កល់មានសុវត្ថិភាព និង

-បរិមាណ និងការបរិយាយពីមូលបត្រដែលបានជួញដូរ ឬបានទទួលក្នុងអំឡុងពេលប្រតិបត្តិការ។

ក្រុមហ៊ុនមូលបត្រត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរតាមរយៈមធ្យោបាយដែលបានព្រមព្រៀងជាមួយអតិថិជន។

សម្រាប់គណនីដែលគ្មានសកម្មភាពជួញដូរ ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់អតិថិជននូវរបាយការណ៍គណនី យ៉ាងហោចណាស់ មួយដងរៀងរាល់ ០៦ (ប្រាំមួយ)ខែនូវព័ត៌មានក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

## ជំពូកទី ៧
## អាកប្បកិរិយាដែលត្រូវហាមឃាត់ក្នុងការប្រកបអាជីវកម្ម

**ប្រការ ២៣.- ការហាមឃាត់ចំពោះភ្នាក់ងារដែលមិនមានអាជ្ញាបណ្ណ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវអនុញ្ញាតឱ្យបុគ្គលណាមួយ ធ្វើជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគក្នុងនាមក្រុមហ៊ុន ឬឧទ្ទេសនាមបុគ្គលទាំងនោះជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ

ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគក្នុងនាមក្រុមហ៊ុនឡើយ លើកលែងតែបុគ្គលនោះបំពេញតាមលក្ខខណ្ឌទាំងអស់ដូចខាងក្រោម÷

១-បុគ្គលនោះជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគបានទទួលអាជ្ញាបណ្ណពី គ.ម.ក. និងធ្វើសកម្មភាពតែក្នុងក្របខណ្ឌនៃអាជ្ញាបណ្ណរបស់ក្រុមហ៊ុន និងក្របខណ្ឌនៃអាជ្ញាបណ្ណភ្នាក់ងារប៉ុណ្ណោះ និង

២-បុគ្គលនោះមិនមែនជាភ្នាក់ងារនៃក្រុមហ៊ុនមូលបត្រ ឬក្រុមហ៊ុនទីប្រឹក្សាវិនិយោគដទៃទៀត។

**ប្រការ ២៤.- ការធានាទិញមូលបត្រ និងការសម្ងាត់នៃព័ត៌មាន**

ក្រុមហ៊ុនមូលបត្រមិនត្រូវយកព័ត៌មានសម្ងាត់របស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដើម្បីធ្វើការជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់ខ្លួន ឬណែនាំឥតិយជនឱ្យជួញដូរមូលបត្រទាំងនោះឡើយ។

នៅពេលដែលក្រុមហ៊ុនមូលបត្រទទួលបានអាជ្ញាបណ្ណសម្រាប់ធ្វើអាជីវកម្មធានាទិញមូលបត្រ ព្រមទាំងអាជីវកម្មមូលបត្រផ្សេងទៀត ក្រុមហ៊ុនត្រូវបែងចែកផ្នែកនីមួយៗឱ្យដាច់ដោយឡែកពីគ្នាស្របតាមប្រភេទអាជីវកម្ម ដើម្បីបែងចែកការទទួលខុសត្រូវច្បាស់លាស់ ប្រយោជន៍ធានាឱ្យបានថា ព័ត៌មានសម្ងាត់មិនត្រូវបានចែករំលែករវាងផ្នែកនីមួយៗ។

នៅពេលផ្នែកធានាទិញមូលបត្រនៃក្រុមហ៊ុនមូលបត្របានធ្វើការធានាទិញមូលបត្រ ផ្នែកផ្តល់ប្រឹក្សាវិនិយោគមិនត្រូវផ្តល់ប្រឹក្សាឱ្យជួញដូរមូលបត្រនោះ ក្នុងអំឡុងពេលចាប់ពីចុះកិច្ចសន្យាធានាទិញមូលបត្រជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្ររហូតដល់កាលបរិច្ឆេទបញ្ចប់កិច្ចសន្យាធានាទិញ។

បុគ្គលដែលជាអភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកមានសិទ្ធិកាន់កាប់ភាគហ៊ុនចំនួនច្រើនក្នុងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមួយមិនត្រូវកាន់កាប់តំណែងជាអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬកាន់កាប់ភាគហ៊ុនក្នុងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមួយផ្សេងទៀត។

**ប្រការ ២៥.- ការហាមឃាត់ការទូទាត់សងលើការខាតបង់**

ទោះបីដោយផ្ទាល់ ឬប្រយោលក្តី ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវ÷

-ផ្តល់ដល់អតិថិជននូវការធានាប្រាក់ចំណេញអប្បបរមាដែលពាក់ព័ន្ធនឹងការវិនិយោគមូលបត្រ ឬជួញដូរមូលបត្រ ឬ

-ទូទាត់សងទាំងអស់ ឬមួយផ្នែកនៃការខាតបង់ដែលកើតឡើងដោយសារការវិនិយោគមូលបត្រ ឬការជួញដូរមូលបត្ររបស់អតិថិជនតាមគ្រប់រូបភាពណាក៏ដោយរាប់បញ្ចូលទាំងការផ្តល់ជាប្រាក់ ឬការបញ្ចុះតម្លៃជើងសា ឬថ្លៃសេវា ឬការអនុវត្តប្រតិបត្តិការមូលបត្រណាមួយ។

ករណីមានការទូទាត់សងរបស់ក្រុមហ៊ុន ភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតត្រូវរាយការណ៍ជាមុនទៅបុគ្គលិកជំនាញផ្នែកច្បាប់។

**ប្រការ ២៦.- ការហាមឃាត់លើការផ្ដល់ឱ្យ និងការទទួលអំណោយ និងអត្ថប្រយោជន៍ផ្សេងៗ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្ដល់ឱ្យ ឬទទួលនូវគ្រឿងលើកទឹកចិត្ត អំណោយ ឬអត្ថប្រយោជន៍ផ្សេងៗទៅ ឬពីអតិថិជន ឬអតិថិជនសក្ដានុពល លើកលែងតែក្នុងករណីដូចខាងក្រោម÷

១- អត្ថប្រយោជន៍ដែលបានផ្ដល់នោះមិនប៉ះពាល់ដល់ឯករាជ្យភាពរបស់អ្នកទទួល និង

២-អត្ថប្រយោជន៍នោះត្រូវបានអនុញ្ញាតជាលាយលក្ខណ៍អក្សរ ដោយបុគ្គលិកជំនាញផ្នែកច្បាប់មុនពេលទទួល ឬផ្ដល់ឱ្យ។

**ប្រការ ២៧.- ការហាមឃាត់ចំពោះការកំណត់ការប្រកួតប្រជែងមិនស្មោះត្រង់**

ក្រុមហ៊ុនមូលបត្រមិនត្រូវស្នើក្រុមហ៊ុនមូលបត្រដទៃទៀត ឱ្យកែប្រែនូវថ្លៃស្នើលក់ និងថ្លៃស្នើទិញ (Ask and Bid) ឬលក្ខខណ្ឌជួញដូរផ្សេងទៀត ឬកែប្រែអត្រាកម្រៃជើងសាមូលបត្រ ថ្លៃសេវា និងលាភការផ្សេងៗឡើយ ឬចូលរួមសកម្មភាពផ្សេងទៀតក្នុងគោលបំណងកាត់បន្ថយការប្រកួតប្រជែង។

## ជំពូកទី ៨
## កម្រៃជើងសា និងការទូទាត់ដោយផ្អែកតាមគុណសម្បត្តិ

**ប្រការ ២៨.- កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវមានគោលការណ៍ណែនាំផ្ទៃក្នុង និងនីតិវិធីក្នុងការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗរបស់ខ្លួន ដោយអនុលោមតាមបទប្បញ្ញត្តិដែលមានជាធរមាន ហើយត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និងនីតិវិធីទាំងនេះ។ រាល់ការកែប្រែ ឬផ្លាស់ប្ដូរចំណុចណាមួយក្នុងគោលការណ៍ណែនាំ និងនីតិវិធីនេះ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវជូនដំណឹងទៅ គ.ម.ក. ក្នុងរយៈពេល ០៧ (ប្រាំពីរ )ថ្ងៃនៃថ្ងៃធ្វើការមុនការផ្លាស់ប្ដូរ។

**ប្រការ ២៩.- ការដាក់កំហិតលើការទូទាត់ដោយផ្អែកតាមគុណសម្បត្តិ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវធ្វើកិច្ចសន្យាជាមុនជាមួយអតិថិជនណាម្នាក់ ដើម្បីទទួលការទូទាត់ដោយផ្អែកតាមគុណសម្បត្តិនោះទេ។

## ជំពូកទី ៩

## ការផ្សាយពាណិជ្ជកម្ម និងការដាក់បង្ហាញព័ត៌មានទៅកាន់សាធារណជនទូទៅ

**ប្រការ ៣០.- លក្ខខណ្ឌតម្រូវក្នុងការផ្សព្វផ្សាយ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងភ្នាក់ងាររបស់ខ្លួនមិនត្រូវផ្សព្វផ្សាយជាសាធារណៈ ឬចូលរួម ឬអនុញ្ញាតឱ្យប្រើឈ្មោះរបស់ក្រុមហ៊ុនក្នុងការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណលក់ ឬមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួនដែលការផ្សព្វផ្សាយនោះ÷

១- ផ្ទុកនូវការសន្យាមិនសមហេតុផលចំពោះលទ្ធផលជាក់លាក់ណាមួយ

២-ប្រើស្ថិតិមិនមានលក្ខណៈតំណាង ដើម្បីទាញយកសេចក្តីសន្និដ្ឋានដែលគ្មានលក្ខណៈជាក់ច្បាស់ ឬបំផ្លើស ឬខកខានមិនបានបង្ហាញសម្មតកម្មសំខាន់ៗដែលបានប្រើប្រាស់ ដើម្បីឈានទៅរកសេចក្តីសន្និដ្ឋានទាំងនោះ

៣-ផ្ទុកនូវយោបល់ ឬការព្យាករណ៍ព្រឹត្តិការណ៍អនាគតដែលមិនបានបញ្ជាក់ច្បាស់លាស់ថាព័ត៌មានទាំងនេះគ្រាន់តែជាយោបល់ ឬការព្យាករណ៍

៤-មិនបានបង្ហាញឱ្យបានត្រឹមត្រូវពីហានិភ័យទៅអតិថិជន

៥- ធ្វើឱ្យខូចខាតផលប្រយោជន៍សាធារណៈ ឬ

៦-មិនអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាធរមាន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវរៀបចំគោលនយោបាយ និងនីតិវិធីដែលសមស្របនឹងទំហំ រចនាសម្ព័ន្ធអាជីវកម្ម និងអតិថិជនរបស់ខ្លួនសម្រាប់ការផ្ទៀងផ្ទាត់ឡើងវិញ និងការគ្រប់គ្រងនៃការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណលក់ និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀតពាក់ព័ន្ធនឹងអាជីវកម្មរបស់ខ្លួន។ រាល់គោលនយោបាយ និងនីតិវិធីត្រូវបានអនុញ្ញាតដោយអគ្គនាយកនៃ គ.ម.ក.។

ឯកសារនៃការផ្សាយពាណិជ្ជកម្ម ខិត្តប័ណ្ណលក់ និងមធ្យោបាយផ្សព្វផ្សាយផ្សេងទៀត និងកំណត់ត្រានៃការត្រួតពិនិត្យគោលនយោបាយ និងនីតិវិធីដែលតម្រូវឱ្យមានក្នុងកថាខណ្ឌទី ២ នៃប្រការនេះត្រូវថតចម្លង និងរក្សាទុកដើម្បីផ្តល់ជូន គ.ម.ក. ឱ្យទាន់ពេលវេលានៅពេលមានការត្រួតពិនិត្យ។

**ប្រការ ៣១.- ការវាយតម្លៃការគ្រប់គ្រង**

ក្រុមហ៊ុនមូលបត្រមិនត្រូវផ្សាយពាណិជ្ជកម្មដោយផ្ទាល់ ឬប្រយោលនូវលទ្ធផលវាយតម្លៃការគ្រប់-គ្រងដែលកំណត់ក្នុងប្រកាសស្ដីពីលក្ខខណ្ឌតម្រូវលើភាពរឹងមាំហិរញ្ញវត្ថុនៃក្រុមហ៊ុនមូលបត្រ និងមិនត្រូវផ្សាយពាណិជ្ជកម្មកម្រិតមូលធនសុទ្ធកាតព្វកិច្ចរបស់ខ្លួន ដើម្បីធ្វើការប្រៀបធៀបជាមួយក្រុមហ៊ុនមូលបត្រដទៃទៀត។

**ប្រការ ៣២.- ការផ្ដល់ព័ត៌មានដែលទាក់ទិននឹងការវិនិយោគវិស័យមូលបត្រ**

នៅពេលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណធ្វើសេចក្ដីថ្លែង ឬប្រកាសជាសាធារណៈ អំពីលក្ខខណ្ឌទីផ្សារ និង/ឬការជួញដូរ និង/ឬការវិនិយោគក្នុងវិស័យមូលបត្រ ក្រុមហ៊ុនត្រូវធ្វើយ៉ាងណាកុំឱ្យមានការយល់ខុសដោយត្រូវពិចារណាលើ÷

១- ព័ត៌មានពាក់ព័ន្ធណាមួយដែលនាំឱ្យមានការយល់ខុសលើខ្លឹមសារទាំងមូល។

២- កម្រិតចំណេះដឹង និងការយល់ដឹងរបស់អ្នកទទួលព័ត៌មាន។

៣- ការផ្ដល់ត្រូវធ្វើឱ្យបានច្បាស់លាស់ដោយបញ្ជាក់ឱ្យបានល្អិតល្អន់ ដើម្បីបំភ្លឺពីភាពស្មុគស្មាញ និងលក្ខណៈពិសេសនៃព័ត៌មាន ។

**ប្រការ ៣៣.- ការផ្ដល់ព័ត៌មានបានមកពីតតិយជន**

នៅពេលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រើប្រាស់ព័ត៌មានទាំងឡាយណាដែលបានមកពីតតិយជនក្នុងគោលបំណងដើម្បីបញ្ចុះបញ្ចូលអតិថិជនឱ្យធ្វើការវិនិយោគ ឬណែនាំឱ្យបុគ្គលណាមួយប្រើប្រាស់ព័ត៌មាននោះ ក្រុមហ៊ុនត្រូវមានហេតុផលជាមូលដ្ឋានដើម្បីធានាថាព័ត៌មានទាំងនោះអាចជឿបាន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើត និងអនុវត្តស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង ដើម្បីឱ្យច្បាស់ថាព័ត៌មានដែលទទួលបានពីតតិយជនជាព័ត៌មានដែលមានមូលដ្ឋានអាចជឿបាន ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

**ជំពូកទី ១០**

**របាយការណ៍វិភាគស្រាវជ្រាវ និងការផ្ដល់ប្រឹក្សាជួញដូរ**

**ប្រការ ៣៤.- ការរៀបចំ និងដាក់បង្ហាញព័ត៌មានដែលបានស្រាវជ្រាវវិភាគ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណដែលធ្វើការផ្សព្វផ្សាយនូវរបាយការណ៍វិភាគស្រាវជ្រាវ ឬព័ត៌មានផ្ដល់ប្រឹក្សាសម្រាប់ការជួញដូរ ÷

១- មិនត្រូវជួញដូរមូលបត្រ ឬមូលបត្រពាក់ព័ន្ធដែលបានវិភាគនៅក្នុងរបាយការណ៍វិភាគស្រាវជ្រាវ ក្នុងគណនីផ្ទាល់របស់ខ្លួន ក្នុងអំឡុងពេល ០២ (ពីរ) ថ្ងៃ ដែលព័ត៌មាននោះត្រូវបានផ្សព្វផ្សាយជាសាធារណៈ។

២- ត្រូវមានគោលនយោបាយ និងនីតិវិធីជាលាយលក្ខណ៍អក្សរដើម្បី÷

ក- កាត់បន្ថយជាអតិបរមានូវទំនាស់ផលប្រយោជន៍ដែលអាចកើតឡើងពីការរៀបចំរបាយការណ៍វិភាគ និងការផ្តល់ប្រឹក្សា និងការការពាររបាយការណ៍ និងការផ្តល់ប្រឹក្សាកុំឱ្យនៅក្រោមឥទ្ធិពលក្រុមហ៊ុនបោះផ្សាយលក់មូលបត្រ ឬភាគីពាក់ព័ន្ធដទៃទៀត។

ខ- ដាក់កំហិតឱ្យស្ថិតក្រោមការត្រួតពិនិត្យនូវរាល់ការជួញដូរមូលបត្រពាក់ព័ន្ធ របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ។

៣- ត្រូវផ្តល់ព័ត៌មានឱ្យបានទូលំទូលាយនៅក្នុងរបាយការណ៍ស្រាវជ្រាវ ឬការផ្តល់ប្រឹក្សា÷

ក- នូវព័ត៌មានស្តីពីទំនាក់ទំនងអាជីវកម្ម ទំនាក់ទំនងក្រុមហ៊ុន ឬអ្នកវិភាគជាមួយក្រុមហ៊ុនបោះផ្សាយមូលបត្រ ហើយព័ត៌មាននេះអាចបង្ហាញពីទំនាស់ផលប្រយោជន៍សក្តានុពលនៅក្នុងការផ្តល់ប្រឹក្សាពាក់ព័ន្ធនឹងក្រុមហ៊ុនបោះផ្សាយមូលបត្រ។

ខ- នូវព័ត៌មានអំពីការកាន់កាប់មូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយដោយក្រុមហ៊ុនមូលបត្រ ឬអ្នកវិភាគពាក់ព័ន្ធ ប្រសិនបើមាន។

គ- នូវព័ត៌មានអំពីការទទួលបានកម្រៃ ឬប្រយោជន៍ជាសារវ័ន្តផ្សេងៗពីក្រុមហ៊ុនបោះផ្សាយដោយក្រុមហ៊ុនមូលបត្រ ឬអ្នកវិភាគសម្រាប់ការរៀបចំរបាយការណ៍វិភាគ ឬការផ្តល់ប្រឹក្សា ប្រសិនបើមាន។

ឃ- នូវព័ត៌មានអំពីប្រព័ន្ធសម្រាប់ចំណាត់ថ្នាក់កាលានុវត្តភាពនៃការវិនិយោគ និងភាពត្រឹមត្រូវនៃការផ្តល់ប្រឹក្សាធៀបទៅនឹងប្រព័ន្ធនោះ។

ង- នូវគោលនយោបាយ និងនីតិវិធីរបស់ក្រុមហ៊ុនចំពោះការផ្សព្វផ្សាយនៃការស្រាវជ្រាវ។

៤- មិនត្រូវចេញផ្សាយរបាយការណ៍ស្រាវជ្រាវដែលរៀបចំដោយអ្នកវិភាគ ឬបុគ្គលពាក់ព័ន្ធនឹងអ្នកវិភាគដែលបម្រើការងារជាបុគ្គលិកជាន់ខ្ពស់ អភិបាល ឬនិយោជិតរបស់ក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬបម្រើការងារជាអ្នកប្រឹក្សាយោបល់ដល់ក្រុមហ៊ុនបោះផ្សាយ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវជំរុញ ឬលើកទឹកចិត្តដល់ក្រុមហ៊ុនដែលមានសម្ព័ន្ធភាពភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ឬបុគ្គលិកជាន់ខ្ពស់ ឬនិយោជិត ឬបុគ្គលដទៃទៀតដែលពាក់ព័ន្ធនឹងការរៀបចំរបាយការណ៍ស្រាវជ្រាវវិភាគឱ្យជួញដូរមូលបត្រនៃក្រុមហ៊ុនបោះផ្សាយមូលបត្រពាក់ព័ន្ធ ដោយមិនមានការអនុញ្ញាតជាមុនពីបុគ្គលិកជំនាញផ្នែកច្បាប់។

## ជំពូកទី ១១
## ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង

### ប្រការ ៣៥.- ការបង្កើត និងការអនុវត្តស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើត និងធានាអោយបាននូវការត្រួតពិនិត្យផ្ទៃក្នុងមួយសមស្រប រួមមានគោលនយោបាយ និងនីតិវិធីបង្កើត និងរក្សាដោយបុគ្គលិកជាន់ខ្ពស់ ដើម្បីចូលរួមចំណែកសម្រេចគោលដៅអាជីវកម្ម ព្រមទាំងធានាបាននូវសណ្តាប់ធ្នាប់ និងប្រសិទ្ធភាពក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនដោយអនុវត្តតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិពាក់ព័ន្ធ និងលក្ខខណ្ឌអាជ្ញាបណ្ណក្រុមហ៊ុន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវកំណត់ឱ្យបានច្បាស់ពីតួនាទីក្រុមប្រឹក្សាភិបាល បុគ្គលិកជាន់ខ្ពស់ បុគ្គលិកជំនាញផ្នែកច្បាប់ និងបុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង។ ករណីមានការធ្វើប្រតិភូកម្មប្រតិបត្តិការត្រួតពិនិត្យផ្ទៃក្នុងលើដំណើរការអាជីវកម្ម បុគ្គលដែលផ្ទេរសិទ្ធិអំណាច និងបុគ្គលទទួលសិទ្ធិអំណាចត្រូវកំណត់ភារកិច្ចឱ្យបានច្បាស់លាស់ជាលាយលក្ខណ៍អក្សរ។

### ប្រការ ៣៦.- បុគ្គលិកត្រួតពិនិត្យផ្ទៃក្នុង

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវតែងតាំងបុគ្គលិកដែលមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ដើម្បីធ្វើជាបុគ្គលិកត្រួតពិនិត្យផ្ទៃក្នុងដែលធានានូវប្រសិទ្ធភាពការងារ និងឯករាជ្យភាពរបស់ខ្លួនក្នុងការបំពេញភារកិច្ច ។

បុគ្គលិកត្រួតពិនិត្យផ្ទៃក្នុងមានសិទ្ធិត្រួតពិនិត្យឯកសារ និងកំណត់ត្រានានារបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងចូលរួមក្នុងកិច្ចប្រជុំចាំបាច់ផ្សេងៗពាក់ព័ន្ធនឹងការបំពេញភារកិច្ចរបស់ខ្លួន និងអាចរាយការណ៍ទៅនាយកប្រតិបត្តិ និងសវនករផ្ទៃក្នុង ឬគណៈកម្មាធិការសវនកម្ម។

### ប្រការ ៣៧.- យន្តការត្រួតពិនិត្យផ្ទៃក្នុង

ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីដែលពាក់ព័ន្ធត្រូវរួមបញ្ចូលទាំងការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈបង្ការទុក និងអង្កេត។ ការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈបង្ការទុកមានគោលបំណងដើម្បីការពារ ឬកាត់បន្ថយឱ្យបានជាអតិបរមានូវការតែបន្លំ ឬកំហុស។ ការត្រួតពិនិត្យផ្ទៃក្នុងមានលក្ខណៈអង្កេតមានគោលបំណង ដើម្បីស្វែងរកឱ្យឃើញការតែបន្លំ ឬកំហុស សំដៅចាត់វិធានការកែតម្រូវឱ្យបានឆាប់រហ័ស។

ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីដែលពាក់ព័ន្ធត្រូវកត់ត្រាជាឯកសារ និងត្រូវបានកែសម្រួល ឬត្រួតពិនិត្យឡើងវិញភ្លាមៗនៅពេលមានវិសោធនកម្មច្បាប់ ឬបទប្បញ្ញត្តិពាក់ព័ន្ធ។

ស្តង់ដារត្រួតពិនិត្យផ្ទៃក្នុងត្រូវបញ្ចូលគ្រប់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ព្រមទាំងនីតិវិធីធ្វើអាជីវកម្ម និងប្រព័ន្ធកុំព្យូទ័រត្រូវរៀបចំឡើងឱ្យសមស្របតាមដំណាក់កាលការងារគ្រប់គ្រង និងធានាសង្គតិភាពជាមួយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**ប្រការ ៣៨.- ការពង្រឹងការអនុវត្តត្រួតពិនិត្យផ្ទៃក្នុង**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធានាឱ្យបាននូវនីតិវិធីដែលអាចឱ្យភ្នាក់ងាររបស់ខ្លួន ប្រើប្រាស់បានដើម្បីជួយសម្រួលការងារ និងការផ្តល់ប្រឹក្សាគ្រប់ពេលវេលា ក្នុងករណីមានការសាកសួរនានាពាក់ព័ន្ធនឹងផ្លូវច្បាប់ក្នុងពេលដំណើរការអាជីវកម្ម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវបង្កើតនូវកម្មវិធីសិក្សាដល់ភ្នាក់ងាររបស់ខ្លួន ដើម្បីឱ្យពួកគេស្វែងយល់ពីគោលបំណងនៃបទប្បញ្ញត្តិដែលកំណត់ពីកាតព្វកិច្ច និងទង្វើដែលត្រូវបានហាមឃាត់ ហើយត្រូវបង្កើតនូវវគ្គបណ្តុះបណ្តាលសំខាន់ៗនានាជាទៀងទាត់ ឬតាមការចាំបាច់។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវតាមដានការអនុវត្តច្បាប់ឱ្យទៀងទាត់ ដើម្បីបង្ការទុកជាមុននូវការបំពានច្បាប់ និងស្វែងរកឱ្យឃើញផលប៉ះពាល់នានាដែលអាចធ្វើឱ្យរអាក់រអួលប្រព័ន្ធប្រតិបត្តិការពាក់-ព័ន្ធនឹងការត្រួតពិនិត្យផ្ទៃក្នុង។

ករណីរកឃើញការបំពានណាមួយធ្វើឡើងដោយភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ បុគ្គលិកជាន់ខ្ពស់ ឬនិយោជិតរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ក្រុមហ៊ុនត្រូវចាត់វិធានការភ្លាមៗ និងមានប្រសិទ្ធភាពដើម្បីការពារការបំពានដដែលៗ តាមរយៈវិធានការវិន័យទៅលើអ្នកប្រព្រឹត្តទាំងនោះ និងកែលម្អចំណុចខ្វះខាតនានានៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធានាឱ្យបាននូវនីតិវិធីសមស្របក្នុងការដោះស្រាយការតវ៉ារបស់អតិថិជន និងវិវាទរវាងបុគ្គលិកនិងអតិថិជន។

## ជំពូកទី ១២
## ប្រាក់អតិថិជន

**ប្រការ ៣៩.- គណនីសាច់ប្រាក់អតិថិជន**

ក្រុមហ៊ុនមូលបត្រត្រូវបើកគណនីសាច់ប្រាក់អតិថិជននៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ សម្រាប់អតិថិជនណាដែលក្រុមហ៊ុនមូលបត្រត្រូវថែរក្សា និងចាត់ចែងប្រាក់ជំនួស។

ក្រុមហ៊ុនមូលបត្រត្រូវថែរក្សា និងចាត់ចែងជំនួសនូវប្រាក់របស់អតិថិជនដែលជាកម្មសិទ្ធិរបស់អតិថិជន។

ឈ្មោះគណនីសាច់ប្រាក់អតិថិជនត្រូវមានពាក្យ "គណនីសាច់ប្រាក់អតិថិជន" និងត្រូវតែបើកសម្រាប់តែអតិថិជនរបស់ក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជនទាំងនោះប៉ុណ្ណោះ។

រាល់ប្រាក់អតិថិជនរបស់ក្រុមហ៊ុនមូលបត្រត្រូវតែដាក់តម្កល់ នៅក្នុងគណនីសាច់ប្រាក់អតិថិជន។ ក្រុមហ៊ុនមូលបត្រមិនត្រូវដាក់តម្កល់ប្រាក់អតិថិជន នៅក្នុងគណនីណាផ្សេងពីគណនីសាច់ប្រាក់អតិថិជនឡើយ លើកលែងតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន។ ក្រុមហ៊ុនមូលបត្រអាចដាក់ប្រាក់ដែលទទួលបានពីអតិថិជនលាយឡំ និងតម្កល់នៅក្នុងគណនីសាច់ប្រាក់អតិថិជនដូចគ្នាបាន លុះត្រាតែក្រុមហ៊ុនមូលបត្រធ្វើ និងរក្សាកំណត់ត្រាត្រឹមត្រូវសម្រាប់អតិថិជននីមួយៗនៅក្នុងសៀវភៅធំអតិថិជនដែលមាននៅក្នុងគណនីផ្ទៃក្នុងរបស់ក្រុមហ៊ុនមូលបត្រ ដើម្បីងាយស្រួលក្នុងការស្វែងរកគ្រប់ពេលវេលានូវប្រាក់អតិថិជនដែលជាកម្មសិទ្ធិរបស់អតិថិជននីមួយៗ។

ក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់ប្រាក់អតិថិជនដែលទទួលបានក្នុងគណនីសាច់ប្រាក់អតិថិជនភ្លាមមិនឱ្យហួសពីថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលក្រុមហ៊ុនមូលបត្រទទួលបានប្រាក់នោះ ឬថ្ងៃដែលបានបញ្ជាក់ថាបានទទួលប្រាក់ លើកលែងតែប្រាក់នោះត្រូវតម្កល់ទុកក្នុងគណនីណាមួយតាមបញ្ជាអតិថិជន។

រាល់ការបើកគណនីសាច់ប្រាក់អតិថិជន ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងដល់ គ.ម.ក. ពីការបើកគណនីនោះ។

រាល់ការដាក់តម្កល់ប្រាក់អតិថិជនក្នុងគណនីសាច់ប្រាក់អតិថិជន ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់ដល់អតិថិជនពីទីកន្លែង និងឈ្មោះភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងរបៀបនៃការរក្សាទុកប្រាក់នោះ។

ក្រុមហ៊ុនមូលបត្រមានកាតព្វកិច្ចពាក់ព័ន្ធនឹងប្រាក់អតិថិជនរហូតដល់ ÷

១-អតិថិជនបានទទួលប្រាក់គ្រប់ចំនួនពីក្រុមហ៊ុនមូលបត្រ។

២-កម្មសិទ្ធិលើមូលបត្ររបស់អតិថិជនបានចុះបញ្ជីនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

## ប្រការ ៤០.- ការរក្សាទុកកំណត់ត្រា

ក្រុមហ៊ុនមូលបត្រត្រូវ ÷

១-ធ្វើកំណត់ត្រាលើលំហូរចេញ-ចូលនៃគ្រប់ប្រតិបត្តិការនៅក្នុងគណនីសាច់ប្រាក់អតិថិជននីមួយៗ ។

២-ផ្ទៀងផ្ទាត់ប្រចាំថ្ងៃរវាងកំណត់ត្រាសម្រាប់គណនីសាច់ប្រាក់អតិថិជននីមួយៗ ជាមួយកំណត់ត្រារបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ និងត្រូវជូនដំណឹងដល់ គ.ម.ក. ក្នុងករណីក្រុមហ៊ុនមូលបត្រមិនអាចធ្វើការផ្ទៀងផ្ទាត់ប្រចាំថ្ងៃ។

**ប្រការ ៤១.- ការគាំពារគណនីសាច់ប្រាក់អតិថិជន**

ប្រាក់អតិថិជនដែលតម្កល់ទុកក្នុងគណនីសាច់ប្រាក់អតិថិជនមិនត្រូវជាប់ពាក់ព័ន្ធនឹង ឬយកទៅប្រើប្រាស់សម្រាប់ការទូទាត់ បន្ទុក ឬបន្ទុកលើបញ្ជា ឬដំណើរផ្សេងៗដែលមានលក្ខណៈស្រដៀងគ្នា លើកលែងតែមានការអនុញ្ញាតពីបុគ្គលដែលមានសិទ្ធិលើប្រាក់នោះ។

ក្រុមហ៊ុនមូលបត្រមិនត្រូវប្រើប្រាស់ប្រាក់អតិថិជនដែលថែរក្សា និងចាត់ចែងជំនួសអតិថិជននៅក្នុងគណនីសាច់ប្រាក់អតិថិជន ដើម្បីទូទាត់បំណុល និងមិនត្រូវដកប្រាក់នោះចេញពីគណនីឡើយ លើកលែងតែករណីដូចដែលបានចែងក្នុងប្រការ ៤៤ នៃប្រកាសនេះ។

ក្រុមហ៊ុនមូលបត្រមិនត្រូវរក្សាទុកប្រាក់ដែលទទួលបានសម្រាប់ផលប្រយោជន៍អតិថិជនឱ្យលាយឡំជាមួយប្រាក់ផ្ទាល់របស់ក្រុមហ៊ុន និងមិនត្រូវប្រើប្រាស់ប្រាក់នោះជាប្រាក់ចំណេញ ឬការធានា ឬជាកិច្ចធានាប្រតិបត្តិការណាមួយ ឬការផ្តល់ឥណទានដល់បុគ្គលណាមួយឡើយ។

ដោយអនុលោមតាមច្បាប់ស្តីពីក្ស័យធន ប្រាក់អតិថិជនដែលតម្កល់ទុកក្នុងគណនីសាច់ប្រាក់អតិថិជនមិនត្រូវដកចេញពីទ្រព្យសកម្មរបស់បុគ្គលណាផ្សេងក្រៅពីអតិថិជនឡើយ ហើយមិនត្រូវយកទៅប្រើប្រាស់ដើម្បីទូទាត់បំណុលរបស់ក្រុមហ៊ុនមូលបត្រ ឬភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ឬបុគ្គលណាផ្សេង ក្នុងករណីអសាធនីយភាព ការជម្រះបញ្ជី ការគ្រប់គ្រងបណ្តោះអាសន្ន ឬព្រឹត្តិការណ៍ស្រដៀងគ្នាពាក់ព័ន្ធនឹងបុគ្គលទាំងនេះ។ បុគ្គលជម្រះបញ្ជី អភិបាលបណ្តោះអាសន្ន ឬបុគ្គលដែលកាន់តំណែងប្រហាក់ប្រហែល មិនមានសិទ្ធិចាត់ទុកទ្រព្យសកម្មនៅក្នុងគណនីសាច់ប្រាក់អតិថិជនជាទ្រព្យសកម្មរបស់បុគ្គលដទៃទៀតក្រៅពីអតិថិជន។

**ប្រការ ៤២.- ប្រាក់អតិថិជន**

ប្រាក់ក្នុងគណនីសាច់ប្រាក់អតិថិជនដែលក្រុមហ៊ុនមូលបត្រទទួលបានស្របតាមប្រកាសនេះ រួមមាន ÷

១- ប្រាក់ដែលទទួលបានពីអតិថិជនសម្រាប់ធ្វើការទិញមូលបត្រ ឬថែរក្សា និងចាត់ចែងមូលបត្រជំនួស ឬប្រាក់ទទួលបានពីសេវាថែរក្សាគណនីជួញដូរមូលបត្រ។

២- ប្រាក់ដែលទទួលបានពីការលក់មូលបត្រសម្រាប់ផលប្រយោជន៍អតិថិជន។

៣- រាល់ប្រាក់ផ្សេងទៀតទទួលពី ឬសម្រាប់ផលប្រយោជន៍អតិថិជនក្នុងដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនមូលបត្រ។

ប៉ុន្តែប្រាក់អតិថិជនមិនរាប់បញ្ចូល ÷

ក- ប្រាក់ប្រើសម្រាប់សងបំណុលដែលអតិថិជនជំពាក់ក្រុមហ៊ុនមូលបត្រ។

ខ-ប្រាក់ដែលត្រូវទូទាត់ថ្លៃសេវា និងកម្រៃជើងសា និងបន្ទុកចំណាយដែលពាក់ព័ន្ធផ្សេងទៀតទៅឱ្យក្រុមហ៊ុនមូលបត្រ។

គ-ប្រាក់ដែលត្រូវទូទាត់ឱ្យទៅបុគ្គលដែលមានសិទ្ធិទទួលប្រាក់នោះ។

**ប្រការ ៤៣.- ការជូនដំណឹង និងការទទួលស្គាល់ពីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ**

មុននឹងបញ្ចូលប្រាក់ដែលទទួលបានពីអតិថិជន ទៅក្នុងគណនីសាច់ប្រាក់អតិថិជនដែលរក្សាទុកនៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ប្រការ ៣៩ នៃប្រកាសនេះ ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូល-បត្រនោះ និងទាមទារយកលិខិតទទួលស្គាល់មកវិញដើម្បីបញ្ជាក់ថា រាល់ប្រាក់ដែលបានបញ្ចូលក្នុងគណនីសាច់ប្រាក់អតិថិជនត្រូវបានថែរក្សា និងចាត់ចែងជំនួសដោយក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជនរបស់ខ្លួនដោយអនុលោមតាមប្រការ ៣៩ និង ៤១ នៃប្រកាសនេះ ហើយភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវអនុវត្តតាមប្រការ ៣៩ និង ៤១ ខាងលើ។ លិខិតទទួលស្គាល់ពីភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រត្រូវមានទម្រង់ដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក. និងត្រូវចុះហត្ថលេខាដោយអ្នកតំណាងរបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។

**ប្រការ ៤៤.- ការដកប្រាក់អតិថិជនពីគណនីសាច់ប្រាក់អតិថិជន**

ក្រុមហ៊ុនមូលបត្រមិនត្រូវដកប្រាក់អតិថិជនចេញពីគណនីសាច់ប្រាក់អតិថិជនឡើយ លើកលែងករណីដូចខាងក្រោម÷

១-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ទៅឱ្យបុគ្គលណាមួយដែលមានសិទ្ធិទទួល។

២-នៅពេលអតិថិជនធ្វើការជួញដូរមូលបត្រ ក្រុមហ៊ុនមូលបត្រមានកាតព្វកិច្ចទូទាត់ក្នុងនាមអតិថិជនដែលទុកប្រាក់ក្នុងគណនីនោះ។

៣-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ថ្លៃសេវា កម្រៃជើងសាមូលបត្រ និងបន្ទុកចំណាយផ្សេងទៀតដែលអតិថិជនត្រូវបង់។

៤-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ទៅឱ្យបុគ្គល ឬគណនីផ្សេងយោងតាមការស្នើរបស់អតិថិជនតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ។

៥-ក្រុមហ៊ុនមូលបត្រធ្វើការទូទាត់ ឬដកប្រាក់ដែលតម្រូវដោយច្បាប់។

**ប្រការ ៤៥.- ការប្រាក់ដែលកើតពីគណនីសាច់ប្រាក់អតិថិជន**

រាល់ការប្រាក់ដែលអតិថិជនទទួលបានពីការរក្សាទុកប្រាក់ក្នុងគណនីសាច់ប្រាក់អតិថិជនត្រូវទូទាត់ឱ្យអតិថិជន ដោយគោរពតាមកិច្ចព្រមព្រៀងរវាងក្រុមហ៊ុនមូលបត្រ និងអតិថិជន។

## ជំពូកទី ១៣
## មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន

**ប្រការ ៤៦.- ភារកិច្ចក្រុមហ៊ុនមូលបត្រនៅពេលទទួលមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន**

ក្រុមហ៊ុនមូលបត្រត្រូវចាត់ចែងឱ្យមានអ្នកថែរក្សា ដើម្បីគ្រប់គ្រងថែរក្សាមូលបត្រ ឬទ្រព្យសម្បត្តិផ្សេងទៀត។ ក្នុងករណីជាមូលបត្រត្រូវរក្សាទុកនៅក្នុងប្រតិបត្តិកររក្សាទុកមូលបត្រ។

ក្រុមហ៊ុនមូលបត្រត្រូវដាក់តម្កល់មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនជាមួយនឹងអ្នកថែរក្សាភ្លាម មិនឱ្យហួសពីថ្ងៃធ្វើការបន្ទាប់ពីថ្ងៃដែលក្រុមហ៊ុនមូលបត្រទទួលបានមូលបត្រ ឬទ្រព្យ-សម្បត្តិផ្សេងៗនោះ ឬថ្ងៃដែលបានបញ្ជាក់ថាបានទទួលមូលបត្រ ឬទ្រព្យសម្បត្តិផ្សេងៗ លើកលែងតែមូលបត្រ ឬទ្រព្យសម្បត្តិផ្សេងៗនោះត្រូវតម្កល់ទុកក្នុងគណនីណាមួយតាមបញ្ជាអតិថិជន។

**ប្រការ ៤៧.- ព័ត៌មាន និងការទទួលដំណឹងពីអ្នករក្សាទុក**

ក្រុមហ៊ុនមូលបត្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នករក្សាទុក (Custody Provider) អំពីមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនដែលត្រូវដាក់តម្កល់ និងទទួលបានលិខិតទទួលស្គាល់ពីអ្នករក្សាទុកវិញ ដែលលិខិតនោះត្រូវបញ្ជាក់ថា ÷

១-រាល់មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនដែលរក្សាទុកក្នុងគណនីរក្សាទុកត្រូវបានថែរក្សា និងចាត់ចែងជំនួសដាច់ដោយឡែក ដោយក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជនរបស់ខ្លួន។

២-មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជនត្រូវបែងចែកឱ្យបានច្បាស់ និងត្រូវរក្សាទុកដាច់ដោយឡែកពីគណនីរបស់ក្រុមហ៊ុនមូលបត្រដែលបានដាក់តម្កល់មូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់ខ្លួនផ្ទាល់។

**ប្រការ ៤៨.- ការដក ឬផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់អតិថិជន**

ក្រុមហ៊ុនមូលបត្រមិនត្រូវដក ឬផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតណាមួយរបស់អតិថិជនពីគណនីរក្សាទុក លើកលែងតែ ÷

១- ការផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតទៅបុគ្គលណាមួយដែលមានសិទ្ធិទទួល។

២- ការបំពេញកាតព្វកិច្ចរបស់អតិថិជនដែលកើតមានពីការជួញដូរមូលបត្រធ្វើឡើងដោយក្រុមហ៊ុនមូលបត្រក្នុងនាមអតិថិជន។

៣- ការផ្ទេរមូលបត្រ និងទ្រព្យសម្បត្តិផ្សេងទៀតទៅបុគ្គល ឬគណនីណាមួយស្របតាមការស្នើសុំជាលាយលក្ខណ៍អក្សររបស់អតិថិជន។

៤- ការផ្ទេរណាមួយដែលតម្រូវដោយច្បាប់។

## ជំពូកទី ១៤
## ការកត់ត្រា និងការចុះបញ្ជី

### ប្រការ ៤៩.- វិធានកត់ត្រា និងចុះបញ្ជី

អនុលោមតាមមាត្រា ៤៦ នៃអនុក្រឹត្យ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវធ្វើការកត់ត្រា និងចុះបញ្ជីអំពីសកម្មភាពអាជីវកម្មរបស់ខ្លួន ហើយត្រូវរក្សាទុកបញ្ជីនេះយ៉ាងតិច ១០ (ដប់) ឆ្នាំ និងតាមវិធានដូចខាងក្រោម÷

១- ទិន្នានុប្បវត្តិដែលមានកំណត់ត្រាលម្អិតប្រចាំថ្ងៃនូវរាល់ប្រតិបត្តិការទិញ និងលក់មូលបត្រទាំងអស់ រាល់ការកត់ត្រាលំហូរនៃការទទួល និងបញ្ជូនមូលបត្រ រាប់បញ្ចូលចំនួនវិក័យបត្រ រាល់ការកត់ត្រាលំហូរប្រាក់ទទួល និងការចំណាយ ព្រមទាំងការកត់ត្រាឥណពន្ធ និងឥណទានផ្សេងទៀត។ កំណត់ត្រាទាំងនេះត្រូវបង្ហាញពីគណនីពាក់ព័ន្ធក្នុងប្រតិបត្តិការនីមួយៗដោយត្រូវមាន ឈ្មោះ និងចំនួនមូលបត្រ ថ្លៃលក់ ឬទិញក្នុងមួយឯកតា និងថ្លៃសរុប កាលបរិច្ឆេទជួញដូរ កាលបរិច្ឆេទការជាត់ទាត់និងទូទាត់ ព្រមទាំងឈ្មោះ និងហត្ថលេខារបស់បុគ្គលដែលបានទិញ ឬលក់ ឬប្រគល់ ឬបញ្ជូនទៅឱ្យ។

២- សៀវភៅធំដែលឆ្លុះបញ្ចាំងពីទ្រព្យសកម្មនិងបំណុល ចំណូលនិងចំណាយ ព្រមទាំងដើមទុនរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៃក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ។ សៀវភៅធំកត់ត្រាប្រតិបត្តិការត្រូវបង្កើតឡើងដោយផ្អែកលើសេចក្តីបញ្ជាក់ពីប្រតិបត្តិការដែលផ្ញើជូនអតិថិជន ហើយសៀវភៅធំកត់ត្រាប្រតិបត្តិការនេះមានព័ត៌មានដូចជា: កាលបរិច្ឆេទប្រតិបត្តិការ ប្រភេទប្រតិបត្តិការទិញឬលក់ ថ្លៃ កម្រៃជើងសា និងការចំណាយ កាលបរិច្ឆេទជាត់ទាត់និងទូទាត់ ឈ្មោះនិងអាសយដ្ឋានរបស់អ្នកទិញ និងអ្នកលក់ លេខសម្គាល់ប្រតិបត្តិការ បរិមាណមូលបត្រជួញដូរ វិធីសាស្ត្រ ជាត់ទាត់និងទូទាត់ និងព័ត៌មានអំពីការជាត់ទាត់និងទូទាត់នៃប្រតិបត្តិការជួញដូរ។

៣- កំណត់ត្រានៃការបញ្ជាមូលបត្រនីមួយៗទៅតាមលំដាប់លំដោយនៃកាលបរិច្ឆេទ ដោយបង្ហាញពីកាលបរិច្ឆេទទទួលបញ្ជា លក្ខខណ្ឌនៃបញ្ជា ការកែប្រែឬការលុបចោលបញ្ជា គណនីដែលបញ្ជា កាល-

បរិច្ឆេទ ការអនុវត្តបញ្ជាទៅទីផ្សារ ថ្ងៃនៅពេលអនុវត្តបញ្ជា កាលបរិច្ឆេទនៃការអនុវត្ត ឬការលុបចោលប្រតិបត្តិការ។

៤-ឯកសារពាក់ព័ន្ធនឹងការអនុវត្តបញ្ជារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

៥-កំណត់ត្រាដែលទាក់ទងនឹងសកម្មភាពត្រួតពិនិត្យផ្ទៃក្នុងមានដូចខាងក្រោម÷

ក-ដំណើរការត្រួតពិនិត្យផ្ទៃក្នុង និងការអនុវត្តច្បាប់របស់ក្រុមហ៊ុនមូលបត្រ។

ខ-តួនាទី និងសកម្មភាពនៃបុគ្គលិកជំនាញផ្នែកច្បាប់ដែលចុះផ្ទាល់ក្នុងការត្រួតពិនិត្យផ្ទៃក្នុង។

គ-ទិន្នន័យពិស្តារ និងលទ្ធផលនៃដំណើការសវនកម្មផ្ទៃក្នុង។

៦-កំណត់ត្រា និងការរក្សាទុកនូវរាល់ការតវ៉ាជាលាយលក្ខណ៍អក្សរព្រមទាំងឯកសារឆ្លើយតបចំពោះពាក្យបណ្តឹង និងសំណុំឯកសារប្រើប្រាស់ផ្សេងៗទៀត។

៧-ក្រុមហ៊ុនទទួលអាជ្ញាបណ្ណត្រូវរក្សាទុកផងដែរនូវកំណត់ត្រា និងឯកសារ÷

ក-របាយការណ៍ធនាគារ និងគណនីផ្ទៀងផ្ទាត់ធនាគារ។

ខ-ភស្តុតាងនៃមូលប្បទានបត្រដែលបានទូទាត់ មូលប្បទានបត្រដែលបានលុបចោលប្រសិនបើមាន។

គ-រាល់កិច្ចព្រមព្រៀងដែលធ្វើឡើងរវាងក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ និងអតិថិជនរបស់ខ្លួនយោងតាមប្រការ ៦ នៃប្រកាសនេះ។

ឃ-រាល់វិក័យបត្រផ្ទេរទ្រព្យសម្បត្តិរបស់អតិថិជនដែលបង្ហាញពីបុគ្គលឈរឈ្មោះកាន់កាប់ទ្រព្យសម្បត្តិ។

ង-រាល់របាយការណ៍ សំបុត្រ សេចក្តីណែនាំ អនុស្សរណៈ សេចក្តីប្រកាស ការផ្សព្វផ្សាយ និងការផ្តល់ប្រឹក្សាដែលក្រុមហ៊ុនមូលបត្របញ្ជូនទៅឱ្យអតិថិជនដែលមានបង្ហាញពីកាលបរិច្ឆេទ។

ច-អាជ្ញាបណ្ណ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗដែលចេញដោយអាជ្ញាធរ។

ឆ-របាយការណ៍ផ្សេងទៀតដែលបានរៀបចំ ឬទទួលបានក្នុងដំណើរការអាជីវកម្ម។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវកត់ត្រាគ្រប់ប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃ ដោយអនុវត្តតាមស្តង់ដារទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ព្រមទាំងបទប្បញ្ញត្តិដែលចេញដោយ គ.ម.ក.។

ប្រព័ន្ធកត់ត្រាដែលបានប្រើត្រូវមានការការពារគ្រប់ជ្រុងជ្រោយ ចៀសវាងនូវកំហុសនៃការកត់ត្រា។

ប្រព័ន្ធកត់ត្រាដែលយកមកប្រើប្រាស់ត្រូវផ្តល់ព័ត៌មានឆាប់រហ័ស ត្រឹមត្រូវ និងងាយយល់សម្រាប់អ្នកពាក់ព័ន្ធ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវរៀបចំជាស្រេចនូវឯកសារបញ្ជីស្នាមនានា ដោយធ្វើជារបាយ-ការណ៍ និងត្រូវបញ្ជូនទៅ គ.ម.ក. ។

## ជំពូកទី ១៥

## បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ៥០.- ការផ្លាស់ប្តូរកម្មសិទ្ធិអាជ្ញាបណ្ណ

ក្រុមហ៊ុនទទួលអាជ្ញាបណ្ណមិនត្រូវផ្លាស់ប្តូរ រចនាសម្ព័ន្ធគ្រប់គ្រង រចនាសម្ព័ន្ធរូបវន្ត ឬរចនាសម្ព័ន្ធកម្មសិទ្ធិនៃក្រុមហ៊ុនរួមមាន ការបោះផ្សាយ ឬការផ្ទេរភាគហ៊ុន ឬផ្ទេរកម្មសិទ្ធិក្រុមហ៊ុន ដោយគ្មានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក.។

### ប្រការ ៥១.- ការជួញដូររបស់និយោជិត

និយោជិតរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ដែលមានបំណងជួញដូរមូលបត្រសម្រាប់គណនីផ្ទាល់របស់ពួកគេ ឬគណនីភាគីពាក់ព័ន្ធ ឬក្នុងនាមគណនីដែលពួកគេមានផលប្រយោជន៍ត្រូវទទួលការអនុញ្ញាតឱ្យជួញដូរជាលាយលក្ខណ៍អក្សរពីបុគ្គលិកជំនាញផ្នែកច្បាប់។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវតម្រូវឱ្យនិយោជិតបញ្ជាក់ជាលាយលក្ខណ៍អក្សរប្រចាំឆ្នាំ អំពីការអនុវត្តកាតព្វកិច្ចតាមការអនុញ្ញាត ដោយអនុលោមតាមកថាខណ្ឌទី ១ នៃប្រការនេះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ប្រចាំថ្ងៃទៅលើការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ និងការជួញដូររបស់និយោជិតសម្រាប់គណនីផ្ទាល់របស់ពួកគេ ឬគណនីភាគីពាក់ព័ន្ធ ឬក្នុងនាមគណនីដែលពួកគេមានផលប្រយោជន៍។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវរក្សាទុកឱ្យបានត្រឹមត្រូវនូវកំណត់ត្រា ÷

ក- ការអនុញ្ញាតឱ្យជួញដូរមូលបត្រជាលាយលក្ខណ៍អក្សរដែលចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ។

ខ- ការទទួលយកអនុវត្តតាមកាតព្វកិច្ចរបស់និយោជិតដែលចែងក្នុងកថាខណ្ឌទី ២ នៃប្រការនេះ និងការផ្ទៀងផ្ទាត់ប្រចាំថ្ងៃដែលមានចែងក្នុងកថាខណ្ឌទី ៣ នៃប្រការនេះ។

### ប្រការ ៥២.- ដែនកំណត់នៃការលក់មូលបត្របោះផ្សាយដោយក្រុមហ៊ុនមូលបត្រ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណមិនត្រូវផ្តល់ប្រឹក្សាទៅឱ្យអតិថិជនក្នុងការទិញមូលបត្ររបស់ខ្លួនដែលបានបោះផ្សាយរួចហើយ ឬរំពឹងថានឹងបោះផ្សាយ។

### ប្រការ ៥៣.- ការដាក់កំហិតលើការជួញដូរក្រៅទីផ្សារ

ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រមិនត្រូវជំរុញឱ្យមានជួញដូរមូលបត្រចុះបញ្ជីនៅក្រៅទីផ្សារមូលបត្រប្រពិស្រុត។

## ជំពូកទី ១៦
## ទោសប្បញ្ញត្តិ

**ប្រការ ៥៤.- ទណ្ឌកម្មចំពោះការមិនគោរពបទប្បញ្ញត្តិនៃប្រកាសនេះ**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា បុគ្គលដែលប្រព្រឹត្តល្មើស ឬខកខានមិនបានអនុវត្តកាតព្វកិច្ច ដូចមានចែងក្នុងប្រកាសនេះ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងក្នុងប្រការ ៥៥ នៃប្រកាសនេះ និង/ឬការផាកពិន័យអន្តរការណ៍ពី គ.ម.ក. ជាប្រាក់÷

-ពី ៥.០០០.០០០(ប្រាំលាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល។

-ពី ២០.០០០.០០០(ម្ភៃលាន) រៀល ទៅ ២០០.០០០.០០០(ពីរយលាន) រៀល ចំពោះនីតិបុគ្គល។

**ប្រការ ៥៥.- ទណ្ឌកម្មរដ្ឋបាល**

ចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងបញ្ញត្តិណាមួយនៃប្រកាសនេះ អគ្គនាយកនៃ គ.ម.ក. អាចសម្រេចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

-ការព្រមាន។

-បទបញ្ជាឱ្យកែតម្រូវ។

-ការព្យួរ ឬការបណ្តេញចេញពីមុខតំណែងនូវអភិបាល និង/ឬបុគ្គលិកជាន់ខ្ពស់។

-ការដាក់កំហិតលើអាជ្ញាបណ្ណ។

-ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ។

## ជំពូកទី ១៧
## អវសានប្បញ្ញត្តិ

**ប្រការ ៥៦.- គោលការណ៍ណែនាំផ្សេងៗ**

គ.ម.ក. អាចចេញនូវគោលការណ៍ណែនាំ ដើម្បីសម្រួលការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងទីផ្សារមូលបត្រ និងដល់សាធារណជន។

**ប្រការ ៥៧.-បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៨.-ការអនុវត្ត**

អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ នាយកដ្ឋានអង្គភាពដទៃទៀត ចំណុះឱ្យគណៈកម្មការមូលបត្រកម្ពុជា ក្រុមហ៊ុនមូលបត្រ ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១

**គាត ឈន់**

**ចម្លងជូន ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- គណៈកម្មការមូលបត្រកម្ពុជា
- គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធស្តីពីពាក្យស្នើសុំបើកគណនី

ប្រកាសលេខ..០០៨/១១ គ.ម.ក.ប្រ.ក

ចុះថ្ងៃទី២៧ខែមិថុនាឆ្នាំ២០១១

| ឈ្មោះក្រុមហ៊ុនមូលបត្រ.................................<br>ឈ្មោះភ្នាក់ងារក្រុមហ៊ុនមូលបត្រ...................... | កាលបរិច្ឆេទនៃការស្នើសុំ<br>.............................. | លេខគណនី<br>.............................. |
|---|---|---|

ប្រភេទគណនី .......................................... រូបវន្តបុគ្គល ..........................................

ស្ថាប័ន ..........................................................................................................

ឈ្មោះអតិថិជន (នាម និងគោត្តនាម) ............................................ ជាអក្សរឡាតាំង..............

លេខអត្តសញ្ញាណវិនិយោគិនដែលទទួលបានពី គ.ម.ក..........ថ្ងៃ ខែ ឆ្នាំកំណើត.............សញ្ជាតិ.......

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន........................កាលបរិច្ឆេទផុតសុពលភាព................

ចេញដោយ........................លេខទូរស័ព្ទ...................................លេខទូរសារ.................

អ៊ីម៉ែល.........................................អាសយដ្ឋានទំនាក់ទំនង................................................

..........................................................................................................

លក្ខន្តិកៈគ្រួសារ ☐ នៅលីវ ☐ មានគ្រួសារ ☐ លែងលះ

មុខរបរ..............................................................មុខតំណែង........................................

អាសយដ្ឋានកន្លែងធ្វើការ..........................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ.........................................ប្រភេទអាជីវកម្ម................................

រយៈពេលនៃអតីតភាពការងារ.........................................................................................

ឈ្មោះសហព័ទ្ធ (នាម និង គោត្តនាម) .........................................................................

ជាអក្សរឡាតាំង.........................................................................................................

មុខរបរ................................................មុខតំណែង ................................................

អាសយដ្ឋានកន្លែងធ្វើការ..........................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ.........................................ប្រភេទអាជីវកម្ម................................

រយៈពេលនៃអតីតភាពការងារ.........................................................................................

ចំណេះដឹងលើការវិនិយោគ

☐ ល្អណាស់ ☐ ល្អ ☐ មានកម្រិត ☐ គ្មាន

បទពិសោធន៍ក្នុងសកម្មភាពវិនិយោគ

☐ បណ្ណរតនាគារ ☐ ភាគហ៊ុន ☐ សញ្ញាបណ្ណ ☐ មូលបត្រផ្សេងទៀត ☐ គ្មាន

ឯកសារធនាគាររបស់អតិថិជន

ឈ្មោះធនាគារ ....................................................................................................

លេខគណនីធនាគារ....................................................................................................

ប្រភេទគណនីធនាគារ..................................................................................................

បុគ្គលដែលអាចទាក់ទងបានក្នុងករណីចាំបាច់

ឈ្មោះ (នាម និង គោត្តនាម)...................................... ជាអក្សរឡាតាំង.................................

អាសយដ្ឋានទំនាក់ទំនង.................................................................................................

លេខទូរស័ព្ទ........................ លេខទូរសារ ............................ អ៊ីម៉ែល ..............................

ទំនាក់ទំនងរវាងភ្នាក់ងារក្រុមហ៊ុនមូលបត្រ និង អតិថិជនៈ

☐ ញាតិសន្តាន ☐ ស្គាល់តាមរយៈការណែនាំ (ឈ្មោះអ្នកណែនាំ...............................)

☐ មិត្តភក្តិ ☐ ពុំធ្លាប់មានទំនាក់ទំនងជាមួយគ្នា ☐ ផ្សេងៗ...............................

ឯកសារភ្ជាប់សម្រាប់ការស្នើសុំបើកគណនី

☐ អត្តសញ្ញាណបណ្ណថតចំលង ☐ សៀវភៅគ្រួសារថតចំលង ☐ លិខិតឆ្លងដែន

ឬទិដ្ឋការថតចំលង ☐ សៀវភៅធនាគារថតចំលង (រយៈពេល ០៦ ខែចុងក្រោយ)

យោបល់របស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ.................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

..........................................................................................................................

<table>
<tr>
<td>ហត្ថលេខារបស់ភ្នាក់ងារក្រុមហ៊ុនមូលបត្រ................................<br>ធ្វើនៅថ្ងៃទី...........ខែ..........ឆ្នាំ...<br>..........................................</td>
<td>ហត្ថលេខារបស់ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬអ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ<br>..........................................<br>ធ្វើនៅថ្ងៃទី.......ខែ.......ឆ្នាំ.......</td>
<td>ហត្ថលេខារបស់អតិថិជន<br>..........................................<br>ធ្វើនៅថ្ងៃទី...........ខែ...........<br>ឆ្នាំ.....................................</td>
</tr>
<tr>
<td colspan="3">ការព្រមព្រៀងលើការផ្ទេរសិទ្ធិ<br>អតិថិជន ក្រុមហ៊ុន</td>
</tr>
</table>

## ឧបសម្ព័ន្ធស្តីពីពាក្យស្នើសុំផ្តល់ប្រឹក្សា

ប្រកាសលេខ...០០៨/១១ គ.ម.ក.ប្រ.ក.

ចុះថ្ងៃទី២៧ខែមិថុនាឆ្នាំ២០១១

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ........................<br>ឈ្មោះភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ...................... | កាលបរិច្ឆេទនៃការស្នើសុំ<br>........................................................................ |

ឈ្មោះអតិថិជន(នាម និង គោត្តនាម)....................................ជាអក្សរឡាតាំង ..........................

ថ្ងៃ ខែ ឆ្នាំកំណើត ........................................................ សញ្ជាតិ .......................................

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន...........................................................................

កាលបរិច្ឆេទផុតសុពលភាព..........................ចេញដោយ.........................................................

លេខទូរស័ព្ទ..............................លេខទូរសារ..............................អ៊ីម៉ែល ..........................

អាសយដ្ឋានទំនាក់ទំនង...........................................................................................

លក្ខន្តិកៈគ្រួសារ ☐ នៅលីវ ☐ មានគ្រួសារ ☐ លែងលះ

មុខរបរ.....................................................មុខតំណែង ...............................................

អាសយដ្ឋានកន្លែងធ្វើការ...........................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ.....................................ប្រភេទអាជីវកម្ម.................................

រយៈពេលនៃអតីតភាពការងារ....................................................................................

ឈ្មោះសហព័ទ្ធ (នាម និង គោត្តនាម) ....................................ជាអក្សរឡាតាំង..........................

មុខរបរ.....................................................មុខតំណែង ...............................................

អាសយដ្ឋានកន្លែងធ្វើការ...........................................................................................

លេខទូរស័ព្ទកន្លែងធ្វើការ ..........................................................................................

ប្រភេទអាជីវកម្ម..............................................រយៈពេលនៃអតីតភាពការងារ .......................

ចំណេះដឹងលើការវិនិយោគ

☐ ល្អណាស់ ☐ ល្អ ☐ មានកម្រិត ☐ គ្មាន

បទពិសោធន៍ក្នុងសកម្មភាពវិនិយោគ

☐ បណ្ណូលធនាគារ ☐ ភាគហ៊ុន ☐ សញ្ញាបណ្ណ ☐ មូលបត្រផ្សេងទៀត ☐ គ្មាន

ឯកសារធនាគាររបស់អតិថិជន

ឈ្មោះធនាគារ.................................................................................................

លេខគណនីធនាគារ.............................................................................................

ប្រភេទគណនីធនាគារ..........................................................................................

---

បុគ្គលដែលអាចទាក់ទងបានក្នុងករណីចាំបាច់

ឈ្មោះ (នាម និង គោត្តនាម)..................................ជាអក្សរឡាតាំង ...................................

អាសយដ្ឋានទំនាក់ទំនង.........................................................................................

លេខទូរស័ព្ទ...............................លេខទូរសារ ..............................អ៊ីម៉ែល..............................

---

ទំនាក់ទំនងរវាងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ និង អតិថិជន៖

☐ ញាតិសន្តាន ☐ ស្គាល់តាមរយៈការណែនាំ (ឈ្មោះអ្នកណែនាំ...............................)

☐ មិត្តភក្តិ ☐ ពុំធ្លាប់មានទំនាក់ទំនងជាមួយគ្នា ☐ ផ្សេងៗ..............................

---

ឯកសារភ្ជាប់សម្រាប់ផ្តល់ប្រឹក្សា

☐ អត្តសញ្ញាណបណ្ណថតចំលង ☐ សៀវភៅគ្រួសារថតចំលង ☐ លិខិតឆ្លងដែន

ឬ ទិដ្ឋការថតចំលង ☐ សៀវភៅធនាគារថតចំលង (រយៈពេល ០៦ ខែចុងក្រោយ)

---

យោបល់របស់ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ.........................................................................

.................................................................................................................

.................................................................................................................

.................................................................................................................

---

| ហត្ថលេខារបស់ភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ | ហត្ថលេខារបស់ប្រធានភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគ ឬអ្នកគ្រប់គ្រងសាខា ឬនាយកប្រតិបត្តិ | ហត្ថលេខារបស់អតិថិជន |
| --- | --- | --- |
| ....................................... | ....................................... | ....................................... |
| ធ្វើនៅថ្ងៃទី.......ខែ......ឆ្នាំ......... | ធ្វើនៅថ្ងៃទី........ខែ......ឆ្នាំ........ | ធ្វើនៅថ្ងៃទី......ខែ......ឆ្នាំ..... |

---

ការព្រមព្រៀងលើការផ្ទេរសិទ្ធិ

អតិថិជន ក្រុមហ៊ុន

## ឧបសម្ព័ន្ធស្តីពីទម្រង់នៃកិច្ចព្រមព្រៀងអតិថិជន

**ប្រកាសលេខ...០០៥/១១...គ.ម.ក.ប្រ.ក.**

ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១

ទីកន្លែង និងកាលបរិច្ឆេទនៃកិច្ចព្រមព្រៀង:..............................

កិច្ចព្រមព្រៀងរវាង÷

- ក្រុមហ៊ុន :

ឈ្មោះ.......................................អាសយដ្ឋាន.........................................................

ជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណចុះបញ្ជីនៅ.............................................ប្រទេសកម្ពុជា

ភ្នាក់ងារក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ.................................................................

និង

- អតិថិជន :

ឈ្មោះ.......................................អាសយដ្ឋាន....................................................

លេខអត្តសញ្ញាណបណ្ណ/លេខលិខិតឆ្លងដែន.......................លេខបញ្ជីពាណិជ្ជកម្ម (ករណីជាស្ថាប័ន)

..................ថ្ងៃទី.......ខែ.........ឆ្នាំ.............។

**ភាគីទាំងពីរព្រមព្រៀងគ្នា ដូចខាងក្រោម :**

### សាចសា

១- ក្រុមហ៊ុនជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណឱ្យធ្វើអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជា............. .............. ដោយ គ.ម.ក.។

២-អតិថិជនមានបំណងជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួន ដើម្បីផ្តល់សេវាជួញដូរ និងផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

៣-អនុលោមតាមមាត្រា ៥៤ នៃអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រការ ៦ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណត្រូវចុះកិច្ចព្រមព្រៀងជាមួយអនាគតអតិថិជន។

៤-ភាគីទាំងពីរត្រូវអនុវត្តតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ដោយអនុលោមតាមច្បាប់ អនុក្រឹត្យ និងបទប្បញ្ញត្តិពាក់ព័ន្ធ ។

## និយមន័យ

៥-ពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងកិច្ចព្រមព្រៀងនេះ ត្រូវឱ្យនិយមន័យដោយអនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិដែលកំណត់ដោយ គ.ម.ក. និងច្បាប់ពាក់ព័ន្ធនៅព្រះរាជាណាចក្រកម្ពុជា។

និយមន័យខាងក្រោមនេះដែលត្រូវប្រើប្រាស់ក្នុងកិច្ចព្រមព្រៀង ÷

**កិច្ចព្រមព្រៀង**: សំដៅដល់កិច្ចព្រមព្រៀងអតិថិជន។

**ប្រាក់អតិថិជនគ្រប់គ្រាន់** : សំដៅដល់ប្រាក់ដែលអាចប្រើប្រាស់បាន នៅក្នុងគណនីសាច់ប្រាក់អតិថិជនក្នុងពេលជាក់លាក់មួយ សម្រាប់ការបញ្ជាទិញមូលបត្ររបស់អតិថិជន ដោយយកសមតុល្យក្នុងគណនីសាច់ប្រាក់អតិថិជនដកចេញនូវរាល់បំណុលអតិថិជនទាំងអស់ ការបញ្ជាទិញពីមុនទាំងអស់របស់អតិថិជន ព្រមទាំងប្រាក់ដែលអតិថិជនបានស្នើដក ឬស្នើទូទាត់ទៅតតិយជន។

**ធនាគារ** : សំដៅដល់ធនាគារពាណិជ្ជដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ និងការគ្រប់គ្រងនៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។

**ព័ត៌មានអតិថិជន** : សំដៅដល់ព័ត៌មានពាក់ព័ន្ធនឹងអតិថិជនដែលផ្តល់ឱ្យក្រុមហ៊ុនមូលបត្រ នៅពេលដែលបើកគណនីអតិថិជន ហើយត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ។

**បំណុលអតិថិជន** : សំដៅដល់ប្រាក់ដែលអតិថិជនជំពាក់ក្នុងការទូទាត់ទៅបុគ្គលផ្សេងទៀតដោយអនុលោមតាមកិច្ចព្រមព្រៀងនេះ ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធដែលមានជាអាទិ៍ កម្រៃជើងសាថ្លៃសេវា លាភការផ្សេងៗ ពន្ធ ឬចំណាយផ្សេងទៀតដែលទាក់ទងនឹងការលក់ ឬការទិញមូលបត្រ និងកម្រៃរដ្ឋបាលដែលទាក់ទងនឹងការធ្វើប្រតិបត្តិការលើគណនីសាច់ប្រាក់អតិថិជន។

**បញ្ជាអតិថិជន**: សំដៅដល់បញ្ជាទិញ ឬលក់មូលបត្ររបស់អថិតិជនទៅក្រុមហ៊ុនមូលបត្រ។

**ក្រមសីលធម៌វិជ្ជាជីវៈ** : សំដៅដល់ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារក្រុមហ៊ុនមូលបត្រ។

**អាជ្ញាបណ្ណ** : សំដៅដល់អាជ្ញាបណ្ណដែលផ្តល់ឱ្យក្រុមហ៊ុនដោយអគ្គនាយកនៃ គ.ម.ក.។

**ការជួញដូរមូលបត្រ**: សំដៅដល់ការជួញដូរមូលបត្របានចុះបញ្ជីនៅផ្សារមូលបត្រប្រតិស្រុត។

**សេវាកម្ម** : សំដៅដល់ការផ្តល់សេវាជួញដូរ និងផ្តល់ប្រឹក្សាដែលទាក់ទងនឹងមូលបត្រ។

**ប្រតិសិទ្ធិសកល**: សំដៅដល់បុគ្គលដែលទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចទូទៅពីបុគ្គលដទៃ។

**ប្រតិសិទ្ធិដោយឡែក**: សំដៅដល់បុគ្គលដែលទទួលបន្តសិទ្ធិមួយ ឬច្រើនជាកំណត់ផ្អែកតាមមូលហេតុនីមួយៗ។

## ៦- ការជ្រើសរើសក្រុមហ៊ុន

១- អតិថិជនជ្រើសរើសក្រុមហ៊ុនធ្វើជាភ្នាក់ងាររបស់ខ្លួនដើម្បីផ្តល់សេវាកម្មដោយគោរពតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ។ អតិថិជនព្រមព្រៀងអនុវត្តកាតព្វកិច្ចនានាដែលកើតចេញពីការអនុវត្តអាណត្តិដោយក្រុមហ៊ុនក្នុងដែនអនុញ្ញាតដែលផ្តល់ដោយអតិថិជនក្រោមកិច្ចព្រមព្រៀងនេះ។

២-ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការជួញដូរមូលបត្រក្នុងគណនីអតិថិជនក្នុងនាមអតិថិជន ដោយមិនមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជនតាមរយៈកិច្ចព្រមព្រៀងនេះ។

៣-ក្រុមហ៊ុនត្រូវធានាថា ក្រុមហ៊ុនបានទទួលអាជ្ញាបណ្ណដែលអនុញ្ញាតអោយផ្តល់សេវាកម្មដល់អតិថិជន។ ក្រុមហ៊ុនត្រូវផ្តល់សេវាកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រដល់អតិថិជនស្របតាមលក្ខខណ្ឌអាជ្ញាបណ្ណដែលបានផ្តល់ដោយអគ្គនាយកនៃ គ.ម.ក.។

## ៧- ការធ្វើបច្ចុប្បន្នកម្មព័ត៌មាន

១-ក្រុមហ៊ុនត្រូវទទួលស្គាល់ និងព្រមព្រៀងថាក្រុមហ៊ុនបានបំពេញទម្រង់ពាក្យស្នើសុំបើកគណនីអតិថិជន ដែលមានកំណត់នៅក្នុងឧបសម្ព័ន្ធរបស់ក្រមសីលធម៌វិជ្ជាជីវៈ។

២-អតិថិជនត្រូវធានាថា ព័ត៌មានដែលផ្តល់ឱ្យនៅពេលចុះកិច្ចព្រមព្រៀង ជាព័ត៌មានពិតប្រាកដ និងត្រឹមត្រូវ ។

៣-អតិថិជនត្រូវទទួលស្គាល់ថា ក្រុមហ៊ុនផ្តល់សេវាកម្មជូនអតិថិជនដោយផ្អែកលើព័ត៌មានអតិថិជន។ អតិថិជនយល់ព្រមជូនដំណឹងភ្លាមទៅក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរព័ត៌មានជាសារវន្តរបស់អតិថិជន។

៤-ក្រុមហ៊ុនត្រូវធ្វើបច្ចុប្បន្នកម្មការផ្លាស់ប្តូរព័ត៌មានទាំងឡាយណាទាក់ទងនឹងក្រុមហ៊ុន និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវព័ត៌មាននោះដែលកំណត់នៅក្នុងកិច្ចព្រមព្រៀង។ អនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ ក្រុមហ៊ុនត្រូវទទួលស្គាល់ និងយល់ព្រមថាក្រុមហ៊ុនផ្តល់ឱ្យអតិថិជននូវព័ត៌មានជាលាយលក្ខណ៍អក្សរមុនពេលអនុវត្តបញ្ជាក្នុងនាមអតិថិជន។ ចំណុចទី ៧ នៃកិច្ចព្រមព្រៀងនេះមិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

## ៨ .- ការជួញដូរមូលបត្រ

១-ក្រុមហ៊ុនត្រូវអនុវត្តការជួញដូរមូលបត្រក្នុងនាមអតិថិជននៅពេលមានបញ្ជាពីអតិថិជនតែប៉ុណ្ណោះ។ ក្រុមហ៊ុនមិនត្រូវធ្វើប្រតិបត្តិការគណនីឆន្ទានុសិទ្ធិក្នុងនាមអតិថិជន និងមិនអនុញ្ញាតនូវរាល់បញ្ជាពីអតិថិជនឱ្យអនុវត្តការជួញដូរមូលបត្រ ដោយផ្អែកលើមូលដ្ឋានឆន្ទានុសិទ្ធិក្នុងគ្រប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ លើកលែងតែមានការអនុញ្ញាតពី គ.ម.ក.។

២-អតិថិជនផ្តល់សិទ្ធិឱ្យក្រុមហ៊ុនធ្វើការងារចាំបាច់សមស្របក្នុងនាមអតិថិជន តាមបញ្ជាអតិថិជន ដើម្បី ÷

ក- បញ្ជូនបញ្ជារបស់អតិថិជន

ខ- ផ្ទេរមូលបត្រដែលត្រូវបានលក់ ឬទិញតាមបញ្ជារបស់អតិថិជន

គ- ធានាថារាល់ការផ្ទេរ បានកត់ត្រាត្រឹមត្រូវនៅប្រតិបត្តិកររក្សាទុកមូលបត្រ។

៣-ក្រុមហ៊ុនព្រមព្រៀងចាត់ចែងធ្វើការផ្ទេរមូលបត្រក្នុងនាមអតិថិជន ហើយត្រូវកត់ត្រាការផ្ទេរនោះ ដោយអនុលោមតាមក្រមសីលធម៌វិជ្ជាជីវៈ និងស្របតាមវិធាន ប្រព័ន្ធ ព្រមទាំងនីតិវិធីរបស់ប្រតិបត្តិកររក្សាទុកមូលបត្រ និងបទប្បញ្ញត្តិជាធរមាន។

៤-ក្រុមហ៊ុន និងអតិថិជនត្រូវទទួលស្គាល់ និងព្រមព្រៀងថា ÷

ក- ក្រុមហ៊ុនមិនត្រូវទិញមូលបត្រក្នុងនាមអតិថិជនឡើយ លើកលែងតែអតិថិជនផ្តល់ឱ្យក្រុមហ៊ុននូវប្រាក់គ្រប់គ្រាន់ក្នុងការទិញមូលបត្រ និងអតិថិជនយល់ព្រមថាមិនត្រូវធ្វើការដាក់បញ្ជាទិញមូលបត្រនៅតម្លៃលើសពីបរិមាណប្រាក់អតិថិជនដែលមានឡើយ និង

ខ-ក្រុមហ៊ុនមិនត្រូវលក់ស៊ីតសែល (short sell) ឡើយ និងអតិថិជនមិនត្រូវដាក់បញ្ជាលក់មូលបត្ររបស់ខ្លួនឡើយ លើកលែងតែមូលបត្រនោះបានចុះបញ្ជីនៅប្រតិបត្តិកររក្សាទុកមូលបត្រក្នុងឈ្មោះរបស់អតិថិជន និងអាចលក់បាន ។

៥-អតិថិជនព្រមព្រៀងតាមការកំណត់នៃបញ្ជារបស់ខ្លួន ហើយត្រូវទទួលស្គាល់ និងយល់ព្រមថា បញ្ជារបស់អតិថិជននឹងមិនត្រូវបានលុបចោល ឬផ្លាស់ប្តូរបន្ទាប់ពីបានអនុវត្តឡើយ។ បញ្ជារបស់អតិថិជនមិនអាចត្រូវបានលុបចោល ឬផ្លាស់ប្តូរ មុនពេលអនុវត្តតាមបញ្ជារបស់អតិថិជន លើកលែងតែអតិថិជនបានជូនដំណឹងដល់ក្រុមហ៊ុននូវការលុបចោល ឬការផ្លាស់ប្តូរនោះស្របតាមការតម្រូវរបស់ក្រុមហ៊ុន។ ចំណុចទី ៨ នៃកិច្ចព្រមព្រៀងនេះ មិនអនុវត្តចំពោះក្រុមហ៊ុនទីប្រឹក្សាវិនិយោគ និងភ្នាក់ងារផ្តល់ប្រឹក្សាវិនិយោគឡើយ។

៩.- វិធីសាស្ត្រក្នុងការដាក់បញ្ជា

១-អតិថិជនអាចដាក់បញ្ជាដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម ÷

ក-ជាលាយលក្ខណ៍អក្សរ

ខ-តាមរយៈទូរស័ព្ទ ទូរសារ និងតាមវិធីទំនាក់ទំនងអេឡិចត្រូនិចផ្សេងទៀតដែលកំណត់ដោយ គ.ម.ក.។

២-បញ្ជាអតិថិជនត្រូវបង្ហាញព័ត៌មានទាក់ទងនឹងការជួញដូរមូលបត្រ រួមមាន ឈ្មោះមូលបត្រ ប្រភេទមូលបត្រ បរិមាណមូលបត្រ និងថ្លៃមូលបត្រ និងកាលបរិច្ឆេទ។ ក្រុមហ៊ុនត្រូវធ្វើកំណត់ត្រាបញ្ជា

នោះក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ ឬថតសម្លេង ឬតាមអេឡិចត្រូនិចដើម្បីធ្វើជាភស្តុតាងនៃការដាក់បញ្ជា។

១០.- ការបដិសេធទទួលបញ្ជា

១-ក្រុមហ៊ុនមិនត្រូវអនុវត្តតាមបញ្ជាអតិថិជនទេ ប្រសិនបើការអនុវត្តបញ្ជាអតិថិជននោះផ្ទុយនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ឬលក្ខន្តិកៈនៃកិច្ចព្រមព្រៀងនេះ។ ក្រុមហ៊ុនមិនទទួលខុសត្រូវលើការខាតបង់ ថ្លៃដើម ឬការចំណាយរបស់អតិថិជនឡើយ ដែលបណ្តាលមកពីការបដិសេធរបស់ក្រុមហ៊ុនក្នុងការអនុវត្តតាមបញ្ជារបស់អតិថិជន។

២-ក្រុមហ៊ុនត្រូវជូនដំណឹងភ្លាមៗដល់អតិថិជនជាលាយលក្ខណ៍អក្សរ ក្នុងករណីមានការបដិសេធដូចមានចែងក្នុងកថាខណ្ឌទី១ ឬមានកំហុសឆ្គងក្នុងការអនុវត្តបញ្ជារបស់អតិថិជន ឬការអនុវត្តបញ្ជាដោយអនុលោមតាមលក្ខខណ្ឌនៃបញ្ជាអតិថិជន។

១១.- ការជូនដំណឹងការជួញដូរមូលបត្រ

ក្រុមហ៊ុនត្រូវជូនដំណឹងដល់អតិថិជននូវរាល់ប្រតិបត្តិការមូលបត្រ ដែលធ្វើក្នុងនាមអតិថិជនដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ។ អតិថិជនយល់ព្រមពិនិត្យយ៉ាងយកចិត្តទុកដាក់នូវការជូនដំណឹងនោះ ហើយជូនដំណឹងទៅក្រុមហ៊ុនវិញភ្លាមនូវភាពខុសគ្នារវាងកំណត់ត្រារបស់អតិថិ-ជន និងព័ត៌មានដែលបង្ហាញក្នុងសេចក្តីជូនដំណឹង។

១២.- គណនីសាច់ប្រាក់អតិថិជន

១- អតិថិជនផ្តល់សិទ្ធិដល់ក្រុមហ៊ុនចំពោះ ÷

ក-ការដាក់តម្កល់ប្រាក់ដែលទទួលបានពីអតិថិជន ឬក្នុងនាមអតិថិជនទៅក្នុងគណនីសាច់-ប្រាក់អតិថិជនដែលពាក់ព័ន្ធនឹងអតិថិជន

ខ-ការទទួលប្រាក់ពីការលក់មូលបត្រក្នុងនាមអតិថិជនតាមបញ្ជាចូលក្នុងគណនីសាច់ប្រាក់អតិថិជន

គ- ការទូទាត់ចេញពីគណនីសាច់ប្រាក់អតិថិជនសម្រាប់ការទិញមូលបត្រក្នុងនាមអតិថិជនតាមបញ្ជារបស់អតិថិជន

ឃ-ការទូទាត់សងបំណុលអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រ ពីគណនីសាច់ប្រាក់អតិថិជន

ង- ការទូទាត់ផ្សេងៗ ពីគណនីសាច់ប្រាក់អតិថិជនដែលតម្រូវដោយច្បាប់ និង

ច- ការដាក់ប្រាក់ចូល និងការដកប្រាក់ចេញពីគណនីសាច់ប្រាក់អតិថិជន នៅពេលមានបញ្ជាអតិថិជន ឬការណែនាំជាលាយលក្ខណ៍អក្សរពីអតិថិជន។

២- អតិថិជនមានសិទ្ធិទទួលរាល់ចំណូលការប្រាក់ដែលកើតមានក្នុងគណនីអតិថិជន។

១៣.- របាយការណ៍

១-ក្រុមហ៊ុនត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរដល់អតិថិជនទាក់ទងនឹងការជួញដូរមូលបត្រដូចខាងក្រោម ÷

ក- សេចក្តីជូនដំណឹងស្តីអំពីការជួញដូរមូលបត្រដោយអនុលោមតាមប្រការ ២១ នៃក្រមសីលធម៌វិជ្ជាជីវៈ

ខ- របាយការណ៍ប្រតិបត្តិការប្រចាំខែក្នុងគណនីអតិថិជន ដោយអនុលោមតាមប្រការ ២២ នៃក្រមសីលធម៌វិជ្ជាជីវៈ។

គ- របាយការណ៍ពាក់ព័ន្ធនឹងប្រាក់អតិថិជនដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រ។

២-អតិថិជនព្រមព្រៀងក្នុងការពិនិត្យយ៉ាងយកចិត្តទុកដាក់លើខ្លឹមសារនៃរបាយការណ៍ដែលផ្តល់ដោយក្រុមហ៊ុន ដើម្បីធានាថាខ្លឹមសារនៃរបាយការណ៍ដែលបានផ្តល់ឱ្យមានសង្គតិភាពនឹងកំណត់ត្រាផ្ទាល់ខ្លួន និងជូនដំណឹងដល់ក្រុមហ៊ុនភ្លាមនូវរាល់ភាពខុសគ្នាណាមួយ។

១៤.- លាភការ

១-ភាគីទាំងពីរទទួលស្គាល់ និងព្រមព្រៀងថាការបង់លាភការឱ្យក្រុមហ៊ុនដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះត្រូវបានកំណត់តាមតារាង [១] និងអាចប្រែប្រួលតាមការកំណត់របស់ គ.ម.ក.។

២- ក្រុមហ៊ុនអាចធ្វើបច្ចុប្បន្នកម្មតារាង [១] នៅពេលមានការផ្លាស់ប្តូរលាភការ និងត្រូវជូនដំណឹងដល់អតិថិជនជាលាយលក្ខណ៍អក្សរនូវរាល់ការផ្លាស់ប្តូរនោះ។ ដើម្បីឱ្យការតម្លើងលាភការដែលត្រូវបង់ដូចមានចែងក្នុងកិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្ត លុះត្រាតែកិច្ចព្រមព្រៀងនេះបានធ្វើបច្ចុប្បន្នកម្ម ហើយអតិថិជនបានជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងការយល់ព្រម។

៣-ក្រុមហ៊ុនត្រូវព្រមព្រៀងថា នៅពេលគិតថ្លៃសេវាពីអតិថិជនលើសចំនួនដែលមានចែងក្នុងតារាង [១] ត្រូវបង្វិលប្រាក់ដែលបង់លើសចូលក្នុងគណនីសាច់ប្រាក់អតិថិជនភ្លាមៗ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អតិថិជន។

១៥.- ផលប្រយោជន៍ និងទំនាក់ទំនង

ក្រុមហ៊ុនត្រូវបញ្ជាក់នូវរាល់ផលប្រយោជន៍ និងទំនាក់ទំនងទាំងអស់រវាងក្រុមហ៊ុន និងបុគ្គលផ្សេងទៀតដែលអាចមានឥទ្ធិពលដល់ក្រុមហ៊ុន ឬភ្នាក់ងារក្រុមហ៊ុនមូលបត្រក្នុងតារាង [២] ដោយអនុលោមតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀង និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

១៦.- ការតវ៉ា

១- ករណីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ ឬភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រមិនអនុវត្តតាមខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អតិថិជនអាចធ្វើបណ្តឹងជាលាយលក្ខណ៍អក្សរដោយត្រូវមានបញ្ជាក់ឈ្មោះ និងព័ត៌មានលំអិតនៃបុគ្គលដោះស្រាយការតវ៉ារបស់ក្រុមហ៊ុន។

២- ក្រុមហ៊ុនត្រូវយល់ព្រមដោះស្រាយវិវាទរបស់អតិថិជន ក្នុងអំឡុងពេល ០៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលការតវ៉ា។

១៧.- អ្នកតំណាងរបស់អតិថិជន

១-អតិថិជនអាចជ្រើសរើសបុគ្គលក្រៅពីក្រុមហ៊ុនមូលបត្រ ឬបុគ្គលពាក់ព័ន្ធរបស់ក្រុមហ៊ុនមូលបត្រធ្វើជាអ្នកតំណាង តាមរយៈលិខិតផ្ទេរសិទ្ធិ ឬការអនុញ្ញាតដោយច្បាប់ ដើម្បីដាក់បញ្ជាទិញ-លក់មូលបត្រ ឬបញ្ជាផ្សេងទៀតក្នុងនាមអតិថិជនពាក់ព័ន្ធនឹងការជួញដូរមូលបត្រតាមរយៈក្រុមហ៊ុនមូលបត្រ។ នៅពេលចុះកិច្ចព្រមព្រៀងនេះ អតិថិជនដែលមានបំណងជ្រើសរើសបុគ្គលដែលធ្វើជាអ្នកតំណាងត្រូវបញ្ជាក់ក្នុងតារាង [៣]។

២-មុនទទួលបញ្ជាពីអ្នកតំណាងរបស់អតិថិជន ក្រុមហ៊ុនត្រូវតម្រូវឱ្យអតិថិជនផ្តល់ឱ្យក្រុមហ៊ុនមូលបត្រនូវឯកសារដើម ឬថតចម្លងមានបញ្ជាក់ត្រឹមត្រូវនៃការអនុញ្ញាតនូវការជ្រើសរើសអ្នកតំណាង។

៣-អតិថិជនត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរភ្លាម ដល់ក្រុមហ៊ុនពីការដកហូតសិទ្ធិរបស់អ្នកតំណាង។ ក្រុមហ៊ុនអាចធ្វើប្រតិបត្តិការដែលទទួលបានពីអ្នកតំណាងតាមបញ្ជាទិញ-លក់មូលបត្រ ឬបញ្ជាផ្សេងទៀត លើកលែងតែមានការជូនដំណឹងផ្សេងទៀតពីអតិថិជន។

១៨.-ការរក្សាភាពសម្ងាត់

ក្រុមហ៊ុនយល់ព្រមថា មិនត្រូវដាក់បង្ហាញព័ត៌មានសម្ងាត់របស់អតិថិជន ឬព័ត៌មានសម្ងាត់ដទៃទៀតពាក់ព័ន្ធនឹងអតិថិជនដែលក្រុមហ៊ុនទទួលបានក្នុងការអនុវត្តសេវាកម្ម ស្របតាមកិច្ចព្រមព្រៀងនេះទៅឱ្យបុគ្គលណាមួយឡើយ លើកលែងតែមានករណីណាមួយដូចខាងក្រោម ÷

១-មានការយល់ព្រមជាលាយលក្ខណ៍អក្សរពីអតិថិជន ដោយមានបញ្ជាក់ពីបុគ្គលដែលមានសិទ្ធិទទួលនូវព័ត៌មានសម្ងាត់នោះ។

២-មានការស្នើសុំពី គ.ម.ក. ឬតុលាការនៃព្រះរាជាណាចក្រកម្ពុជា ឬ

៣-មានការតម្រូវដោយច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត ។

**១៩.- សេចក្តីថ្លែងព័ត៌មានហានិភ័យ**

១-អតិថិជនត្រូវទទួលស្គាល់ថាថ្លៃមូលបត្រអាចប្រែប្រួលឡើង ឬចុះហើយព័ត៌មានដែលត្រូវបានផ្តល់ឱ្យអំពីចំណូលនៃការវិនិយោគ ឬថ្លៃមូលបត្រដែលស្របតាមកិច្ចព្រមព្រៀងនេះនឹងមិនត្រូវបានធានាដោយក្រុមហ៊ុន ឬបុគ្គលផ្សេងទៀតឡើយ។

២-ក្រុមហ៊ុនត្រូវផ្តល់ព័ត៌មានបន្ថែម ពាក់ព័ន្ធនឹងសេចក្តីថ្លែងព័ត៌មានហានិភ័យផ្សេងទៀតដែលផ្អែកលើសេវាកម្មដែលបានផ្តល់ឱ្យ ប្រសិនបើមាន។

**២០.- ច្បាប់ចម្លងនៃកិច្ចព្រមព្រៀង**

កិច្ចព្រមព្រៀងនេះត្រូវធ្វើជាពីរច្បាប់ ដែលមានចុះហត្ថលេខា និងត្រារបស់ក្រុមហ៊ុន ឬស្នាមម្រាមដៃរបស់ភាគីទាំងសងខាង ហើយក្រុមហ៊ុនត្រូវផ្តល់ឱ្យអតិថិជនមួយច្បាប់ភ្លាមៗ និងមួយច្បាប់ទៀតរក្សាទុកនៅក្រុមហ៊ុន។

**២១.- បដិវាទកម្ម**

ដោយអនុលោមតាមប្រការ ៦ នៃក្រមសីលធម៌វិជ្ជាជីវៈ រាល់លក្ខខណ្ឌនៃកិច្ចព្រមព្រៀងមិនត្រូវលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬភាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់។ រាល់លក្ខខណ្ឌនៅក្នុងកិច្ចព្រមព្រៀងនេះ ឬ/និងកិច្ចព្រមព្រៀងផ្សេងទៀត រវាងភាគីទាំងពីរដែលលុបចោល ឬដាក់កំហិតលើសិទ្ធិអតិថិជន ឬភាតព្វកិច្ចរបស់ក្រុមហ៊ុនដែលទទួលស្គាល់ដោយច្បាប់ មិនមានអានុភាពអនុវត្តឡើយ។

**២២.-ការជូនដំណឹង**

១-រាល់របាយការណ៍ និងការជូនដំណឹងដែលផ្តល់ឱ្យអតិថិជនត្រូវស្របទៅតាមកិច្ចព្រមព្រៀងនេះ ឬក្រមសីលធម៌វិជ្ជាជីវៈ លើកលែងតែមានសំណើជាលាយលក្ខណ៍អក្សរផ្សេងពីនេះពីអតិថិជន។

២-អតិថិជនព្រមព្រៀងជូនដំណឹងភ្លាមៗដល់ក្រុមហ៊ុន នៅពេលមានការផ្លាស់ប្តូរអាសយដ្ឋាន ឬព័ត៌មានសម្រាប់ទំនាក់ទំនងផ្សេងទៀតរបស់ខ្លួន។ ករណីអតិថិជនខកខានមិនបានជូនដំណឹងដល់ក្រុមហ៊ុនពីការផ្លាស់ប្តូរទាំងនេះ រាល់របាយការណ៍ ឬការជូនដំណឹងត្រូវផ្ញើជូនអតិថិជនទៅកាន់អាសយដ្ឋានដែលក្រុមហ៊ុនបានដឹងចុងក្រោយ។

២៣.- ការបញ្ចប់កិច្ចសន្យា

១-ភាគីនីមួយៗមានសិទ្ធិបញ្ចប់កិច្ចព្រមព្រៀងនេះគ្រប់ពេលវេលា ដោយត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃដល់ភាគីម្ខាងទៀត។

២-ភាគីទាំងពីរយល់ព្រមថាការបញ្ចប់កិច្ចព្រមព្រៀងនេះ មិនប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចដែលមិនទាន់អនុវត្តចប់របស់ភាគីនីមួយៗ ដែលមានមុនពេលបញ្ចប់កិច្ចព្រមព្រៀងនេះ។

២៤.- កិច្ចព្រមព្រៀងរួម

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងរួមរវាងភាគីទាំងសងខាងដែលចែងអំពីការតែងតាំងក្រុមហ៊ុនមូលបត្រធ្វើជាភ្នាក់ងាររបស់អតិថិជន និងលក្ខខណ្ឌនៃការផ្តល់សេវាកម្ម ។ រាល់បទបង្ហាញ ឬសេចក្តីថ្លែងការណ៍ ឬកិច្ចព្រមព្រៀងផ្សេងទៀតទោះជាលាយលក្ខណ៍អក្សរ ឬក៏ផ្ទាល់មាត់រវាងភាគីទាំងសងខាងដែលពាក់ព័ន្ធនឹងបញ្ហានេះ មិនមានអានុភាពអនុវត្តឡើយ។

២៥.- ការកែប្រែ

កិច្ចព្រមព្រៀងនេះអាចកែប្រែនៅពេលមានការយល់ព្រមរវាងភាគីទាំងសងខាង។ នៅពេលមានការធ្វើវិសោធនកម្មច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលផ្ទុយទៅនឹងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនមូលបត្រត្រូវកែប្រែកិច្ចព្រមព្រៀងនេះ ឲ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យមូលបត្រដែលបានធ្វើវិសោធនកម្ម ដោយមិនចាំបាច់មានការយល់ព្រមពីអតិថិជន និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរឱ្យអតិថិជនអំពីការកែប្រែកិច្ចព្រមព្រៀងនេះ។

២៦.- ការចាត់តាំង

អតិថិជនព្រមព្រៀងថារាល់សិទ្ធិនិងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចព្រមព្រៀងនេះនឹងត្រូវផ្ទេរទៅឱ្យប្រតិសិទ្ធិសាកល ប្រតិសិទ្ធិដោយឡែក និងអ្នកតំណាងរបស់អតិថិជន ក្នុងករណីមានការផ្លាស់ប្តូរកម្មសិទ្ធិនៃមូលបត្រដែលកើតឡើងដោយប្រតិបត្តិការនៃច្បាប់ ការទទួលមរណភាពរបស់អតិថិជន ក្ស័យធន អសមត្ថភាព ដីកាតុលាការ ឬដោយហេតុផលណាមួយផ្សេងទៀត។ ក្នុងករណីនេះ ក្រុមហ៊ុនត្រូវចាត់ចែងនូវរាល់ការផ្ទេរមូលបត្រ និងការចុះបញ្ជីនៃការផ្ទេរនោះ។

២៧.- ច្បាប់គ្រប់គ្រង និងយុត្តាធិការ

១- កិច្ចព្រមព្រៀងនេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២-រាល់វិវាទដែលកើតចេញពីកិច្ចព្រមព្រៀងនេះ អាចដោះស្រាយតាមនីតិវិធីដោះស្រាយវិវាទដែលកំណត់ដោយ ត.ម.ក.។

**ដើម្បីឱ្យកិច្ចសន្យានេះមានសុពលភាព ភាគីទាំងពីរព្រមព្រៀងគ្នាដោយមានចុះហត្ថលេខា ឬស្នាមម្រាមដៃ :**

[ក្រុមហ៊ុន] *ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រា*

[អតិថិជន] *ហត្ថលេខា ឬស្នាមម្រាមដៃ ឈ្មោះពេញ និងត្រាករណីជាស្ថាប័ន*

## តារាងទី ១

## លាភការ

*ការកំណត់កម្រៃជើងសា ថ្លៃសេវា និងលាភការផ្សេងៗ*

| ប្រភេទកម្រៃ | ចំនួនប្រាក់ | ការគណនា |
|---|---|---|
| កម្រៃជើងសា | | |
| ថ្លៃសេវា | | |
| លាភការផ្សេងៗ | | |
| | | |
| | | |

## តារាងទី ២

## ផលប្រយោជន៍ និងទំនាក់ទំនង

*ផលប្រយោជន៍ និងទំនាក់ទំនងដែលអាចមានឥទ្ធិពលទៅលើក្រុមហ៊ុនក្នុងការផ្តល់សេវា*

| ឈ្មោះ | ទំនាក់ទំនងជាមួយក្រុមហ៊ុន | ការពន្យល់ពីឥទ្ធិពល |
|---|---|---|
| | | |
| | | |
| | | |

## តារាងទី ៣

## អ្នកតំណាងរបស់អតិថិជន

| ឈ្មោះអ្នកតំណាង | អាសយដ្ឋាននិងលេខទំនាក់ទំនង | ទំហំនៃការអនុញ្ញាតសិទ្ធិ |
|---|---|---|
| | | |
| | | |
| | | |